ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Nov-2013, 15:38
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី២២២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*
លោក រ៉ូជី ហ្វីលីព
*(Mr. Rogger PHILLIPS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា
លោក នីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*
លោក វ៉េង ហ៊ត់
លោក វីល្លៀម ស្មីត *(Mr. William SMITH)*
លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក លោក ឃីត រេយ៍ន័រ
*(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិុចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

លោក ប៉ាស្កាល់ អាលប័ន
*(Mr. Pascal AUBOIN)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីក្រោមបន្ទប់សវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។

សូមអរគុណលោកប្រធាន។

[០៩:០១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ និងសាធារណជនជាទីទាំងអស់សាជាថ្មី។ តទៅនេះនឹងសូមធ្វើសេចក្តីសន្និដ្ឋានការពារបញ្ចប់ចំពោះករណី០០២/០១។ មុននឹងបញ្ចប់កាលពីថ្ងៃសុក្រ ខ្ញុំបានលើកអំពីអត្តចរិត និងតួនាទីរបស់លោក ខៀវ សំផន នៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់៧៥។ ឥឡូវនេះ ខ្ញុំបាទសូមបន្តដូចតទៅ៖

នៅក្នុងចលនាខ្មែរក្រហម លោក ខៀវ សំផន ស្ថិតនៅក្នុងចំណោមជនស្នេហាជាតិ ដែលលោកនៅតែត្រូវគេចាត់ទុកជានិច្ចថាជាបញ្ញាជន ដែលមិនស្ថិតនៅក្នុងចំណោមជនស្នូលតាំងពីដំបូងនៃបុគ្គលដែលមានអំណាចមួយក្តាប់តូច។ ទោះបីជាលោកបានធ្វើអ្វីៗ ដើម្បីបុព្វហេតុបដិវត្តន៍ក្តី ឬក៏មិនបាន

ធ្វើដូច្នោះក្តី។

លោក ខៀវ សំផន បានរៀបរាប់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ អំពីលក្ខខណ្ឌដ៏តឹងតែងនៃការចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាថា សូមដកស្រង់៖ "ចំពោះបក្សកុម្មុយនីស្តកម្ពុជា កាលដែលខ្ញុំបានចូលបក្សបារាំង មិនមែនមានន័យអ្វីទេ ពីព្រោះលក្ខខណ្ឌរបស់គេតឹងរ៉ឹងជាងបក្សបារាំងឆ្ងាយណាស់។ ទី១ ត្រូវមានសកម្មភាពប្រយុទ្ធ ហើយត្រូវបានឆ្លងកាត់លត់ដំ កសាងសាកល្បងក្នុងការតស៊ូបដិវត្តន៍សាចុះសាឡើង។ ទី២ ខ្ញុំត្រូវមានវណ្ណភាពល្អ តែខ្ញុំមិនមានវណ្ណភាពល្អទេ ពីព្រោះខ្ញុំជាបញ្ញាជនថ្នាក់ខ្ពស់ រៀនសូត្រនៅប៉ារីស ដែលគេហៅថាវណ្ណភាពល្អហ្នឹង ទាល់តែវណ្ណៈកសិករ ហើយកសិករក្រទៀត។ ដូច្នេះសូម្បីតែថាការតស៊ូលត់ដំ សាកល្បងសាចុះសាឡើង ក៏ខ្ញុំមិនដែល។ ដូច្នេះមានន័យថា ខ្ញុំមិនបានបំពេញលក្ខណៈសម្បត្តិទាំងពីរនេះទេ"។

[០៩:០៣:៥៨]

នេះសបញ្ជាក់ឲ្យឃើញថា លោក ខៀវ សំផន មិនបានបំពេញលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជានោះឡើយ។ ហេតុដូច្នេះហើយ ទើបលោកមិនត្រូវបានគេប្រគល់អំណាចជាក់ស្តែងណាមួយនៅក្នុងបក្ស។

ចំពោះតំណែងនៅក្នុងរណសិរ្សនៃរាជរដ្ឋាភិបាលរួបរួមជាតិវិញ ជាតំណែងខ្ពស់ តែគ្មានអំណាចដូចលោក ខៀវ សំផន បានកត់សម្គាល់ច្បាស់លាស់ថា សូមដកស្រង់៖ "ហេតុអ្វីបានខ្ញុំដែលមើលទៅក្រៅមកឃើញថា កាន់តំណែងខ្ពស់? ហើយបែរជាមិនបានចូលរួមក្នុងការសម្រេចអ្វីធំដុំនៃការរបស់បក្ស ឬកិច្ចការរបស់ប្រទេសនោះ គឺដោយសារ ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកខ្ញុំជាបញ្ញាជនរត់មករស់នៅបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាមនុស្សរបស់បក្សទេ។ នេះជាការពិតនៅមុនឆ្នាំ១៩៧៥ ហើយនៅថ្ងៃតៗមកក្រោយទៀតក៏នៅតែយ៉ាងនេះ"។ សូមចប់ការដកស្រង់។

លោក ហ្វីលីព ស្សូត ដែលជាអ្នកជំនាញក៏បានធ្វើការអះអាងនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ អំពីតួនាទីរបស់លោក ខៀវ សំផន ផងដែរ។ ដោយលោកបានបញ្ជាក់ថា "លោក ខៀវ សំផន មិនមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមជាសមាជិកនៃគណៈអចិន្ត្រៃយ៍ពេញសិទ្ធិនោះឡើយ។ ប៉ុន្តែលោក ខៀវ សំផន គឺជាបញ្ញាជនដែលគាត់មិនបានឆ្លងកាត់តួនាទីជាប្រធានភូមិភាគពីមុនមកទេ"។ នេះអាចបញ្ជាក់ឲ្យឃើញថា លោក ខៀវ សំផន បានទទួលតំណែងដោយសារតែប្រជាប្រិយភាពដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវការប្រើ មិនមែនតាមរយៈការតស៊ូលត់ដំនោះទេ។

[០៩:០៥:៥៥]

ដូចលោក ហ្វីលីព ស្សូត បានផ្តល់នូវសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ថា៖“មូលហេតុដែល -- មូលហេតុនេះ គឺដោយសារគាត់ស្ថិតនៅមុខតំណែងពិសេសមួយនៅក្នុងកណ្តាលនៃអំណាច ហើយជាមុខតំណែងវិសាមញ្ញមួយដែល ប៉ុល ពត ចង់ឲ្យគាត់ត្រង់នោះ ហើយគេអាចនឹងនិយាយថា ប៉ុល ពត បានមើលឃើញ ខៀវ សំផន ថាជាអ្នកដែលអាចទទួលនូវភារកិច្ចដឹកនាំច្រើន”។ តាមការឆ្លើយអះអាងរបស់លោក មាស វឿន នៅចំពោះអង្គជំនុំជម្រះនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ថា សូមដស្រង់៖ “លោក ខៀវ សំផន មិនបានធ្វើអ្វីទេ គ្រាន់តែនៅធម្មតាដើម្បីគេចឲ្យផុតពីការរករឿងគាត់ពីភ្នំពេញ”។ សូមចប់ការដកស្រង់។

ចេញពីព្រឹត្តិការណ៍នោះ លោក ខៀវ សំផន មិនអាចក្លាយទៅជាអ្នកដឹកនាំដ៏ពិតប្រាកដសោះឡើយ ហើយត្រូវកម្រិតត្រឹមតែតួនាទីជាពិធីការ ឬមានសារៈសំខាន់តិចជាងនោះ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ លោក ហ្ស៊ូឡង់ ហ្គោហ្វ្រេស *(Jullian Gaufres)* បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា៖ “លោក ខៀវ សំផន កាលនុ៎ង គាត់នៅលើវទេ ហើយគាត់ធ្វើអ្វីៗទាំងអស់ហ្នឹង គឺដើម្បីអភិវឌ្ឍប្រទេសរបស់គាត់។ ដោយចូលរួមសកម្មភាពផ្សេងៗ ហើយគោលបំណងចម្បងរបស់គាត់ហ្នឹង គឺថាធ្វើឲ្យលក្ខខណ្ឌជីវិត ជីវភាពប្រជាជនកម្ពុជាប្រសើរជាងមុន ហើយនិងដើម្បីឲ្យស្ថានភាពសេដ្ឋកិច្ចឲ្យបានប្រសើរឡើង”។ ចប់ការដកស្រង់។

តាមការពិនិត្យទៅលើការបង្ហាញសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ដូចបានរៀបរាប់ខាងលើ សបញ្ជាក់ឲ្យឃើញថា លោក ខៀវ សំផន មានអត្តចរិតស្លូតបូត សុភាពរាបសា ស្រឡាញ់យុត្តិធម៌ និងការរីកចម្រើនដែលផ្តល់នូវសុខុមាលភាព និងការអភិវឌ្ឍដល់សង្គម។

[០៩:០៨:១៤]

នៅចន្លោះឆ្នាំ១៩៧០ ដល់ ១៩៧៥ នៅក្នុងប៉ុន្មានឆ្នាំដំបូងនៃការរត់គេចខ្លួន លោក ខៀវ សំផន បាននៅដាច់ពីគេ នៅស្រុកស្រែចម្ការ លោកគ្មានតួនាទី និងសកម្មភាពនៅក្នុងចលនាបដិវត្តន៍ទាល់តែសោះ។ ជំពូកនានាដែលសរសេរក្នុងដីកាដំណោះស្រាយ ហើយដែលពិពណ៌នាពីសកម្មភាពនៃបក្សកុម្មុយនីស្តកម្ពុជា ចាប់និយាយពីការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងរចនាសម្ព័ន្ធបក្ស ចាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ តែប៉ុណ្ណោះ។

នៅថ្ងៃក្រោយរដ្ឋប្រហារ ប៉ុល ពត និងសម្តេច សីហនុ នៅឯក្រុងប៉េកាំងដូចគ្នា។ សម្ព័ន្ធភាព

រវាងអ្នកទាំងពីរក៏បានចាប់ផ្តើមឡើង។ ប៉ុល ពត មើលឃើញភ្លាមៗនូវអត្ថប្រយោជន៍ក្នុងការពង្រីកចលនាបដិវត្តន៍ដោយយកលោក ខៀវ សំផន ធ្វើជាអ្នកទាក់ទងជាមួយសម្តេច សីហនុ ។ លោក ខៀវ សំផន បានទទួលដំណឹងថា គេបានប្រគល់ជូនលោកនៅឋានន្តរស័ក្តិជាផ្លូវការយ៉ាងមហាអធិកអធមក្នុងអង្គភាពផ្សេងៗនៃរណសិរ្សរបស់សម្តេច សីហនុ-ខ្មែរក្រហមនៅកណ្តាលព្រៃ។

[០៩:០៩:២៨]

លោក ខៀវ សំផន បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ថា សូមដកស្រង់៖ “លោកបានទទួលតំណែងជាឧបនាយករដ្ឋមន្ត្រីខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គមេបញ្ជាការខ្យល់។ ការពិតខ្ញុំគ្មានឥទ្ធិពលអ្វីបន្តិចក៏គ្មានដែរ នៅលើកងទ័ព សូម្បីតែអង្គភាពតូចមួយក៏គ្មាននៅក្រោមបង្គាប់របស់ខ្ញុំដែរ។ ផ្ទុយទៅវិញ ខ្ញុំត្រូវលះបង់អត្តិភាពរបស់ខ្ញុំ កិត្តិយសរបស់ខ្ញុំដើម្បីឲ្យខ្ញុំអាចបំពេញភារកិច្ចជូនមាតុភូមិរបស់ខ្ញុំ ដែលកំពុងត្រូវរងគ្រោះថ្នាក់ដល់អាយុជីវិត”។ សូមបញ្ចប់ការដកស្រង់។

តាមការឆ្លើយអះអាងនេះ គឺថាអ្វីដែលលោកចង់បាននោះគឺការរួបរួមកម្លាំងជាតិក្រោយពីជួបវិបត្តិសង្គ្រាមធ្ងន់ធ្ងរដោយសារតែប្រទេសធំៗច្បាំងគ្នា។ ដោយលោកបានអះអាងនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ បន្ថែមទៀតថា សូមដកស្រង់៖ “ក្រោយពេលរដ្ឋប្រហារខ្ញុំគ្រាន់តែឲ្យកម្លាំងជាតិទាំងអស់រួបរួមគ្នាសាគ្គីតស៊ូ។ ដល់ក្រោយរដ្ឋប្រហារមក វាសង្គ្រាមវៀតណាមវាហូរហៀរចូលមកជាតិក្នុងដីយើង មហាយក្សទាំងអស់ដែលគេច្បាំងគ្នានៅវៀតណាមខាងត្បូង ក្រោយរដ្ឋប្រហារ គេមកច្បាំងគ្នានៅក្នុងទឹកដីយើងនៅលើជាតិយើង”។ លោក លោកស្រីចៅក្រម សូមបិទដកស្រង់។

[០៩:១១:១៥]

លោក លោកស្រីចៅក្រម សង្គ្រាមនៅកម្ពុជានៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានចរិតលក្ខណៈជាសង្គ្រាមតំបន់ មិនមែនជាសង្គ្រាមស៊ីវិលសុទ្ធសាធនោះទេ។ ការទម្លាក់គ្រប់បែកដំបូងនៅលើទឹកដីកម្ពុជានៅឆ្នាំ១៩៦៦ ហើយបានរីកធំថែមទៀត នៅបន្ទាប់ពីសង្គ្រាមវៀតណាមផ្ទុះឡើងនៅឆ្នាំ១៩៦៨ ដែលបានប្រែក្លាយទៅជាសង្គ្រាមនៅក្នុងតំបន់ឥណ្ឌូចិន។ ហើយសង្គ្រាមនេះបានបង្ហាញនូវសញ្ញាណជាលក្ខណៈអន្តរជាតិកាន់តែច្បាស់ថែមទៀត បន្ទាប់ពីមានរដ្ឋប្រហារថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ដោយសារឥទ្ធិពលមនោគមន៍វិជ្ជានៃសង្គ្រាមត្រជាក់។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១២ លោក ដេវីដ ឆេនដ៍ល័រ បានឆ្លើយថា សូមដកស្រង់៖ “វាជាធាតុផ្សំនៃសង្គ្រាមជាមួយវៀតណាម ដែលវៀតណាមគេមិនចាត់ទុកថាជាសង្គ្រាមប្រឆាំងនឹងវៀត-ណាមទេ តែជាសង្គ្រាមប្រឆាំងនឹងភាគីនៅក្នុងតំបន់”។ សូមចប់ការដកស្រង់។

ហេតុនេះយើងឃើញថា ការជ្រៀតចូលនៃកងទ័ពបរទេសមកប្រយុទ្ធគ្នានៅលើទឹកដីកម្ពុជាបានធ្វើឲ្យទង់ទ្រាយនៃសង្គ្រាមកាន់តែធំឡើង ហើយបានទាញភាគីកម្ពុជាដែលកំពង់តែច្បាំងគ្នាឲ្យធ្លាក់ចូលក្នុងសង្គ្រាមនោះដែរ។

ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើផ្លូវហូជីមិញ និងការតាមទម្លាប់គ្រាប់បែកមកលើពួកវៀតកុងនៅលើទឹកដីកម្ពុជា ដូចលោក ដេវីដ ឆេនដ៍ល័រ បានអះអាងបន្ថែមថា សូមដកស្រង់៖ “ទាក់ទងនឹងវៀតណាម និងសហរដ្ឋអាមេរិកហ្នឹង ហើយនៅឆ្នាំ១៩៧៣ គឺជាឆ្នាំដែលគេទម្លាក់គ្រាប់បែកច្រើនជាងគេនៅពេលដែលវាមានការទាក់ទងទៅនឹងសង្គ្រាមនៅវៀតណាម។ ហើយជាការទម្លាក់គ្រាប់បែក ឬជម្លោះដោយមូលហេតុសមហេតុសមផលរវាងកម្ពុជា និងសហរដ្ឋអាមេរិកនោះ”។ សូមចប់ការដកស្រង់។

[០៩:១៣:៣៤]

រដ្ឋាភិបាលសហរដ្ឋអាមេរិកបានគាំទ្ររដ្ឋាភិបាល លន់ នល់ ដែលជាសម្ព័ន្ធមិត្តរបស់ខ្លួន ដើម្បីតាមកម្ទេចពួកខ្មែរក្រហម ដែលបានប្រែក្លាយជម្លោះនៅកម្ពុជាទៅជាសង្គ្រាមក្នុងតំបន់ ដោយសារការចូលរួមរបស់សហរដ្ឋអាមេរិក និងភាគីវៀតណាម។ ដូចលោក អាល់ រ៉ុក្កូហ្វ លោកបានជម្រាបជូនអង្គជំនុំជម្រះនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ថា សូមដកស្រង់៖ “ការទម្លាក់គ្រាប់បែកអាមេរិកហ្នឹង គឺជាការជួយខាងភាគីរដ្ឋាភិបាលកម្ពុជា គឺថាកម្ពុជាពឹងផ្អែកទៅលើអាមេរិកនៅពេលនោះ។ ទ័ពអាកាសខ្មែរនៅពេលនោះ គឺមានលក្ខណៈទន់ខ្សោយ។ ដូច្នេះគឺមិនអាចពឹងផ្អែកលើទ័ពអាកាសខ្មែរបានទេ”។ សូមចប់ការដកស្រង់។

នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ នៅចំពោះមុខអង្គជំនុំជម្រះលោក ប៉ុងសូដ៏ ក៏បានឆ្លើយអះអាងអំពីការចូលលុកលុយប្រទេសកម្ពុជាពីសំណាក់កងទ័ពវៀតណាមកុម្មុយនីស្តផងដែរថា សូមដកស្រង់៖ “ហើយពេលនោះកងទ័ពវៀតណាម វៀតណាមកុម្មុយនីស្ត វៀតណាមខាងជើង ចូលលុកលុយប្រទេសកម្ពុជា ហើយចាប់យុវជនទាំងអស់បង្កើតកងទ័ពរំដោះជាតិកម្ពុជា”។ សូមចប់ការដកស្រង់។

[០៩:១៥:០៥]

ហេតុដូច្នេះការទទួលតំណែងក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា របស់លោក ខៀវ សំផន គឺដើម្បីការពារបូរណភាព និងឯករាជ្យជាតិនៃកម្ពុជាក្នុងនាមជាជនស្នេហាជាតិដែលជាការសម្រេចចិត្តដ៏ត្រឹមត្រូវ។ ហេតុដូច្នេះហើយទើបលោក ខៀវ សំផន សុខចិត្តធ្វើជាតំណាងដើម្បីជាស្ពានសម្រាប់ទំនាក់ទំនងរវាងសម្តេច សីហនុ ដែលលោកគង់នៅប៉េកាំងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាដែលមានលទ្ធភាពដឹកនាំការតស៊ូនៅក្នុងប្រទេស ដើម្បីរួមគ្នាប្រមូលកម្លាំងជាតិទាំងមូលក្នុងការការពារកម្ពុជាមួយឯករាជ្យ អធិបតេយ្យ កុំឲ្យរលំរលាយសាបសូន្យ។ ពីព្រោះតែលោកស្វែងយល់ថា សម្ព័ន្ធភាពសម្តេចនរោត្តម សីហនុ ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាអាចធ្វើឲ្យចលនាថ្មីមួយនេះទទួលបានជោគជ័យ។ ដោយលោក ខៀវ សំផន គិតឃើញថា បើគ្មានរូបលោកធ្វើជាស្ពានទេ បក្សកុម្មុយនីស្តកម្ពុជានឹងសម្តេច នរោត្តម សីហនុ មិនអាចរួបរួមគ្នាបានឡើយ។ ហេតុនេះទើបលោកចេញមុខជាអ្នកដឹកនាំសំខាន់មួយនៃកម្លាំងតស៊ូនៅក្នុងប្រទេស បើទោះបីជាលោកមានការទើសទាល់ខ្លាំងណាស់ចំពោះតំណែងខ្យល់ទាំងនោះក៏ដោយ។ ដោយស្ថិតក្នុងសភាពការណ៍ចំពោះមុខ លោក ខៀវ សំផន ត្រូវតែជ្រើសរើសយកការបង្រួបបង្រួមជាតិជាជាងមុខមាត់។ ថ្វីត្បិតវាជារឿងគួរឲ្យអាម៉ាស់ក្នុងការទទួលយកតំណែងខ្យល់ទាំងនោះក៏ដោយ។

[០៩:១៦:៤៣]

ឥឡូវនេះ សូមអង្គជំនុំជម្រះពិនិត្យមើលថា ហេតុអ្វីបានឈ្មោះលោក ខៀវ សំផន ត្រូវបានលើកយកមកពិភាក្សាដើម្បីឲ្យកាន់តំណែងដ៏ធំមហិមាក្នុងចលនាថ្មីរបស់ហ្រ្គុងនិងហ្វុង ដោយហេតុថាភក្តីភាពនៃប្រជាជនកម្ពុជាចំពោះសម្តេច សីហនុ និងភាពមិនចេះស៊ីសំណូករបស់លោក ខៀវ សំផន ធ្វើឲ្យសម្ព័ន្ធនេះក្លាយទៅជាចំណុចវិជ្ជមានសម្រាប់ពួកខ្មែរក្រហម។

លោក ហ្វីលីព ស្បូត បានឆ្លើយចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ដោយបញ្ជាក់អំពីវត្តមានរបស់សម្តេច សីហនុ ដែលជាប្រធានចលនាតស៊ូ ហើយលោក ខៀវ សំផន ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា សូមដកស្រង់៖ “ជាមនុស្សម្នាក់ដែលមានភាពស្មោះត្រង់ ហើយមនុស្សម្នាក់ដែលមានភាពលេចធ្លោ។ សម្តេច សីហនុ គាំទ្រខ្មែរក្រហម និងភាពដឹកនាំនៃចលនាតស៊ូប្រឆាំងរបប លន់ នល់ គាត់បានផ្សះផ្សាថ្នាក់ដឹកនាំកម្ពុជាជាច្រើន។ កិត្តិយស ខៀវ សំផន ជារឿងមួយសំខាន់”។ សូមចប់ការដកស្រង់។ លោក ហ្វីលីព ស្បូត ក៏បានបញ្ជាក់ផងដែរអំពីប្រជាប្រិយភាពរបស់សម្តេច សីហនុ ក្នុងចំណោមប្រជារាស្ត្រខ្មែរ ដែលអាចញ៉ាំងឲ្យខ្មែរក្រហមអាចជ្រើសរើសកងទ័ពបាន

យ៉ាងច្រើន បន្ទាប់ពីមានការអំពាវរបស់សម្តេចក្រោយថ្ងៃរដ្ឋប្រហារ។

ការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់របស់អាមេរិក និងអំពើអាក្រក់នៃរបប លន់ នល់ បាន ពន្លឿននូវសកម្មភាពចូលរួមរបស់ប្រជាជនកម្ពុជាក្នុងចលនាតស៊ូ។ ចាប់តាំងពីការចាប់កំណើតនៃហ្វ៊ុង និងការដាក់រូបលោក ខៀវ សំផន ឲ្យធ្វើជាអ្នកតំណាងសាធារណៈនៃចលនាបដិវត្តន៍ គឺជាតួនាទីដែល នៅជាប់នឹងរូបលោករហូត។ បន្ទាប់មក ប៉ុល ពត បានអញ្ជើញលោកឲ្យទៅជួបនៅក្នុងទីបញ្ជាការនៅឯ ខេត្តរតនគិរី។ នៅទីនោះហើយដែលលោក ខៀវ សំផន សុខចិត្តផ្តល់កិត្តិនាមរបស់លោកជូនរណសិរ្ស ដែលលោកជឿជាក់ ដើម្បីការពារគុណសម្បត្តិនានា ដែលហួសឆ្ងាយពីមនោគមន៍វិជ្ជាកុម្មុយនីស្ត។

[០៩:១៩:០២]

ដូចដែលលោកបានឆ្លើយតបភ្លាមៗទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៣ ដែលបានសួរមកលោក។ លោកបានឆ្លើយថា សូមដកស្រង់៖ “ចង់ជួយប្រមែប្រមូលកម្លាំង ជាតិដើម្បីធ្វើឲ្យសង្គ្រាម (សូមទោស) លោកចង់ជួយប្រមែប្រមូលកម្លាំងជាតិដើម្បីធ្វើសង្គ្រាមកាលពី សម័យនោះ”។ សូមចប់ការដកស្រង់។ នៅក្នុងបរិបទនេះហើយ លោក ខៀវ សំផន ត្រូវបានគេដាក់ឲ្យ កាន់តំណែងជាអនុប្រធាននៃហ្វ៊ុង។ អគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធរបស់ហ្វ៊ុង ឬថែមទាំងជា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃហ្រ៊ុង។

នៅក្នុងបញ្ជីនៃតំណែងស្រមោលទាំងអស់នោះ និងនៅក្នុងឱកាសនៃសមាជលើកទី៣ នៃបក្ស កុម្មុយនីស្តកម្ពុជាដែលបានប្រព្រឹត្តទៅនៅព្រៃនៅឆ្នាំ១៩៧១ លោក ខៀវ សំផន បានក្លាយទៅជាសមា-ជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិមនៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ គេសង្កេតឃើញហេតុផលនយោ បាយដូចគ្នានេះផងដែរ ដែលលោក ខៀវ សំផន បន្តធ្វើតទៅទៀតនៅខណៈដែលសម្តេច សីហនុ លាលែងពីតំណែងស្របពេលដែលដាក់បញ្ចូលរូបលោក ក្នុងតំណែងជាប្រធានគណៈប្រធានរដ្ឋ និងជា សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៅខែមីនា ឆ្នាំ១៩៧៦។ ជាការពិតណាស់ការតែងតាំង ទាំងនេះ មិនមែនមានន័យថាជាដំណើរការល្អឥតខ្ចោះនៅក្នុងបក្សនោះឡើយ ប៉ុន្តែវាជាការតែងតាំងបែប យុទ្ធសាស្ត្រ។

[០៩:២១:០០]

តាមការពិតលោក ខៀវ សំផន គ្មានការទទួលខុសត្រូវខាងយោធា ឬខាងនយោបាយឡើយ។ ហ្រ៊ុងគ្រាន់តែជារដ្ឋាភិបាលគ្មានអំណាច។ រីឯអំណាចពិតវិញវាស្ថិតនៅក្នុងដៃនៃគណៈអចិន្ត្រៃយ៍ ហើយ

អំណាចនោះនៅតែបែបនេះរហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម។ គោលការណ៍លាក់ការណ៍សម្ងាត់ដែលមាននៅក្នុងចលនាខ្មែរក្រហម ត្រូវបានលើកឡើងដោយសាក្សីទាំងអស់ដែល ធ្លាប់បានកាន់កាប់មុខងារនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ។

ការរក្សាការសម្ងាត់មានសារៈសំខាន់ណាស់ សម្រាប់ឱ្យចលនាដែលតែងតែត្រូវគេដេញតាមចាប់នៅទីក្រុង និងនៅក្នុងព្រៃអាចរស់បាន។ ការរក្សាការសម្ងាត់នេះ គឺជាដើមហេតុនៃការដាក់ឈ្មោះបដិវត្តន៍ និងការដាក់លេខកូដសម្រាប់ការិយាល័យនានាដើម្បីបង្វែងដាន។ ការដែលដាក់បញ្ចូលជាមុននូវតួអង្គក្លែងក្លាយ ដែលខ្លួនគ្មានអំណាចពិត ក៏ចូលរួមក្នុងគោលការណ៍នេះដែរ។ ដោយនៅខាងក្រោយឆាក និងមិនចេញមុខ ប៉ុល ពត មានសេរីភាពក្នុងការដឹកនាំតាមចិត្តរបស់គាត់។

លោក ហ្វីលីព ស្សូត ក៏បានអះអាងបែបនេះដែរ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ លោក ហ្វីលីព ស្សូត បានឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះពីបញ្ហាសន្តិសុខ និងបញ្ហាប្រត្តកូលនៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ពាក់ព័ន្ធនឹងលោក ខៀវ សំផន ដោយបញ្ជាក់ថា លោកបានរស់នៅក្នុងព្រៃមិនអាចដើរទៅណាបានទេ ដោយលោកបានអះអាងថា សូមដកស្រង់៖ “លោក ខៀវ សំផន នាពេលនោះគឺថាគាត់គ្រាន់តែជាមេដឹកនាំដែលមានតែឈ្មោះទេសម្រាប់បក្សកុម្មុយនីស្តកម្ពុជានោះ ដោយមានឋានៈជាអគ្គមេបញ្ជាការ។ ប៉ុន្តែពេលនោះនៅក្នុងឆ្នាំ៧៣ ឬ ៧៤ គាត់បានក្លាយជាសមាជិកមជ្ឈិមបម្រុង។ ទោះយ៉ាងណាក៏ដោយ ក៏គាត់មិននៅជិតគណៈកម្មាធិការអចិន្ត្រៃយ៍ គាត់មិននៅជិតអ្នកដែលមានតួនាទីធ្វើសេចក្តីសម្រេចនោះទេ។ ប៉ុន្តែពេលហ្នឹងគាត់ គឺជាមនុស្សម្នាក់ដែល ប៉ុល ពត ទុកចិត្តដោយសារគាត់ធ្វើអ្វីតាមគេប្រាប់។ ប៉ុន្តែពេលហ្នឹងគាត់ស្ថិតក្នុងស្ថានភាពមួយដែលអាចមានបញ្ហាសន្តិសុខច្រើនក្នុងការដើរហើរ”។ សូមចប់ការដកស្រង់។

[០៩:២៣:៤៧]

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ លោក ហ្វីលីព ស្សូត បានទទួលស្គាល់ ខ្លឹមសារនៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *“ប៉ុល ពត៖ អាណាតូមិ អូហ្វ អឺ ណាយមែរ”* ត្រង់ ERN ជាភាសាបារាំង 00639455 ដល់ 56 និងជាភាសាអង់គ្លេស 00369197 ដល់ 98។ លោកបានលើកពីប្រជាប្រិយភាពរបស់លោក ខៀវ សំផន ថាមានប្រជាជនកម្ពុជា និងបរទេសគាំទ្រច្រើន ហើយជឿថាចលនានេះត្រូវដឹកនាំដោយលោក ខៀវ សំផន។ ហើយបានបញ្ជាក់បន្ថែមថា លោក ខៀវ សំផន សូមដកស្រង់៖ “បានចេញសេចក្តីប្រកាសមួយនិយាយអំពីព័ត៌មានលម្អិត និងរីកដំណើរការទៅមុខនៃសង្គ្រាម

ហើយគាត់និយាយអំពីការធ្វើសម្ព័ន្ធមិត្តជាមួយនឹងសម្តេច សីហនុ។ ហើយ ខៀវ សំផន បានទទួលសម្តេច សីហនុ នៅតំបន់រំដោះនេះ ប៉ុន្តែនេះគ្រាន់តែជាផ្សែងបានតែមួយភ្លែតតែប៉ុណ្ណោះ អំណាចទាំងអស់សុទ្ធតែនៅក្នុងកណ្តាប់ដៃនៃអ្នកផ្សេងនោះទេ។ ហើយអ្នកផ្សេងនោះមិនដឹងទេ គឺថាតាមពិតទៅអ្នកដឹកនាំខ្ពស់បំផុតនៃបក្សកុម្មុយនីស្តទេ ជាអ្នកកាន់អំណាច”។

[០៩:២៥:១៨]

ជាក់ស្តែងលោក ខៀវ សំផន មិនធ្លាប់បានកាន់កាប់មុខងារយោធាទាំងមុន និងក្រោយឆ្នាំ១៩៧៥ នោះទេ។ ក្នុងនាមជាបញ្ញាជនសុទ្ធសាធ លោកគ្មានសមត្ថភាពខាងយុទ្ធសាស្ត្រយោធា ឬខាងបញ្ជាទ័ពឡើយ។ គ្រប់សាក្សី និងអ្នកជំនាញដែលដឹងពីឋានានុក្រមយោធាបានលើកឡើងពីលោក សុន សេន និង ប៉ុល ពត ថាជាអ្នកទទួលខុសត្រូវខាងកងទ័ព គឺមិនមែនលោក ខៀវ សំផន។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ លោក អ៊ុង រ៉ែន បានឆ្លើយអះអាងនៅចំពោះមុខអង្គជំនុំជម្រះអំពីរចនាសម្ព័ន្ធយោធាថា សូមដកស្រង់៖ “សុន សេន ក៏ជាថ្នាក់លើ ប៉ុល ពត ក៏ជាថ្នាក់លើ ហើយក្រៅពីនោះមក គឺដូចជាខ្ញុំបានបញ្ជាក់អ៊ីចឹងថា ពេលរាយការណ៍បញ្ហានយោបាយ ឬក៏ខាងយោធាអី គឺមានតែពីរនាក់ហ្នឹងដែលជាអ្នកដើរតួ”។ សូមចប់ការដកស្រង់។

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ លោក នួន ជា ក៏បានឆ្លើយបញ្ជាក់នៅចំពោះអង្គជំនុំជម្រះអំពីរចនាសម្ព័ន្ធយោធាដោយអះអាងថា សូមដកស្រង់៖ “បញ្ហានេះវាគ្មានពាក់ព័ន្ធជាមួយលោក ខៀវ សំផន ទេ ព្រោះ ខៀវ សំផន គាត់មិនមែនខាងយោធាឯណា។ ហើយខ្ញុំខាងប្រធានសភាឯណោះ។ ដូច្នេះមានតែ សុន សេន ទេដែលជាប្រធានសេនាធិការ”។ សូមចប់ការដកស្រង់។

[០៩:២៦:៤៥]

ដូចគ្នានេះដែរ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឌុច បានអះអាងនៅចំមុខអង្គជំនុំជម្រះថា សូមដកស្រង់៖ “តួនាទី ខៀវ សំផន ជាអគ្គមេបញ្ជាការ ខ្ញុំបានបញ្ជាក់ថា ជាតួនាទីឧបកិច្ច។ បានន័យថាមានតែឈ្មោះទេ។ តាមពិតគាត់អត់ចេះបញ្ជាទ័ពផង ហើយគ្មានទ័ពសម្រាប់បញ្ជាទេ។ កងទ័ពទាំងអស់ជារបស់ ប៉ុល ពត”។ សូមចប់ការដកស្រង់។

ទោះជាមុន ឬក្រោយឆ្នាំ១៩៧៥ ក្តីគ្មានយោធាណាម្នាក់ ទោះជាអ្នកទាំងនោះធ្លាប់បានដឹងឮពីមុខងារខ្យល់របស់លោក ខៀវ សំផន ក៏ដោយ ក៏គ្មានអ្នកណាអះអាងថាធ្លាប់បានទទួលបញ្ជាពីលោក ខៀវ សំផន នោះដែរ។

លោក ស្ទីវ ហេដឌ័រ ដែលទទួលបានព័ត៍មានពីភ្នាក់ងារស៊ើបការណ៍ដែលមានវត្តមាននៅកម្ពុជា បានអះអាងថា នៅមុនពេលវាយយកទីក្រុងភ្នំពេញ គឺឈ្មោះ សាឡុត ស ដែលជាអ្នកបញ្ជានៅក្នុងឋានានុក្រមយោធានៃចលនាខ្មែរក្រហម។ លោក ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ត្រូវបានគេចាត់ទុកថាជាអ្នកដឹកនាំស្រមោល។ លោក ស្ទីវ ហេដឌ័រ ក៏បានបញ្ជាក់ពីមុខងារសំបកក្រៅរបស់លោក ខៀវ សំផន ផងដែរ។ លោក ស្ទីវ ហេដឌ័រ បានឆ្លើយបញ្ជាក់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ នៅចំពោះមុខអង្គជំនុំជម្រះដោយយល់ស្របគ្នាជាមួយនឹងលោក ខៀវ -- ដែលយល់ស្របគ្នានេះដែរថា លោក ខៀវ សំផន មិនមានអំណាចពិតប្រាកដនោះទេ។ លោក ស្ទីវ ហេដឌ័រ បានយល់ស្របថា សូមដកស្រង់៖ "មុនឆ្នាំ១៩៧៥ លោក ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រីកម្ពុជា ជាមេបញ្ជាការយោធាដែលជាតំណែងមានតែឈ្មោះ ព្រោះថា ប៉ុល ពត ជាមេបញ្ជាការពិតប្រាកដ។ នៅពេលដែលគាត់ធ្វើដំណើរទៅបរទេសគឺ អៀង សារី ជាអ្នកមានអំណាច។ ចំណែកឯ ខៀវ សំផន ជាប្រធានគណៈប្រតិភូ ប៉ុន្តែនៅពេលដែលមានគណៈប្រតិភូដឹកនាំដោយ អៀង សារី នោះ គឺ អៀង សារី នេះហើយជាអ្នកមានអំណាចពិតប្រាកដ"។ សូមចប់ការដកស្រង់។

[០៩:២៩:០៨]

នៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនឌ័ល័រ ដែលមានចំណងជើងថា "បងទី១" ត្រង់ទំព័រ៨៧ បានសរសេរថា សូមដកស្រង់៖ "សេចក្តីសម្រេចក្នុងការបង្កើតរណសិរ្សរួបរួមជាតិជាមួយសម្តេច សីហនុ ជាប្រមុខរដ្ឋមានឥទ្ធិពលពីរយ៉ាងទៅលើអាជីពរបស់ សាឡុត ស។ ទី១ បន្ទាប់ពីរយៈពេលប្រាំពីឆ្នាំនៃការរត់លាក់ខ្លួនក្នុងព្រៃក្នុងអាយុ៤៥ឆ្នាំ លោកក្លាយទៅជាមេបញ្ជាការយោធារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយមួយទៀតចលនានេះបានទទួលការគាំទ្រយ៉ាងច្រើនពីកងទ័ពវៀតណាម។ ចំណុចទាំងពីរនេះអាចធ្វើឱ្យ ប៉ុល ពត ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលកងទ័ពរបស់ខ្លួនអាចត្រូវបានហ្វឹកហ្វឺនពីសំណាក់កងទ័ពវៀតណាមដ៏រឹងមាំ"។ សូមចប់ការដកស្រង់។

ចាប់ពីរដ្ឋប្រហាររបស់លោក លន់ នល់ មកលោក ខៀវ សំផន បានដើរតាមអ្នកដឹកនាំខ្មែរក្រហមតិចឬច្រើន ទៅតាមមូលដ្ឋានផ្សេងៗ។ ក៏ប៉ុន្តែទោះជានៅខេត្តរតនគិរីក្តី ឬនៅក្នុងមូលដ្ឋានបន្តបន្ទាប់មកទៀតក្តី សក្ខីកម្មរបស់អ្នកដែលធ្លាប់នៅជាមួយអ្នកដឹកនាំបានរៀបរាប់អំពីលោក ខៀវ សំផន នូវរូបភាពជាបុរសសាមញ្ញម្នាក់ ដែលតែងតែសរសេរ និងអានតែឯងដាច់ពីគេ។

[០៩:៣០:៣៧]

ដើម្បីរំឭកចំណុចនេះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ លោក ឈូក រីន បានឆ្លើយអះអាងនៅចំពោះអង្គជំនុំជម្រះថា ប្រធានផ្ទាល់របស់លោកគឺ តាម៉ុក បានប្រជុំប្រាប់ដល់កូនចៅរបស់គាត់ថា លោក ខៀវ សំផន មិនមានអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះឡើយ។ គេនិយាយពីគាត់ថា សូមដកស្រង់៖ "ជាបញ្ញាជនដែលពីមុនមិនបានចូលជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាទេ"។ សូមចប់ការដកស្រង់។ និងថា សូមបើកការដកស្រង់៖ "គាត់ជាអ្នកដឹកនាំគ្មានអំណាច មានតែឈ្មោះ"។ សូមចប់ការដកស្រង់។ លោក ឈូក រីន បានផ្តល់សក្ខីកម្មបន្ថែមថា លោក ខៀវ សំផន ជាបញ្ញាជនដែលគ្មានចូលក្នុងបក្សអីទេ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ លោកក៏បានឆ្លើយ -- លោក ឈូក រីន ក៏បានឆ្លើយអះអាងបន្ថែមពីតួនាទីរបស់ ខៀវ សំផន ក្នុងចន្លោះឆ្នាំ១៩៧៣ ដល់១៩៧៥ ដែលគាត់បានស្តាប់ឮតាម៉ុក និយាយផងដែរថា សូមដកស្រង់៖ "ខៀវ សំផន ហ្នឹងជាបញ្ញាជន គាត់មិនចូលរួមជាកម្លាំងស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងទេ"។ សូមចប់ការដកស្រង់។

[០៩:៣២:០២]

យើងសូមលើកឡើងខ្លីៗពីវគ្គរៀនសូត្រដែលលោក ខៀវ សំផន អាចធ្លាប់បានបង្រៀននៅក្នុងព្រៃ តាមពិតសាក្សីតែម្នាក់គត់ ដែលបានលើកអំពីចំណុចនេះគឺ ភី ភួន ដែលរៀបរាប់ពីបទបង្ហាញរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងភាពចាំបាច់នៃការប្រមូលកម្លាំង តាមតែអាចធ្វើទៅបាន និងពាក់ព័ន្ធនឹងសារៈសំខាន់នៃរណសិរ្ស។ លោក ភី ភួន បានរៀបរាប់នៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ អំពីខ្លឹមសារនៃសុន្ទរកថារបស់លោក ខៀវ សំផន ដែលផ្សាយក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា និងការបង្រៀនរបស់លោក ខៀវ សំផន អំពីការចងក្រងកម្លាំងរណសិរ្ស។ លោកបានរៀបរាប់ថា កម្លាំងរណសិរ្សហ្នឹង-- (សូមទោស) សូមដកស្រង់៖ "កម្លាំងរណសិរ្សហ្នឹងតាមខ្ញុំចាំ ទី១ ត្រូវប្រមូលកម្លាំងបញ្ញវន្តទាំងអស់ ហើយបន្ទាប់មកត្រូវប្រមូលកម្លាំងដែលជាកម្លាំងក្នុងប្រទេស គឺកម្លាំងជាតិទាំងមូល"។ សូមចប់ការដកស្រង់។

[០៩:៣៣:០៦]

ដូចនេះទោះបីលោក ខៀវ សំផន បានបង្រៀនពិត ឬមិនបង្រៀនក្តី ក៏ខ្លឹមសារនៃការបង្រៀនបានត្រឹមតែដើម្បីរួបរួមកម្លាំងប្រជាពលរដ្ឋទូទាំងប្រទេស ដើម្បីពង្រឹងរណសិរ្សរួបរួមជាតិកម្ពុជាតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រម ដូចលោក លោកស្រីចៅក្រមបានជ្រាបរួចហើយថា គ្មានឯកសារណា

មួយ ឬសក្ខីកម្មណាពាក់ព័ន្ធ -- ដែលពាក់ព័ន្ធ ដែលអាចឲ្យគេអះអាងថា នៅក្នុងក្របខ័ណ្ឌនៃមុខងារទាំងនេះ លោក ខៀវ សំផន បានចូលរួមសម្រេចចិត្តក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ចូលរួមប្រព្រឹត្តបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជនដំណាក់កាលទី២ ដែលជាបទល្មើសស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង ០០២/០១ នោះឡើយ។

លោក លោកស្រីចៅក្រម ដូចខ្ញុំបានជម្រាបជូនរួចហើយ ខ្ញុំក្រោកឈរនៅពេលនេះដើម្បីការពារសុភាពបុរសម្នាក់ដែលត្រូវគេលាបពណ៌ឲ្យក្លាយជាបិសាច។ ឥឡូវនេះ នៅពេលដែលពណ៌ត្រូវរលុបបាត់អស់ យើងនឹងឃើញយ៉ាងច្បាស់ថា សុភាពបុរសនោះ គឺលោក ខៀវ សំផន ដ៏ស្អាតស្អំដែលអង្គជំនុំជម្រះត្រូវតែឲ្យរួចខ្លួនពីបទចោទ និងផ្តល់សេរីភាពជូនលោកវិញ។ សូមអរគុណ។

[០៩:៣៤:៥៨]

**លោក អាកខ្វួរ វែកគែន៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ និងជម្រាបសួរសាធារណជន។

ខ្ញុំសូមនិយាយបន្តពីលោកមេធាវី គង់ សំអុន។ ខ្ញុំនឹងនិយាយអំពីគំនិតមួយចំនួនដែលយើងបានស្តាប់ឮពីសហព្រះរាជអាជ្ញានៅក្នុងសំណើរបស់ពួកគាត់ ហើយនិងនិយាយអ្វីៗដែលខាង នួន ជា បានលើកឡើងរួចមកហើយពាក់ព័ន្ធទៅនឹងបញ្ហានៃទីតាំងទួលពោធិ៍ជ្រៃ និងគោលនយោបាយដែលជាបញ្ហាសំខាន់។

ចំណុចទី១ ដែលខ្ញុំចង់និយាយនោះ គឺខ្ញុំចង់និយាយអំពីទ្រឹស្តីនៃសំណាញ់ដែក។ សហព្រះរាជអាជ្ញាបានរៀបរាប់ថា៖ "ថ្ងៃទី១៧ មេសា ១៩៧៥ ជាកាលបរិច្ឆេទដែលចាប់ពីពេលនោះ សំណាញ់ដែកបានធ្លាក់មកលើប្រទេសកម្ពុជា"។ ពួកគាត់មានរូបភាពបែបនេះនៅក្នុងគំនិតរបស់ពួកគាត់។ បើតាមគំនិតរបស់ពួកគាត់នោះ គឺថាហាក់ដូចជាថាការរស់នៅក្នុងព្រៃអស់រយៈពេលជាង១០ឆ្នាំ លាក់ខ្លួននៅក្នុងព្រៃ រស់នៅនៅតាមជំរំបណ្តោះអាសន្នដែលបានសង់ឫស្សី ឬក៏ពីស្លឹកចេកនោះ ប៉ុល ពត នោះគាត់ចេញពីខ្ទម ឬក៏ផ្ទះរបស់គាត់ដែលមានមិត្តភក្តិចាស់ៗ ហើយនិងមានទាហានឈ្លបជើងទទេ។ ហើយគិតថាប្រហែលជាត្រឹមតែប៉ុន្មានម៉ោងហ្នឹង ខ្មែរក្រហមអាចនឹងបង្កើតកម្ពុជាឲ្យក្លាយទៅជាប្រទេសមួយដែលថាប្រមូលផ្តុំយ៉ាងអស្ចារ្យ រៀបចំរចនាសម្ព័ន្ធបានយ៉ាងអស្ចារ្យ ដោយមានកងទ័ពឯកភាពស្តាប់បង្គាប់ មានមន្ត្រីរដ្ឋការដែលអាចធ្វើការបានភ្លាមៗ ពួកគាត់មាននយោបាយក្នុងការទំនាក់ទំនងគ្នាយ៉ាង

មានការអភិវឌ្ឍយ៉ាងអស្ចារ្យ មានប្រសិទ្ធភាព និងអាចដំណើរការបានយ៉ាងល្អ។ យើងគិតថា គំនិតនេះ វាដូចជាគំនិតដែលថា វាសាមញ្ញហួសហេតុពេក ហើយគ្មានអ្នក -- បើមនុស្សយើងមានសុភវិនិច្ឆ័យនោះ យើងមិនអាចឯកភាពតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាបានទេ។

[០៩:៣៧:១៣]

ដូចមានសុភាសិតមួយបានលើកឡើងថា៖ "ការកសាងប្រទេសពីចំណុចសូន្យនោះ មិនអាចធ្វើបានតែមួយថ្ងៃទេ"។ ជាក់ស្តែងណាស់ថាតំបន់រំដោះនៅកម្ពុជានោះថា ដំណើរការតាំងពីមុនមកហើយដោយគ្មាន ប៉ុល ពត ហើយតំបន់ទាំងអស់នោះត្រូវបានដឹកនាំដោយមនុស្សដែលមានតាំងពីយូរមកហើយហើយដែលមានមេដែលមានលក្ខណៈតឹងរ៉ឹង។

ទ្រឹស្តីសំណាញ់ដែកដែលធ្លាក់មកលើកម្ពុជាតាំងពីថ្ងៃទី១៧ មេសា ៧៥ នោះគឺមិនត្រឹមត្រូវទេ យោងតាមទស្សនៈការទូតនោះ។ យើងដឹងច្បាស់ហើយថា នៅពេលដែលចូលមកដល់ភ្នំពេញខ្មែរក្រហមបានបញ្ជូនជនបរទេសមួយចំនួនតូច ដែលបានបន្តស្នាក់នៅកម្ពុជាបន្ទាប់ពីមានការជូនដំណឹងឱ្យចេញជាច្រើនដងហើយ។ តើយើងមានបានស្តាប់ឮ ថាគេបញ្ជូនអ្នកទាំងអស់ហ្នឹងទៅក្នុងស្រែទេ? ហើយតើខ្មែរក្រហមហ្នឹងពិតជាបានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងពិភពលោកទាំងមូលទេ? គឺអត់ទេ។

ខ្មែរក្រហមនៅតែរក្សាទំនាក់ទំនងជាមួយប្រទេសកុម្មុយនីស្តជាមិត្ត ប្រទេសមិនចូលបក្សសម្ព័ន្ធ។ ហើយសំណុំរឿងរបស់យើងមានភស្តុតាង មានស្លាកស្នាមជាច្រើន ឧទាហរណ៍ដូចជាទស្សនកិច្ចនៅកម្ពុជារបស់គណៈប្រតិភូបរទេសមួយចំនួន។ ខ្ញុំសូមលើកឧទាហរណ៍ខ្លះៗ គឺឆ្នាំ៧៥មានទស្សនកិច្ចនៅប្រទេសកម្ពុជារបស់គណៈប្រតិភូវៀតណាម កូរ៉េខាងជើង យូហ្គោស្លាវី ឡាវ អាល់បានី និងប្រទេសជាមិត្តជាច្រើនទៀតសម្រាប់ការអបអរបុណ្យដំណាច់ឆ្នាំ។ ហើយនៅឆ្នាំ១៩៧៦ មាន៖ ចិន, ប៉ាឡេស្ទីន, សំប៊ី, ស៊ុយអែត, ទុយនីស៊ី, អាហ្វហ្គានីស្ថាន, សេណេហ្គាល់, ម៉ូរីតានី, យូហ្គោស្លាវី, វៀតណាម, កូរ៉េ, ម៉ាលី, តង់សានី ដែលបានមកទស្សនកិច្ចនៅកម្ពុជា។ ឆ្នាំ១៩៧៧ មានចិន, គុយបា, យូហ្គោស្លាវី, កូរ៉េ, វៀតណាម, ឡាវ, ភូមា។ ឆ្នាំ១៩៧៨ មានហ្វាំងឡង់, ដាណឺម៉ាក, ស៊ុយអែត, ចិន, យូហ្គោស្លាវី, រ៉ូម៉ានី, អាល់ហ្សេរី ជាដើម។

[០៩:៣៩:៣៥]

ហើយម្យ៉ាងវិញទៀតរហូតមកដល់ខែមីនា ឆ្នាំ៧៦ សម្តេច សីហនុ នៅតែបន្តគណៈប្រតិភូការទូតក្នុងឋានៈព្រះអង្គជាប្រធានគណៈប្រធានរដ្ឋ។ កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៨ ខែ

មីនា ឆ្នាំ១៩៧៦ បានលើកឡើងពីចំណុចនេះ។ យើងក៏បានឃើញផងដែរ កាលពីខែតុលា ឆ្នាំ១៩៧៥ សម្តេច សីហនុ គាត់នៅញូយ៉ក ហើយខ្ញុំបានបញ្ចាំងវីដេអូឲ្យយើងមើលទាំងអស់គ្នាហើយ។ កំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ទោះបីជាថាមានយថាភាព ឬក៏មិនមានក៏ដោយគឺថាមានបង្ហាញអំពីព័ត៌មានជាច្រើនអំពីសកម្មភាពការទូតរបស់ព្រះអង្គ វាមិនមែនជាសកម្មភាពរបស់ប្រទេសអភិវឌ្ឍធំៗទេ ក៏ប៉ុន្តែមិនមែនថាមិនមាននោះទេ។ ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះ ពីព្រោះថាដោយហេតុថាមានមុខងារនៅក្នុងហ្គ្រុង ហើយនិងហ្លុង ហើយនិងគណៈប្រធានរដ្ឋនោះលោក ខៀវ សំផន បានចូលរួមក្នុងការអភិវឌ្ឍការទូតកម្ពុជា។ នេះគឺជាការពិតសម្រាប់គាត់។ ហើយនៅពេលដែលយើងពិនិត្យមើលទៅលើទស្សនៈរបស់សហព្រះរាជអាជ្ញានោះ យើងមានអារម្មណ៍ថាពួកសហព្រះរាជអាជ្ញាយល់ថាចាប់ពីថ្ងៃ១៧ មេសា ១៩៧៥នោះ គឺថាខ្មែរក្រហមបានយក -- ចូលប្លុកកុម្មុយនីស្តនៃសង្គ្រាមត្រជាក់ គឺខាងកុម្មុយនីស្ត។ ហើយខាងសហព្រះរាជអាជ្ញាគាត់មិនទទួលស្គាល់ត្រង់ចំណុចនេះទេ។

សហព្រះរាជអាជ្ញាយល់ថា នៅពេលដែលប្រទេសណាមួយបដិសេធមិនព្រមសម្របសម្រួល បដិសេធមិនព្រមទទួលជំនួយអំពីសហរដ្ឋអាមេរិកនោះ គឺជាភស្តុតាងបង្ហាញថាប្រទេសនោះហើយកំពុងតែជាប្រទេសបិសាច។ យើងឃើញហើយថា ចិន សភាពសូវៀតហ្នឹង តើគាត់បានទទួលជំនួយទេនៅពេលដែលគាត់កំពុងតែកសាងប្រទេសតាមផ្លូវនយោបាយនោះ ខ្ញុំមានការសង្ស័យ។ តើពិតទេថារបបកម្ពុជាប្រជាធិបតេយ្យបានបដិសេធរាល់ជំនួយទាំងអស់ ដើម្បីឃុំខ្លួននៅក្នុងរបបផ្តាច់ការ ឧក្រិដ្ឋនោះ?

[០៩:៤១:៤៩]

ដើម្បីឲ្យយល់ច្បាស់អំពីចំណុចនេះ ខ្ញុំសូមលើកឡើងនូវកំណត់ហេតុប្រាំបួនរបស់គណៈអចិន្ត្រៃយ៍ដែលយើងមាន។ ដើម្បីឲ្យយើងយល់ទាំងអស់គ្នាថា ប្រាំគឺលើសពីពាក់កណ្តាលទៅទៀតនិយាយអំពីបញ្ហាជំនួយដែលទទួលពីបរទេស។ ឧទាហរណ៍ ឯកសារ E3/781 គឺនិយាយអំពីការពិនិត្យ ការស្តាប់ និងការអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក ដែលមាននិយាយអំពីការទទួលជំនួយពីបរទេស។ ឧទាហរណ៍ដូចជាប្រទេសចិន -- ប្រទេសកូរ៉េនឹងមកផ្តល់ការសាងសង់រោងចក្រផលិតម៉ូទ័រ ហើយមានការបង្ហាញអំពីការដំណើរការរោងចក្រស៊ីម៉ង់ត៍ រោងចក្រចម្រាញ់ប្រេង រោងចក្រកៅស៊ូ ដោយមានជំនួយពីចិន ហើយចិនក៏នឹងជួយដល់ខាងផ្នែកប្រព័ន្ធផ្លូវដែកផងដែរ។

ឯកសារ E3/187 កំណត់ហេតុចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥ គឺចិនគាត់នឹងផ្តល់ជំនួយខាងផ្នែក

ទូរគមនាគមន៍។ ឯកសារ E3/249 កំណត់ហេតុចុះថ្ងៃទី២២ កុម្ភៈ ១៩៧៦ គឺនិយាយអំពីជំនួយចិន។ ឯកសារ E3/230 ចុះថ្ងៃទី២២ កុម្ភៈ ១៩៧៦ មាននិយាយអំពីជំនួយ ៣លានដុល្លាររបស់យូហ្គោស្លាវី ហើយមានការសម្រេចថា យកជំនួយនេះទៅទិញថ្នាំប្រឆាំងមេរោគ ហើយនិងសេរ៉ូម។ ហើយក៏មាននិយាយអំពីជំនួយរបស់ចិន ពាក់ព័ន្ធនឹងអង្ករ ហើយមានការសម្រេចថា បែងចែកអង្ករទាំងអស់នេះទៅតាមតំបន់ដែលត្រូវការ។ និងជាចុងក្រោយនោះគឺ ឧទាហរណ៍ចុងក្រោយគឺឯកសារ E3/238 ចុះថ្ងៃទី២៨ កុម្ភៈ ៧៦ ជំនួយ៥លានដុល្លារពីរដ្ឋាភិបាលស៊ុយអ៊ែត និងជំនួយ៤លានដុល្លារពីរដ្ឋាភិបាលយូហ្គោ-ស្លាវី។ ជំនួយទាំងពីរនេះ គឺសម្រាប់ទិញសម្ភារៈ និងថ្នាំពេទ្យសម្រាប់ចែកជូនប្រជាជន។

[០៩:៤៣:៥៨]

តាមរយៈឧទាហរណ៍ទាំងអស់នេះ យើងឃើញអំពីការពិតដែលបានកើតឡើងនោះ គឺថាប្រទេសយើងទទួលជំនួយពីបរទេស វាមិនដូចជាអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះទេ។ អាស្រ័យហេតុនេះហើយបានជាយើងនិយាយសង្កត់ធ្ងន់ទៅលើលក្ខណៈសំខាន់នៃបរិបទសង្គ្រាមត្រជាក់ដែលបានកើតឡើងរហូតទៅដល់ឆ្នាំ១៩៨៩ គឺមានន័យថាជាង ១០ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។ ហើយប្រសិនបើយើងបំភ្លេចកាលៈទេសៈនៃជម្លោះនយោបាយនេះ យើងមិនអាចយល់អំពីសំណុំរឿងរបស់យើងទេ។ ហេតុដូច្នេះហើយបានជាយើងយល់ថា ដូចជាមិនហួសហេតុទេនៅពេលដែលយើងលើកឡើងថា ទ្រឹស្តីនៃឯកសារដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងដោយខាងសហព្រះរាជអាជ្ញាគឺស្នើសុំឲ្យអង្គជំនុំជម្រះកាត់ទោសជនជាប់ចោទក្រោមលេសដែលខ្លួនថា ដែលថាខ្មែរក្រហមនោះចង់បង្កើតរបបកុម្មុយនីស្តនៅកម្ពុជា។
យើងឃើញច្បាស់មកហើយនៅក្នុងដីកាដំណោះស្រាយដំបូងមុនពេលបំបែកនីតិវិធី ហើយក៏វារឹតតែឃើញច្បាស់ទៅទៀតនៅពេលដែលយើងបានពិនិត្យមើលទ្រឹស្តីរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងជំរំនៃទាសករ។

សហចៅក្រមស៊ើបអង្កេតយល់ឃើញថា គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនោះមិនមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ។ យើងឃើញថា ការដែលសហព្រះរាជអាជ្ញាលើកឡើងថា កម្ពុជាជារដ្ឋទាសភាពនោះវាបង្ហាញឲ្យឃើញថា ការលើកឡើងរបស់សហព្រះរាជអាជ្ញានោះគឺមានលក្ខណៈជានយោបាយជាជាងជាលក្ខណៈតុលាការ។

[០៩:៤៦:០៥]

 

ពាក់ព័ន្ធទៅនឹងបញ្ហាសំណាញ់ដែកនេះដែលថា ខៀវ សំផន ទំនងជាចូលរួមចំណែកក្នុងការធ្វើឲ្យវាធ្លាក់មកលើកម្ពុជា។ សហព្រះរាជអាជ្ញាបានលើកឡើងថា៖ "តាមរយៈការចូលរួមក្នុងការតាក់តែងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ការចូលរួមក្នុងការរៀបចំការបោះឆ្នោតនៅខែមីនា ឆ្នាំ១៩៧៦ នៃសភាជាតិ ខៀវ សំផន ទំនងជាបានចូលរួមនៅក្នុងអង្គហេតុដែលបានប្ដឹងមកអង្គជំនុំជម្រះ"។

នេះគឺជាទឡ្ហីករណ៍ទន់ខ្សោយបំផុត។ តើអស់លោក លោកស្រីធ្លាប់ឃើញប្រទេសកុម្មុយនីស្ដណាដែលមានរដ្ឋធម្មនុញ្ញ ដែលមានសភាជាតិ បើធៀបទៅនឹងប្រទេសប្រជាធិបតេយ្យនោះ? អត់មានទេ។ ហើយនៅឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នោះគឺថាមិនមានការបំភ័ន្តភ្នែកទេ។ តើនេះវាបង្ហាញពីអ្វី? ពាក់ព័ន្ធទៅនឹងការចូលរួមចំណែករបស់លោក ខៀវ សំផន នៅក្នុង ការជម្លៀសប្រជាជនដំណាក់កាលទី១, ទី២ និងទួលពោធិ៍ជ្រៃនោះ។ វាមិនមែនជារឿងធំដុំទេ ហាក់ដូចមើលទៅហាក់ដូចជាគ្មានតែម្ដងការចូលរួមរបស់លោក ខៀវ សំផន នោះ។

[០៩:៤៧:២៦]

ខ្ញុំក៏សូមលើកឡើងអំពីសារៈសំខាន់នៃកាលប្បវត្តិនៃសំណុំរឿងរបស់យើង។ ចំណុចនេះសំខាន់ណាស់ពីព្រោះថាអង្គហេតុជំនុំជម្រះនេះបានកើតឡើងនៅដើមរបបកម្ពុជាប្រជាធិបតេយ្យ។ ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងតែក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយពីថ្ងៃ១៧ មេសា ៧៥ ទួលពោធិ៍ជ្រៃបានប្រព្រឹត្តទៅតែមួយថ្ងៃនៅខែមេសា ឆ្នាំ១៩៧៥។ ចំណែកឯការជម្លៀសប្រជាជន ដំណាក់កាលទី២ គឺត្រូវបានសម្រេចនៅខែសីហា ឆ្នាំ៧៥ ត្រូវបានអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ៧៥។ ហើយយើងឯកភាពរហូតមកដល់ពេលនេះថា ការជម្លៀសនោះគឺថាប្រមូលផ្ដុំប្រជាជនទាំងអស់ ហើយបន្តរហូតទៅដល់ចុងឆ្នាំ៧៦។

ដូច្នេះបញ្ហាភាពវ័យក្មេងនៃរបបដែលខ្ញុំបាននិយាយកាលពីចាប់សេចក្ដីផ្ដើមនោះ គឺថាមានសារៈសំខាន់ណាស់។ ឧទាហរណ៍ តំបន់ ភូមិភាគពាយ័ព្យដែលគេបញ្ជូនប្រជាជន នៅក្នុងដំណាក់កាលទី២នោះគឺជាតំបន់ដែលត្រូវបានគ្រប់គ្រងរហូតមកដល់ថ្ងៃទី១៧ មេសា ៧៥ ដោយកម្លាំងរបស់សាធារណរដ្ឋខ្មែរ។ ហើយវាអាចបង្កឲ្យមានផលវិបាកមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបចំប្រទេស។

[០៩:៤៨:៤៨]

បញ្ហាក្នុងការកំណត់កាលប្បវត្តិមានសារៈសំខាន់ណាស់ ដើម្បីឲ្យយើងយល់អំពីហេតុការណ៍ដែលបានកើតឡើង។ ច្បាស់ណាស់ថា ស្ថានភាពផ្ទៃក្នុង និងការរៀបចំប្រទេសកម្ពុជាមិនមានដូចគ្នាទេ

នៅក្នុងចន្លោះខែមេសា ខែមិថុនា ឆ្នាំ៧៥ ឬរហូតដល់ចុងឆ្នាំ៧៦ នោះ។ ដូចគ្នាផងដែរស្ថានភាពនោះគឺវារឹតតែមិនដូចគ្នាទៅទៀត នៅឆ្នាំ៧៧ និងឆ្នាំ៧៨។ ជាពិសេសបន្ទាប់ពីមានការចាប់ផ្ដើម ធ្វើសង្គ្រាមជាមួយវៀតណាម។

ក៏ប៉ុន្តែ បញ្ហាដែលយើងជួបប្រទះនៅពេលដែលយើងវិភាគការលើកឡើងរបស់សហព្រះរាជអាជ្ញានោះ គឺថាគាត់ធ្វើដូចជាសូមកុំឲ្យមានការបំបែកសំណុំរឿងអ៊ីចឹង ហើយប្រៀបដូចជាការរៀបរាប់កម្ពុជាប្រជាធិបតេយ្យនៅចុងរបបនោះ គឺថាអាចអនុវត្តរហូតទៅដល់ខែមេសា ឆ្នាំ៧៥ ទៅទៀត។ គឺមិនត្រឹមត្រូវទេការធ្វើរបៀបនេះ។ ហើយជំហរនេះគឺថាវាប៉ះទង្គិចទៅនឹងភាពសមហេតុផលផ្នែកមនុស្សជាតិ និងផ្នែកប្រវត្តិសាស្ត្រ។ ហើយខ្ញុំដឹងថាអង្គជំនុំជម្រះនឹងមិនផ្ដល់សុពលភាព លើចំណុចហ្នឹងទេ ហើយនិងចៀសវាងមិនទទួលយកកាលបរិច្ឆេទដែលរៀបរាប់ដោយសហព្រះរាជអាជ្ញានោះទេ។

[០៩:៥០:០២]

ច្បាស់ណាស់ថា បញ្ហាកាលបរិច្ឆេទនេះគឺជាបញ្ហាសំខាន់ដើម្បីឲ្យយើងវាយតម្លៃទៅលើចេតនា និងការចូលរួមចំណែករបស់លោក ខៀវ សំផន។ ធាតុផ្សំទាំងអស់នេះត្រូវវាយតម្លៃនៅពេលកើតមានអង្គហេតុដោយផ្អែកទៅលើទស្សីករណ៍ ដែលផ្អែកទៅលើអង្គហេតុដែលបានកើតឡើងពីមុនៗនោះទេ។ ឧទាហរណ៍មួយ កំណត់ហេតុទី១របស់គណៈអចិន្ត្រៃយ៍ដែលតុលាការយើងមាន ទោះបីជាថាមានយថាភាព ឬក៏មិនមានយថាភាពក៏ដោយ គឺថាជាកំណត់ហេតុនៃទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នៅក្នុងភូមិភាគពាយព្យនៅថ្ងៃទី២០ ដល់ថ្ងៃទី២៤ សីហា ឆ្នាំ៧៥។

ឯកសារនេះមាននូវការកត់សម្គាល់ឃើញអំពីភាពចាំបាច់ក្នុងបង្កើនការងារនៅក្នុងតំបន់ ដែលមានជីវជាតិគឺភូមិភាគពាយ័ព្យ។ គឺឯកសារនេះហើយដែលបញ្ជាក់អំពីការចាប់ផ្ដើមនៃការជម្លៀសដោយ -- នៃការជម្លៀសប្រជាជនដំណាក់កាលទី២។ ក៏ប៉ុន្តែនៅថ្ងៃទស្សនកិច្ចខែសីហា ឆ្នាំ៧៥នេះ ខៀវ សំផន មិនត្រឹមតែកំពុងតែធ្វើទស្សនកិច្ចការទូតនៅបរទេសទេ គឺបួនខែបានកន្លងហួសមកហើយ តាំងពីទួលពោធិ៍ជ្រៃ។ ហើយការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញនោះក៏បានបញ្ចប់តាំងពីយូរមកហើយ។

[០៩:៥១:២១]

យោងតាមកាលប្បវត្តិនោះនៅខែសីហា ឆ្នាំ៧៥ អង្គហេតុទាំងពីរគឺបានសម្រេចរួចទៅហើយ ហើយក៏បានអនុវត្តរួចមកហើយ។ ចំណែកអង្គហេតុទី៣ ទួលពោធិ៍ជ្រៃគឺមានការសម្រេចនៅក្នុងឱកាសទស្សនកិច្ចដែលយើងដឹងថាច្បាស់ថា ខៀវ សំផន មិនបានចូលរួមទេ ហើយយើងមិនអាចប្រកាសបាន

ទេ យើងបញ្ជាក់ពីចំណុចនេះច្បាស់ហើយ។ យើងស្ទើរតែអាចបញ្ឈប់ការសិក្សារបស់យើងអំពីតួនាទីរបស់លោក ខៀវ សំផន នៅត្រឹមខណៈដែលលោក ខៀវ -- លោក គង់ សំអុន បានលើកឡើងរួចមកហើយ។

នៅខែសីហា ឆ្នាំ៧៥ ប្រធានបទនៃគណៈអចិន្ត្រៃយ៍ គឺនិយាយអំពីការចរចារដ្ឋធម្មនុញ្ញ និងអំពីការរៀបចំការបោះឆ្នោត និយាយអំពីការទទួលបានឋានៈជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ដែលវាកើតឡើងដំណាលគ្នានឹងឋានៈដែលទទួលបានជាប្រធានគណៈប្រធានរដ្ឋ បញ្ហានិយាយអំពីការទទួលមុខងាររបស់ ខឿន នៅមន្ទីរ៨៧០។ ចំណុចទាំងអស់នេះ គឺជាចំណុចបន្ទាប់បន្សំ។ អាស្រ័យហេតុនេះហើយបានជាយើងថ្កោលទោសនូវយុទ្ធសាស្ត្ររបស់សហព្រះរាជអាជ្ញាដែលបានជាន់ពន្លិចយើងនៅក្នុងគំនរឯកសារដ៏ធំសម្បើម ដែលមានកំណត់សម្គាល់ជើងទំព័ររាប់ពាន់ គឺរហូតទៅដល់២៩០០ឯណោះហើយមានឯកសាររហូតទៅដល់១៥.០០០ ដែលយើងត្រូវពិគ្រោះ ហើយក្នុងឯកសារទាំងអស់នោះ មិនសូវមានភាពស៊ីសង្វាក់គ្នាទៅទៀត។

[០៩:៥៣:០៣]

ក្រៅពីការពង្រីកវិសាលភាពមិនឈប់ឈរនោះ សហព្រះរាជអាជ្ញាគាត់មានសមត្ថភាព គាត់មានទេពកោសល្យក្នុងក្រឡាប់ស្ថានការណ៍។ ឧទាហរណ៍នៃគណៈអចិន្ត្រៃយ៍ គឺមានលក្ខណៈច្បាស់លាស់ណាស់។ គណៈអចិន្ត្រៃយ៍ប្រជុំម្តង ឬក៏ពីរដងក្នុងមួយសប្តាហ៍ក្នុងអំឡុងរបបនោះ គឺថាសរុបទៅប្រហែលជា៥០ ទៅ១០០ក្នុងមួយឆ្នាំ។ ដូច្នេះបើយើងធ្វើការគណនាសាមញ្ញទៅយើងឃើញថាប្រហែលជាមាន១៩០ ទៅ៣៨០ ក្នុងចន្លោះពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ នៃរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ហើយយើងដឹងច្បាស់ហើយថា ខៀវ សំផន គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ ហើយគណៈអចិន្ត្រៃយ៍នេះ គឺជាស្ថាប័នអំណាចនៅជុំវិញ ប៉ុល ពត។

ក្រោមលេសដែលថា នៅពេលអង្កេតបឋមនៅក្នុងពេលស៊ើបសួរ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបានរកឃើញត្រឹមតែកំណត់ហេតុជាង២០របស់គណៈអចិន្ត្រៃយ៍។ ហើយក្នុងចំណោមកំណត់ហេតុទាំង២០នោះ យើងមិនដឹងថាតើលោក ខៀវ សំផន មានវត្តមានយ៉ាងម៉េចទេនៅក្នុងកំណត់ហេតុទាំងអស់នោះ ហើយសហព្រះរាជអាជ្ញាបានអះអាងថា -- (សូមទោស) សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ឯកសារបានបង្ហាញថា ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំយ៉ាងច្រើនរបស់គណៈអចិន្ត្រៃយ៍។ យើងមើលឃើញហើយថាដូចសហព្រះរាជអាជ្ញា គាត់បានបង្ហាញថាលោក

ខៀវ សំផន នោះបានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នោះប្រហែលជា៨៦ភាគរយ។

លោក លោកស្រីចៅក្រម ភាពសមហេតុផលនោះគឺថាលោក ខៀវ សំផន គាត់មានវត្តមានតែបួនភាគរយនៃចំនួនប្រជុំរបស់គណៈអចិន្ត្រៃយ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ នេះជាអ្វីដែលយើងអាចនិយាយបាន។ ប្រសិនបើយើងចង់និយាយដោយស្មោះត្រង់ ដោយទៀងត្រង់នោះ។ នេះគឺជាការពិត វាមានបង្ហាញនៅក្នុងសំណុំរឿងរបស់យើង។

[០៩:៥៥:១៥]

លើសពីហ្នឹងទៀត ដូចដែលយើងបាននិយាយនៅក្នុងកថាខណ្ឌ២៧២-៧៣ នៃសារណារបស់យើង គឺថានៅពេលដែលលោក ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ គឺតែងតែមានការនិយាយអំពីបញ្ហាពាក់ព័ន្ធទៅនឹងតួនាទីមួយ ដែលគាត់បានកាន់កាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺក្នុងឋានៈគាត់ជាតំណាងឲ្យរណសិរ្ស និងរាជរដ្ឋាភិបាល ក្នុងឋានៈគាត់ជាអ្នកទទួលខុសត្រូវខាងបញ្ជី និងតម្លៃនៅក្នុងផ្នែកពាណិជ្ជកម្ម ក្នុងឋានៈរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ក្នុងឋានៈរបស់គាត់ជាប្រធានគណកម្មការពិនិត្យទំនិញដែលត្រូវទិញ ឬប្រធានគណៈកម្មាធិការពិនិត្យបញ្ហាធនាគារ។

យើងឃើញថា លោក ខៀវ សំផន គឺដូចដែលយើងធ្លាប់បានលើករួចមកហើយថា គាត់មានការជឿជាក់ពី ប៉ុល ពត។ ដូច្នេះហើយគាត់ទំនងជាបានក្លាយទៅជាសមាជិកអចិន្ត្រៃយ៍ ក៏ប៉ុន្តែមិនមែនអ៊ីចឹងទេ។ ចាប់ពីការកត់សម្គាល់ឃើញនោះ យើងមិនត្រូវពិនិត្យមើលទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញានៅក្នុងរបៀបដូចគ្នានោះទេ។ យើងត្រូវចងចាំថា ប្រសិនបើសម្ដីរបស់យើងអាចហួសហេតុពេកនោះ គឺថាគឺយើងព្យាយាមក្នុងការឆ្លើយតបទៅនឹងរបស់សហព្រះរាជអាជ្ញា គឺថាវាមានភស្តុតាងតិចតួចផ្ទាល់ពិតមែន។ អស់រយៈពេលប្រាំឆ្នាំមកហើយ ដែលលោក ខៀវ សំផន រង់ចាំនៅក្នុងគុក ឲ្យគេកាត់ទោសគាត់ក្នុងរយៈពេលសមស្រប ហើយឲ្យមានការគោរពសិទ្ធិគាត់ ហើយគាត់ឥឡូវនេះមានអាយុ៨២ឆ្នាំហើយ។

[០៩:៥៧:០៨]

ពាក់ព័ន្ធទៅនឹងចេតនា និងការចូលរួមចំណែករបស់លោក ខៀវ សំផន ហេតុការណ៍ដែលគេស្នើសុំឲ្យអង្គជំនុំជម្រះវិនិច្ឆ័យនោះ គឺថាមិនបានបង្ហាញដោយអង្គហេតុទេ។ វាមិនបានបង្ហាញពីឫសគល់នៃហេតុការណ៍ទេ គឺមានភាពស្រពេចស្រពិល ពាក់ព័ន្ធទៅនឹងការនិយាយស្មាន និយាយសើៗ ដោយលើកឡើងថា ដោយឃើញថា តួនាទីរបស់លោក ខៀវ សំផន ក្នុងរយៈពេល -- ទោះបីជាច្រើនឆ្នាំក្រោយ

អង្គហេតុក៏ដោយ គាត់មិនអាចមិនដឹងពីអ្វីដែលកើតឡើងពីមុន ហើយដោយសារតែគាត់នៅជិត ប៉ុល ពត ក្នុងអំឡុងរបបនោះ វាបង្ហាញឲ្យឃើញថា គាត់ឯកភាពទៅលើអ្វីដែលបានកើតឡើងទាំងអស់។ នេះគឺជាទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញាបានផ្តល់ជូនអង្គជំនុំជម្រះ។ ហើយយើងយល់ឃើញថា វានៅក្រោមវិមតិសង្ស័យ។ យើងមានការសង្ស័យទាំងអស់ ទាំងស្រុងតែម្តង ហើយមិនមានភស្តុតាងទៀតផង។ ហេតុនេះហើយបានជាយើងជំទាស់ទៅនឹងបេសកកម្មជាប្រវត្តិសាស្ត្រនៃអង្គជំនុំជម្រះនេះ គឺថាមួយៗ គឺថានាំគ្នាស្វែងរកអង្គហេតុក្រៅពីកម្មវត្ថុនៃការជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាគាត់ដឹងច្បាស់ពីភាពទន់ខ្សោយនៃទឡ្ហីករណ៍របស់ពួកគាត់។ ពេលខ្លះទៅគាត់ព្យាយាមអះអាងថា តាំងពីទសវត្សរ៍ឆ្នាំ៥០ លោក ខៀវ សំផន គឺជាអាយ៉ងរបស់បក្សកុម្មុយនីស្តកម្ពុជា គាត់ជាអ្នកកុម្មុយនីស្តដែលស្រេកឃ្លានអំណាចផ្តាច់ការ គាត់ស្រមៃឃើញថា ដាក់ប្រជាជនឲ្យក្លាយទៅជាទាសភាព។

[០៩:៥៩:០៥]

យើងអាចនិយាយអ្វីបានស្រេចតែចិត្ត ក៏ប៉ុន្តែការរៀបរាប់បែបនេះ គឺថាវាផ្ទុយគ្នាទាំងស្រុងទៅនឹងជំនឿ ការប្តេជ្ញាចិត្ត អាជីពនយោបាយ និងអត្តចរិតរបស់លោក ខៀវ សំផន។ ហើយវាមិនត្រឹមត្រូវ វាមិនស៊ីគ្នាទៅនឹងភស្តុតាងដែលយើងបានពិនិត្យមើលក្នុងអំឡុងពីរឆ្នាំនៃសវនាការយើងនេះ ហើយនិងអ្វីដែលលោកមេធាវី គង់ សំអុន ទើបតែបង្ហាញនោះ។ ហើយសហព្រះរាជអាជ្ញាបានពន្យល់យើងទាំងអស់គ្នាថា នៅពេលណា? ហ្នឹងដោយសារហេតុអ្វីដែល ខៀវ សំផន ក្លាយទៅមនុស្សអាក្រក់ដូចដែលគាត់បានរៀបរាប់ឲ្យយើងស្តាប់នោះ។ ដូច្នេះ តើមានហេតុការណ៍អ្វីខ្លះដែលបានប្រែក្លាយបុរសមួយនេះនោះ សហព្រះរាជអាជ្ញាមិនដែលនិយាយទេ។ គាត់គ្រាន់តែបង្ហាញជារបៀបផ្ទុកតែប៉ុណ្ណោះ។

ទឡ្ហីករណ៍នោះ គឺថាក៏វាមិនសមស្របទៅទៀតពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន ជាថ្នាក់ដឹកនាំនៅក្នុងបក្ស។ លោក ខៀវ សំផន មិនត្រឹមតែមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍តែប៉ុណ្ណោះទេ គឺថាទើបតែនៅឆ្នាំ៧៦ទេ ដែលគាត់បានក្លាយទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមដែលបានប្រជុំតែម្តងគត់ក្នុងមួយឆ្នាំ ហើយការទទួលបានឋានៈនេះ គឺថាត្រូវផ្សាភ្ជាប់ទៅនឹងការដែលថាគាត់ទទួលពីតំណែងរបស់សម្តេច សីហនុ ហើយការទទួលនេះ គឺថាគ្មានអំណាចប្រតិបត្តិទាល់តែសោះ។ ហើយយើងមានមន្ទីរ៨៧០ ដែលមេធាវី អង់តា ហ្គីសសេ នឹងនិយាយឲ្យពាក់ព័ន្ធទៅនឹងចំណុចនេះ ពីព្រោះថាជាដំបូងនោះសហព្រះរាជអាជ្ញានិយាយថា ខៀវ សំផន បានទទួលតំណែងពី ខឿន នៅខែកុម្ភៈ ឆ្នាំ៧៧។ ហើយបន្ទាប់មកទៀតគាត់ថា យើងគួរតែដឹងថាខែកុម្ភៈ ឆ្នាំ៧៧ គឺមិនមានអង្គហេតុពាក់ព័ន្ធ

នឹងសវនាការនេះទេ។ ហើយគេនិយាយថា "អូ៎! វាមុន"។ យើងមើលភស្តុតាងទៅ សហព្រះរាជអាជ្ញាសូមអានកំណត់ហេតុគណៈអចិន្ត្រៃយ៍ថ្ងៃទី០៩ តុលា ឆ្នាំ៧៥។ យើងមើលឃើញហើយនៅក្នុងហ្នឹងគឺមានសរសេរអ្នកណាដែលជាប្រធានមន្ទីរនយោបាយ៨៧០នោះ? គឺខៀន។ អ្នកណាជាអ្នកទទួលសេចក្ដីណែនាំពី៨៧០នោះ? គឺ យ៉ែម។

[១០:០១:៥១]

ដូច្នេះ៩០ភាគរយ នៃទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការចូលរួមចំណែក និងចេតនារបស់លោក ខៀវ សំផន មិនត្រឹមតែក្រៅវិសាលភាពនៃការជំនុំជម្រះក្ដីទេ។ ក៏ប៉ុន្តែនៅពេលដែលយើងពិនិត្យការកំណត់អំពីតួនាទីរបស់លោក ខៀវ សំផន ដែលមាននៅក្នុងឯកសារសម័យនោះ ហើយនិងក្នុងសក្ខីកម្មរបស់សាក្សីនោះ យើងឃើញថាសហព្រះរាជអាជ្ញា គឺកែប្រែរហូតនូវខ្លឹមសារនៃភស្តុតាង។ ឧទាហរណ៍ ពួកគាត់មិនអល់អែកក្នុងការបង្កើតស្ថាប័នថ្មីមួយនៃបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំចង់និយាយអំពីស្ថាប័ននេះដែលគេហៅថា "មជ្ឈិមបក្ស" គឺស្ថាប័ននេះមិនមានទេ។ ថ្វីត្បិតតែពាក្យហ្នឹងមាននៅក្នុងអត្ថបទកាសែតមួយចំនួននៅក្នុងទង់បដិវត្ត ក៏ប៉ុន្តែវាអត់មានទេនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជានោះ។ ដូចលោក ស្ទីវ ហេដឌ័រ បានលើកឡើងពាក់ព័ន្ធទៅនឹងមន្ទីរ៨៧០នោះ គឺថាពេលនុ៎ងគឺថាដូចគេនិយាយពីវ៉ាស៊ីនតោនអ៊ីចឹង ដើម្បីរៀបរាប់អំពីអំណាចមជ្ឈិមនៅសហរដ្ឋអាមេរិក។ បញ្ហានោះគឺថាសហព្រះរាជអាជ្ញាមិនត្រឹមតែបង្កើតស្ថាប័ននេះទេ គាត់ថែមទាំងចង្អុលបង្ហាញអំពីសមាជិកផង។ ហើយក្នុងចំណោមសមាជិកនោះគាត់ចង្អុលបង្ហាញថា លោក ខៀវ សំផន គឺមាននៅក្នុងបញ្ជីសមាជិកផងដែរ។

[១០:០៣:២៨]

ការបង្កើតនូវយុទ្ធសាស្ត្រនេះ គឺថាវាត្រូវការពេលវេលា។ ហេតុនេះហើយ បានជាយើងស្នើសុំពេលវេលា។ ហើយស្នើសុំឲ្យមានការបកប្រែនៃសេចក្ដីសន្និដ្ឋានស្ថាពរ សារណាស្ថាពររបស់សហព្រះរាជអាជ្ញាជាភាសាបារាំង។ យើងគឺថា យើងទទួលបានឯកសារនេះដោយគ្មានការបកប្រែទេ។ ខ្ញុំបាននិយាយរួចមកហើយ ហើយយើងខ្ញុំក៏មិនពេញចិត្តដែរចំពោះស្ថានភាពនេះ។

យើងឃើញហើយថា មានការបង្កើតស្ថាប័នដែលហៅថា "មជ្ឈិមបក្ស" នេះ គឺថាព្រះរាជអាជ្ញាគាត់មានទេពកោសល្យក្នុងការបង្ហាញពីគំនិតច្នៃប្រឌិតដែលថាលោក ខៀវ សំផន នោះគឺជាប្រធាន គឺជាអ្នកទទួលខុសត្រូវអំពីអ្វីដែលបានកើតឡើងនៅក្នុងស្ថាប័នថ្មី ដែលគេហៅថា "មជ្ឈិមបក្ស"។ ហើយ

ថាគាត់ហ្នឹងគឺអនុវត្តគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ បើតាមសហព្រះរាជអាជ្ញានោះគឺថា មានការអនុវត្តជាមួយនឹងពួកកុម្មុយនីស្តដែលស្រែកឃ្លានអំណាច ហើយខ្មែរក្រហមគឺគាត់បានសម្រេចរួមគ្នា។

[១០:០៤:៤៤]

បាទ មានអ្នកជំនាញពីរគឺថា ស្ង៉ត ហើយ ឆេនដ័ល័រ បានមកដល់ទីនេះនៅក្នុងសវនាការយើងនេះ និយាយអំពីចំណុចនេះផងដែរ ហើយសេចក្តីសន្និដ្ឋានរបស់ពួកគាត់ខុសពីនេះ។ ឆេនដ័ល័រ បាននិយាយថា៖ "បើតាមគាត់វិញការសម្រេចចិត្តនៅក្នុងគណៈអចិន្ត្រៃយ៍នោះវារួម"។ ប៉ុន្តែគាត់និយាយអំពីគណៈអចិន្ត្រៃយ៍ មិនមែននិយាយពីគណៈមជ្ឈិមទេលោក ខៀវ សំផន ជាសមាជិកគណៈមជ្ឈិមទេ។ អ៊ីចឹងគាត់និយាយអំពីការិយាល័យមួយ មន្ទីរមួយនៅក្នុងបក្ស។ ឆេនដ័ល័រ និយាយថា ៖"ក្នុងគណៈអចិន្ត្រៃយ៍គឺថាគេសម្រេចរួម"។

ហើយ ស្ង៉ត គាត់បាននិយាយថា៖ "សេចក្តីសម្រេចទាំងអស់នុ៎ងត្រូវបានធ្វើឡើងដោយមនុស្សតិចតួចណាស់ ដល់ហើយ ខៀវ សំផន គាត់មិននៅក្នុងក្រុមមនុស្សនេះទេ"។ អ្វីដែលយើងត្រូវចាប់អារម្មណ៍នោះ គឺយើងត្រូវពិភាក្សាអំពីការវិភាគរបស់អ្នកជំនាញទាំងអស់នេះ ប៉ុន្តែព្រះរាជអាជ្ញាមិនបានធ្វើទេ។ គាត់ខកខានក្នុងការពន្យល់ថាហេតុអីក៏ ឆេនដ័ល័រ គាត់គួរឲ្យទុកចិត្តជាង ស្ង៉ត។

[១០:០៥:៥៧]

អ៊ីចឹងការពិចារណានេះ វាមិនមែនចេះតែធ្វើឡើងដោយឯងៗទេ។ ឆេនដ័ល័រ បានពន្យល់ថាគាត់មិនបានធ្វើការស្រាវជ្រាវតាំងពីឆ្នាំ១៩៩០ មកហើយ។ ហើយជីវប្រវត្តិរបស់ ស្ង៉ត ហ្នឹងមានលម្អិតជាង។ ហើយ ឆេនដ័ល័រ ក៏បានសារភាពផងដែរថា ពេលវេលាកាន់តែកន្លងទៅ ហើយយើងរកឯកសារលើរបបកម្ពុជាប្រជាធិបតេយ្យក៏កាន់តែច្រើនទៅ។ ពេលមកនៅទីនេះគាត់បានបញ្ជាក់ថា គាត់ទើបនឹងអាននៅក្នុងបន្ទប់សណ្ឋាគាររបស់គាត់នោះ អំពីដីកាដំណោះស្រាយ។ ហើយអង្កាល់នោះគាត់ថា គាត់ចង់បាន គាត់ចង់បានព័ត៌មាននៅក្នុងដីកាដំណោះស្រាយនេះពេលដែលគាត់ស្រាវជ្រាវពីមុនមកនោះ។ ហើយនៅឆ្នាំ២០១២នេះ ឆេនដ័ល័រ ដែលយើងបានសុំសួរគាត់ថា តើកំណត់ហេតុមីនា ឆ្នាំ១៩៧៦ ដែលធ្វើដោយ -- ថាសេចក្តីសម្រេចហ្នឹងធ្វើដោយតែ ប៉ុល ពត ទេ ឬក៏ជាលក្ខណៈរួម។ គាត់និយាយថា "អូ៎! ខ្ញុំបានអានឯកសារផ្សេងទៀតពេលក្រោយមកនេះ ហើយខ្ញុំមើលទៅហាក់ដូចជាជាសេចក្តីសម្រេចចិត្តហ្នឹងដូចជាលក្ខណៈរួមជាងដែលកាលខ្ញុំគិតពីមុនមក"។ ហើយបន្ទាប់មកទៀត គាត់និយាយថា "បើ

តាមរយៈភស្តុតាងដែលខ្ញុំអានតាំងពីនៅពេលនុ៎ងមកនេះ ថ្នាក់ដឹកនាំហ្នឹងមានលក្ខណៈរួមជាង បើធៀបនឹងឯកសារដែលខ្ញុំធ្លាប់បានស្រាវជ្រាវពីមុនមក មុនឆ្នាំ១៩៩០"។

[១០:០៧:២៤]

នៅថ្ងៃទី០៨ មីនា ឆ្នាំ២០១៣ គឺថាប្រហែលជាមួយខែក្រោយទៀត សហព្រះរាជអាជ្ញាបានឲ្យយោបល់របស់ ឆេនដ៍ល័រ ទៅ ហ្វីលីព ស្បូត ដែលឆ្លើយដូចតទៅនេះ គាត់ឆ្លើយថា៖ "គាត់មិនដឹងអំពីព័ត៌មានថ្មីដែល ឆេនដ៍ល័រ បានរកឃើញទេ បើសិនជាខ្ញុំដឹងនោះៗ យោបល់របស់ខ្ញុំប្រហែលជាខុសពីហ្នឹងហើយ។ ក៏ប៉ុន្តែបើតាមកិច្ចសម្ភាសន៍ដែលខ្ញុំបានធ្វើ ហើយនិងឯកសារដែលខ្ញុំបានអាន ខ្ញុំមានអារម្មណ៍ថា មានប្រហែលជាដូចជាការចេញសេចក្ដីសម្រេចរួមហើយ ប៉ុល ពត ជាអ្នកញាក់ខ្សែដើម្បីឲ្យសេចក្ដីសម្រេចនេះត្រូវបានទទួលដោយអ្នកទាំងអស់គ្នា។ ក៏ប៉ុន្តែសេចក្ដីសម្រេចទាំងអស់នោះសុទ្ធតែជាសេចក្ដីសម្រេចរបស់ ប៉ុល ពត តែម្នាក់ទេ"។ សូមបញ្ចប់ការដកស្រង់។

បើដូច្នេះយើងឃើញថា នៅពេលដែលយើងសិក្សាអំពីភាពផ្ទុយគ្នារបស់អ្នកជំនាញដែលមកទីនេះ អ៊ីចឹងគឺថាគោលជំហររបស់ព្រះរាជអាជ្ញាហ្នឹងដូចជាគោលជំហររបស់ ឆេនដ៍ល័រ ដែលបានឈប់ស្រាវជ្រាវតាំងពីឆ្នាំ១៩៩០មក ហើយដែលបានមកទីនេះដើម្បីផ្ដល់សក្ខីកម្មនោះ ហើយបានទទួលស្គាល់ថាគាត់បានដឹកាដំណោះស្រាយដោយយកចិត្តទុកដាក់។ ខាងព្រះរាជអាជ្ញា -- ខាងលោក ហ្វីលីព ស្បូត នោះថានៅ -- គាត់ឈប់ស្រាវជ្រាវតាំងពីឆ្នាំ២០០៤មក ហើយគាត់ក៏មិនយល់ដែរពីគំនិតយោបល់របស់លោក ឆេនដ៍ល័រ នេះលើការសម្រេចនៃគណៈអចិន្ត្រៃយ៍។ ដូច្នេះព្រះរាជអាជ្ញានោះគឺថាមានទំនោរទៅគ្រាន់តែយកឯកសារនេះបន្តិចៗ នេះម្តុំៗ ហើយក៏មិនដែលព្យាយាមពន្យល់ថា ហេតុអ្វីក៏អ្នកជំនាញនេះឬក៏សាក្សីនេះថា គួរឲ្យទុកចិត្តបានជាងមួយទៀត។ អ៊ីចឹងការមិនពិភាក្សាអំពីរឿងនេះនេះ វាធ្វើឲ្យយើងរកការពិតមិនឃើញទេ អ៊ីចឹងយើងអាចជំទាស់បាន។

[១០:០៨:៥៦]

បាទ ឥឡូវនេះខ្ញុំសូម -- បើនិយាយទាក់ទងទៅនឹងអង្គហេតុទួលពោធិ៍ជ្រៃដែលព្រះរាជអាជ្ញាបានលើកឡើងថា ប្រហែលជាត្រូវបានប្រព្រឹត្តឡើងក្រោមគោលនយោបាយក្នុងការបំបាត់អតីតអ្នករដ្ឋការសាធារណរដ្ឋខ្មែរ គឺជាគោលនយោបាយដែលបង្កើតឲ្យមានការវាយប្រហារជាប្រព័ន្ធ ហើយនិងជាទូទៅ។ អ៊ីចឹងទួលពោធិ៍ជ្រៃគឺថាអាចជា -- យកមកអនុវត្តជាការអនុវត្តនូវគោលនយោបាយនូវប្រហែលជា១៨០គីឡូម៉ែត្រពីភ្នំពេញ។ ដើម្បីឲ្យចំណេញពេល ខ្ញុំនឹងមិននិយាយដដែលៗដូចមេធាវីលោក នួន ជា

ទេ និយាយឲ្យខុសពីនេះ។

[១០:១០:១៣]

បាទខ្ញុំសូមរំឭកថា បើតាមអង្គហេតុគឺថាប្រភព ឬក៏ឫសគល់នៃព្រឹត្តិការណ៍ទាំងអស់នោះ យើងមិនបានស្ដាប់សាក្សី ដែលនិយាយអំពីការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនេះទេ។ អតីតទាហានខ្មែរក្រហមពីរនាក់ដែលមកផ្ដល់សក្ខីកម្មនៅទីនេះ គាត់នៅតែពី១៥គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃទេ កន្លែងអង្គហេតុដែលចោទប្រកាន់នោះ។ ហើយយោធាទាំងអស់នេះគាត់យាមនៅខាងក្រៅទេ នៅកន្លែងដែលគេប្រជុំនៅពោធិ៍សាត់នោះ។ ហើយទាហានម្នាក់ទៀតនោះ គឺថាគាត់នៅឈរជើងប្រហែលជា ៨គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃទេ។ ហើយគាត់ពន្យល់ថា សហការីគាត់ម្នាក់ហ្នឹងជាទាហាន ហ្នឹងនៅស្ដាប់វ៉ាដ្យូ ស្ដាប់អាយកូម ហើយគាត់ឮគេបាញ់ស្នូរកាំភ្លើងនៅក្នុងអាយកូមទេ។ ហើយមានសាក្សីទី៣ ដែលជាអតីតទាហានផងដែរ ទាហាន លន់ នល់។ គាត់បានចូលរួមកិច្ចប្រជុំពីរមុននុ៎ង ដែលកើតឡើងនៅពោធិ៍សាត់ គឺថាពី១៥គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃ ហើយចេញពីប្រជុំមកនោះគាត់ឡើងឡាន ដែលគេដឹកទៅ គេសន្មតថាទៅទួលពោធិ៍ជ្រៃនោះ ហើយគាត់បានរង់ចាំ ចាំអ្នកផ្សេងទៀត។ អ៊ីចឹងដល់ពេលឡានគេថាទៅទួលពោធិ៍ជ្រៃអត់មកវិញហ្នឹងគាត់អត់បានឡើង គាត់ត្រឡប់ទៅផ្ទះវិញទៅ។

[១០:១១:៥៨]

ហើយគេក៏បាននិយាយផងដែរ អំពីលក្ខណៈសើៗនៃការសង្កេតរបស់សហចៅក្រមស៊ើបអង្កេត ឧទាហរណ៍ដូចជាមើលគ្រាន់តែឃើញថាកម្មេចកម្ទីខោអាវនៅទួលពោធិ៍ជ្រៃ អ៊ីចឹងវាអត់ៗមានឃើញលក្ខណៈយោធាអីទេ ហើយជួនកាលឃើញដែលថា ឃើញសំបកកាទូសមួយចំនួន ក៏ប៉ុន្តែសាក្សីដែលមកនេះអត់មានបាននិយាយទេ។ ហើយគឺថាព្រោះថាពីមុនសម័យ ប៉ុល ពត នោះក៏មានគេបាញ់គ្នានៅម្ដុំទួលពោធិ៍ជ្រៃហ្នឹងដែរ។ អ៊ីចឹងការច្បាំងគ្នាដោយហិង្សានេះប្រហែលជា ដូចយើងស្ដាប់លោក អ៊ុង ឆាត់ ដូចអីហ្នឹង លោកក៏បាននិយាយដែរថា នៅខេត្តពោធិ៍សាត់ហ្នឹងនៅថ្ងៃទី១៩ មេសា ៧៥ បានធ្លាក់នៅក្នុងកណ្ដាប់ដៃខ្មែរក្រហម។ ហើយលោក ស៊ុម អាឡាត់ ដែលជាអតីតយោធាសាធារណរដ្ឋខ្មែរដែរគឺថា៖ “ក្រោយពីខេត្តពោធិ៍សាត់ចុះចាញ់ ទាហាន លន់ នល់ នៅតែបន្តធ្វើការដំណើរការរំដោះខ្លួន”។ ហើយគាត់និយាយថា៖ “សូម្បីតែក្រោយដែល លន់ នល់ ចុះចាញ់ហើយហ្នឹងទាហាន លន់ នល់ នៅតែស្លៀកឯកសណ្ឋានដើរនៅពោធិ៍សាត់ហ្នឹងនៅឡើយទេ”។ ហើយគាត់ក៏បានលើកឡើងផងដែរថា៖ “គេតស៊ូឡើងវិញ ហើយដូចបន្ទាប់ពីភ្នំពេញចាញ់ហ្នឹង ដល់ហើយគេផ្សាយតាមវ៉ាដ្យូឲ្យទម្លាក់អាវុធ”។

[១០:១៣:៣០]

បាទ ខ្ញុំធ្វើការកត់សម្គាល់ដូចនេះដូចដែលខ្ញុំ គ្រាន់តែខ្ញុំចង់ឲ្យអស់លោកទាំងអស់គ្នាពិចារណាទេ។ ហើយដូចសេចក្ដីសម្រេចរបស់ក្រុម នួន ជា គឺថាមានលក្ខណៈពិសេស ឧទាហរណ៍ លោក លឹម សាត បានលើកឡើងថា គាត់ជាប្រធានក្រុមតូចមួយនៅក្នុងទាហានខ្មែរក្រហម។ គាត់បានលើកឡើងថា៖ "ខ្មែរក្រហមប្រហែលជាសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ហើយគាត់ហ្នឹងបានគេបញ្ជូនទៅមន្ទីរស-២១ ដោយសារក្បត់អង្គការ"។ ចំណុចនេះអត់បាននិយាយលម្អិតទេនៅសវនាការនេះក៏ដោយ ក៏ប៉ុន្តែធ្វើឲ្យយើងសង្ស័យលើអំណះអំណាងរបស់ព្រះរាជអាជ្ញាដែលថាការសម្លាប់នេះត្រូវចេញបញ្ជាដោយថ្នាក់លើ។

បាទ ឥឡូវខ្ញុំសូមសង្កត់ធ្ងន់លើការដែលសាក្សីទាំងបីហ្នឹងមិនដែល -- និយាយមិនស៊ីសង្វាក់គ្នាទេ។ មិនត្រឹមតែថាខ្លួនមិនបានមើល ជាសាក្សីអង្គហេតុ ឃើញអង្គហេតុដោយផ្ទាល់ខ្លួន ដូចនៅប្រជុំពោធិ៍សាត់ ហើយនិងចំនួនប្រជុំនៅពោធិ៍សាត់ហ្នឹង ដើម្បីបញ្ជូនមនុស្សទៅទួលពោធិ៍ជ្រៃក៏ដោយ ក៏គាត់មិនដឹង ហើយកាលបរិច្ឆេទប្រជុំ ម៉ោងប្រជុំ ចំនួនអ្នកដែលចូលរួមក្នុងប្រជុំនោះ មុខងារស៊ីវិល ហើយនិងយោធា អ្នកដែលចូលរួមកិច្ចប្រជុំហ្នឹងៗ ហើយការដែលថា តើពួកគេស្លៀកពាក់ឯកសណ្ឋាន ឬក៏ស្លៀកខោអាវស៊ីវិល ឬក៏មានស៊ីវិលផង យោធាផង។

[១០:១៥:២០]

អ៊ីចឹងសួរថា គាត់ចង់ដឹងថា គាត់បានចូលទៅក្នុងកន្លែងប្រជុំនុ៎ងដែរ ឬក៏នៅក្រៅ? ដូចថាតើពួកដឹងថាគេចូលទៅប្រជុំនោះ គេជិះអីមក? តើពេលចេញទៅវិញចេញតាមរបៀបណា? ហើយនៅចុងបញ្ចប់នោះ អ៊ីចឹងគឺថាពណ៌ ឬក៏ម៉ាកឡានអីហ្នឹងដែលថា យើងសន្មតថានាំអ្នកទាំងអស់នោះទៅទួលពោធិ៍ជ្រៃនោះ។ ចំណុចទាំងអស់នេះនេះ សាក្សីទាំងបីនាក់ហ្នឹងនៅចម្ងាយ ១៥គីឡូម៉ែត្រពីអង្គហេតុឯណោះ។ អ៊ីចឹងគាត់អត់មានដឹងអីទេ។

បាទ លើសពីភាពផ្ទុយគ្នានេះទៀត ពាក្យសម្ដីដែលយើងបាន ទទួលបានពីគាត់ហ្នឹង គឺថាមិនគួរឲ្យ -- គឺថាទុកចិត្តបានតិចបំផុត។ ហើយយើងបានពន្យល់ហើយចំណុចនេះរួចហើយនៅក្នុងសារណារបស់យើង ហើយខ្ញុំមិននិយាយទៀតទេ ដើម្បីឲ្យចំណេញពេលវេលា។

ដោយសារពុំមានសម្ភារៈភស្តុតាងគ្រប់គ្រាន់ អត់មានឯកសារសម័យហ្នឹង អត់មានគំនិតរបស់អ្នកជំនាញ យោបល់របស់អ្នកជំនាញ អ៊ីចឹងយើងមិន ៗអាចមានមូលដ្ឋានអីច្បាស់បានទេ។ ជាការពិត

ណាស់ដែលសហព្រះរាជអាជ្ញា ដែលមិនបានរកបង្ហាញអំពីអាទិភាពនៃការអង្គហេតុពិសេសនៃការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃទេ។ យើងត្រូវតែយល់អំពីខ្សែបញ្ជា ថាមានអ្នកណាខ្លះបានចូលរួមនៅផ្នែកណាខ្លះ?

[១០:១៧:០៦]

អ៊ីចឹងត្រង់ចំណុចនេះ គឺថាត្រូវតែថាខ្សែបញ្ជាហ្នឹងវាអត់ឃើញមានអីច្បាស់លាស់។ អ៊ុង ឆាត់ បានដែលជាទាហានខ្មែរក្រហមអាយុ២៣ នៅពេលនោះ គាត់ថា គាត់អត់បានទទួលបញ្ជាអីជាក់លាក់ទេ អំពីថ្នាក់លើរបស់គាត់ទាក់ទងនឹងកិច្ចប្រជុំនេះ ហើយគាត់ក៏មិនដឹងថាមានផែនការអ្វីមួយហ្នឹងដែលគេបានបង្កើតឡើងជាមុននោះដែរ។ ហើយគាត់ក៏បានលើកឡើងផងដែរ គឺថាផែនការតែមួយគត់ ដែលគាត់អត់ដឹងទាក់ទងនឹងអតីតយោធាខ្មែរក្រហមហ្នឹង គឺថាគាត់ដឹងតែមួយគត់ គឺថាធ្វើម៉េចឲ្យសាមគ្គីគ្នាដើម្បីសាងសង់ប្រទេសឡើងវិញ។

លឹម សាត បានពន្យល់ផងដែរ គាត់ជាទាហានខ្មែរក្រហម គាត់ថា គាត់បានទទួលបញ្ជាពីថ្នាក់លើរបស់គាត់ ថាឲ្យទាហាន លន់ នល់ ហ្នឹងប្រជុំនៅពោធិ៍សាត់។ ហើយគាត់បានបញ្ជាក់ទៀតផងដែរថា ទោះបីជាអង្គាល់នោះសហព្រះរាជអាជ្ញាចង់បោះព្រុយយ៉ុងឲ្យគាត់ក៏ដោយក៏គាត់ គាត់និយាយថាៗ៖ “គោលបំណងនៃកិច្ចប្រជុំនុ៎ង គឺជា -- មានបំណងសម្លាប់”។ សហព្រះរាជអាជ្ញាបានសួរថា តើមេគាត់បាននិយាយប្រាប់ថា ថ្នាក់ណាដែលបញ្ជាឲ្យ -- ចេញបញ្ជាឲ្យគាត់? ហើយនៅម៉ោង ០៩:៥៤ ថ្ងៃទី០២ ឧសភា គាត់ឆ្លើយថា៖ “មិនមែនអ៊ីចឹងទេ។ សហព្រះរាជអាជ្ញាថា អ៊ីចឹងខុសហើយ”។

[១០:១៨:២៩]

លឹម សាត គាត់ថា គាត់មិនដឹងអំពីគោលនយោបាយសម្លាប់អតីតយោធា លន់ នល់ ទេ ហើយនៅពេលនោះ គាត់និយាយថា៖ “នៅពេលនោះគាត់បានប្រមូលមនុស្សទាំងគ្នា ទាហាន ប៉ូលិស ហើយខ្ញុំមិនដឹងថា គាត់នៅទីនោះដើម្បីឲ្យគេសម្លាប់នោះទេ។ កាលណោះខ្ញុំគ្រាន់តែយាមនៅតាមផ្លូវ ហើយខ្ញុំឃើញឡានធំតែប៉ុណ្ណឹងឯង”។ បញ្ចប់ការដកស្រង់។ តើក្នុងលក្ខខណ្ឌនេះ តើសហព្រះរាជអាជ្ញាអាចថា លោក ខៀវ សំផន មានពិរុទ្ធភាពអំពីការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃហ្នឹងតាមរបៀបណា?

បាទ ជាដំបូងនោះ គឺថាទោះបីជាមានភាពមិនស៊ីសង្វាក់គ្នាដែលខ្ញុំបានលើកឡើងអំមិញនេះក៏ដោយ ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃនោះ ត្រូវបានបង្ហាញថា មានហើយ។ នេះគឺជាកំហុសធ្ងន់ណាស់ក្នុងផ្លូវច្បាប់ដែលលើកឡើងអះអាងយ៉ាងដូច្នេះ។ ជំហានទី២ គឺថាដោយសារមិនអាចចូលតាម

ទ្វារបាន ក៏ចូលតាមបង្អួចទៅ នេះសហព្រះរាជអាជ្ញាធ្វើយ៉ាងដូច្នេះ។ ហើយគេមិនអាចរកឃើញអំពីការអនុវត្តអីទេ ហើយក៏ខំបង្ហាញថា មានអត្ថិភាពនៃគោលនយោបាយទូទៅដែលមានគោលបំណងក្នុងការសម្លាប់អតីតទាហាន លន់ នល់ ហើយអ៊ីចឹងដោយសារខ្លួនមិនអាចរកភស្តុតាងជាក់លាក់បាន ក៏បង្ហាញថាថ្នាក់លើហ្នឹងគេមានចេតនាយ៉ាងដូច្នេះ។

[១០:១៩:៥៩]

បាទ មានអ្នកកវី ហ្សាក់ ព្រីវើស *(Jacques Prevert)* ជាតិបារាំងម្នាក់ និយាយថា ព្រះរាជអាជ្ញាហ្នឹងគេមានអំណះអំណាងច្របូកច្របល់ដែលយើងមិនអាចបែងចែកបាន។ ខ្ញុំសូមដកស្រង់ពាក្យសម្តីមួយៈ

"១) នៅខែមេសា ឆ្នាំ៧២, ៧៥ ខៀវ សំផន បានធ្វើសុន្ទរកថាជាសាធារណៈជាច្រើនតំណាងឲ្យហ្នុង និងហ្រ្គុង ដែលនិយាយកំណត់អំពីអ្នកទទួលខុសត្រូវទាំងប្រាំពីរនាក់នៃរបប លន់ នល់ ដែលជាខ្មាំង ហើយដែល លន់ នល់ ហ្នឹងបានក្បត់ សីហនុ។ ហើយដែលបង្កឲ្យមានសង្រ្គាមវៀតណាមហ្នឹងចូលមកដល់ប្រទេសខ្មែរដូចជាទាហានវៀតណាមចូលមកដល់ទឹកដីខ្មែរជាដើមហ្នឹង។

ទី២) ខៀវ សំផន កាលនៅទួលពោធិ៍ជ្រៃហ្នឹង លោក ខៀវ សំផន ហើយ ប៉ុល ពត នោះនៅជាមួយគ្នា អ៊ីចឹងគេបានទាំងមើល ហើយនិងបញ្ជាការកាប់សម្លាប់ទាហានសាធារណរដ្ឋខ្មែរផងដែរ។

ទី៣) ការវាយប្រហារនោះមាននៅក្នុងកន្លែងដែល ខៀវ សំផន នៅទីនោះ។ អ៊ីចឹងមានកំណត់ហេតុគណៈអចិន្ត្រៃយ៍នៅឆ្នាំ៧៦នោះថា មានលើកឡើងអំពីគោលនយោបាយនេះ។

ចំណុចទី៥ របាយការណ៍ ហើយនិងតេឡេក្រាមត្រូវបានផ្ញើទៅមន្ទីរ៨៧០ ដើម្បីពណ៌នាពីការកាប់សម្លាប់ទាហាន លន់ នល់។ មានតេឡេក្រាមរបស់ភូមិភាគខាងឧត្តរ ទាក់ទងនឹងបញ្ហាទាំងអស់នេះ។

[១០:២១:៤២]

ចំណុចទី៧ គឺថាក្រោយពីជ័យជម្នះហើយ ខៀវ សំផន នៅភ្នំពេញនៅជិត ប៉ុល ពត ហើយនិងមេដឹកនាំផ្សេងទៀត អ៊ីចឹងគាត់ដឹងអ្វីទាំងអស់។

ចំណុចទី៨ ខៀវ សំផន បានចូលរួមកិច្ចប្រជុំអចិន្ត្រៃយ៍ញឹកញាប់ ហើយដែលប្រធានភូមិភាគដែលមកបង្ហាញរាយការណ៍ពីស្ថានភាពនៅកន្លែងខ្លួន តាមភូមិភាគរបស់ខ្លួន។

ចំណុចទី៩ តេឡាក្រាមរបស់ កង ចាប នៅខែកញ្ញា ឆ្នាំ១៩៧៧ ផ្ញើទៅនួន ជា ហើយនិងមន្ទីរ

៨៧០ ចម្លងជូន។

ចំណុចទី១០ សុន្ទរកថារបស់លោក ខៀវ សំផន នៅខែមេសា ឆ្នាំ១៩៧៧-៧៨។

ទី១១) លោក មាស វឿន ដែលសហព្រះរាជអាជ្ញាលើកឡើងថា--"

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់និយាយយឺតបន្តិច និយាយលឿនខ្លាំង អ្នកបកប្រែតាមអត់ទាន់លោកប្រធាន។ សូមបន្ថយល្បឿនបន្តិច។

[១០:២២:៣៩]

**លោក អាកទ្ញូរ វែកគែន៖**

"បាទ ខៀវ សំផន ប្រហែលជាមានអំណាចក្នុងការដោះលែងសមាជិកក្រុមគ្រួសារថ្លៃរបស់គាត់ដែលលោក មាស វឿន បានឲ្យគេចាប់ក្នុងចំណោមអ្នកផ្សេងទៀតដែរ។ តើអ៊ីចឹងមានសេចក្តីសម្រេចនៅឆ្នាំ១៩៧៨ ដែលភ្ជាប់គោលនយោបាយទាក់ទងទៅនឹងខ្មាំង សេ.អ៊ី.អា មានជាប់ពាក់ព័ន្ធនឹង សេ.អ៊ី.អា។ ចំណុចទី៣ គឺថាមានកិច្ចសម្ភាសន៍របស់លោក ខៀវ សំផន នៅក្នុងចន្លោះឆ្នាំ៩០, ៩០ ប្លាយដែលគាត់បានគាំទ្រគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ"។

បាទ ខ្ញុំសូមបញ្ចប់ពីការលើកឡើងទាក់ទងនឹងភាពច្របូកច្របល់របស់អំណះអំណាងខ្មែរក្រហម។ ហើយត្រង់ចំណុចនេះ ខ្ញុំចង់និយាយថាតើមានប៉ុន្មានទំព័រហើយ ហើយមានប៉ុន្មានហើយត្រូវ ខ្ញុំត្រូវមានប៉ុន្មាន ដើម្បីឆ្លើយតបទៅនឹងអំណះអំណាងក្រៅវិសាលភាព ហើយរញ៉េរញ៉ៃច្របូកច្របល់នេះ។

[១០:២៣:៥៣]

ក៏ប៉ុន្តែនៅក្នុងរឿងកាត់ក្តីនេះ ការយុត្តិសាស្ត្រដែលធ្វើឲ្យគេពិចារណាមិនបាន ដើម្បីឆ្លើយតបនេះមានគ្រប់ជាន់ថ្នាក់ គឺជាយុត្តិសាស្ត្រដូចនឹងយុត្តិសាស្ត្រជម្លៀសដំណាក់កាលទី១, ទី២ ដែល។ យើងដកដង្ហើមមិនរួចទេក្នុងការរៀបរាប់ចោទប្រកាន់មិនដឹងឯណាឯណីយ៉ាងនេះនោះ។ ខ្ញុំសូមធ្វើការបែងចែកឲ្យច្បាស់លាស់នៅក្នុងគំនរគ្មានសណ្តាប់ធ្នាប់នេះ។ ពុំមានតេឡេក្រាមណាទាក់ទងទៅនឹងកាប់សម្លាប់មនុស្ស ឬក៏អតីមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរទេ ហើយមិនដែលមានអ្នកណាផ្ញើមកលោក ខៀវ សំផន ជូនដំណឹងដល់គាត់ទេ ហើយក្នុងរបបកម្ពុជាប្រជាធិតេយ្យទាំងមូលតែម្តង។

លោកសហព្រះរាជអាជ្ញា លោកមានរយៈពេលច្រើនម៉ោងដើម្បីឆ្លើយតបមកយើងវិញ ថ្ងៃខានស្អែកនេះ។ យើងឃើញថាមានតេឡេក្រាមតែមួយ គឺថាមុន ហើយនិងក្រោយទួលពោធិ៍ជ្រៃដែលមាន

បញ្ជូនដំណឹងប្រាប់ពីលោក ខៀវ សំផន អំពីការកាប់សម្លាប់នេះទេ។ ដូចមិនមានទេ អត់មានទេគ្មានសេចក្ដីណែនាំ អត់មាន។

[១០:២៥:១១]

ទី២) អង្គហេតុទួលពោធិ៍ជ្រៃនោះ ត្រូវបានប្រព្រឹត្តក្រោយជម្លៀសទីក្រុងភ្នំពេញតែមួយភ្លែតទេ។ តើភាពពាក់ព័ន្ធនៃការអះអាងយ៉ាងនេះនេះ ដែលថាអះអាងយកអស់តែបាន ដែលទាក់ទងទៅនឹងថាឆ្នាំ ៧៦, ៧៧, ៧៨ អី អាចបន្តហួសហ្នឹងទៀត ក៏បានដែរ។ ជាច្រើនឆ្នាំក្រោយអង្គហេតុ ដែលអង្គហេតុនេះសុទ្ធតែប្ដឹងទៅតុលាការហើយ។ អ៊ីចឹងវាមិនជាការគ្រប់គ្រាន់ទេ ក្នុងការទាញការសន្និដ្ឋានដែលចេញអង្គហេតុ ដែលនៅក្រោយអង្គហេតុដែលយើងត្រូវកាត់សេចក្ដីនេះ ត្រូវបង្ហាញភស្តុតាង។

អ៊ីចឹងអំណះអំណាងតែមួយគត់ អំណះអំណាងតែមួយដែលយើងចាប់អារម្មណ៍ទាក់ទងនឹងបញ្ហានេះ គឺដែលមិនទាន់ដោះស្រាយបាន គឺទាក់ទងទៅនឹងការនិយាយទូរស័ព្ទ ដែលមានលោក ខៀវ សំផន មានហត្ថលេខាបន្ទាប់ពីការកិច្ចប្រជុំធំមួយរបស់ ហ្វ្រុង នៅថ្ងៃ២៤, ២៥, ២៦ កុម្ភៈ ឆ្នាំ១៩៧៥។ នេះគឺជាដំណាក់កាលសង្គ្រាមសំខាន់ណាស់ ខ្លាំងក្លាណាស់ប្រឆាំងនឹង លន់ នល់។ ហើយលិខិតនេះដែលចុះហត្ថលេខដោយលោក ខៀវ សំផន ដែលបញ្ជាក់ពីថាមានបញ្ហា ការយល់ព្រមឲ្យមានការកាប់សម្លាប់មនុស្ស ប៉ុន្តែលោកមិនបានផ្ដល់ភស្តុតាងអ្វីទេ ទាក់ទងនឹងការសម្លាប់ទួលពោធិ៍ជ្រៃនោះ។

បាទ អ៊ីចឹងសូមអានសម្រង់មួយនៃកិច្ចពិភាក្សានេះ ការនិយាយគ្នានេះ ដែលចុះនៅខែកុម្ភៈ ឆ្នាំ១៩៧៥ គឺការផ្សាយវ៉ាដ្យូ (សូមទោស)។ គឺឯកសារ E3/117 “នៅក្នុងកាលៈទេសៈនេះ អំណោយផលខ្លាំងក្លានេះ សមាជជាតិដ៏អស្ចារ្យបានធ្វើការពិភាក្សាយ៉ាងខ្លាំងក្លា ហើយនិងស្រាវជ្រាវអស់រយៈពេលពីរថ្ងៃ ហើយបានចេញផ្សាយនូវសេចក្ដីប្រកាសជាច្រើនអំពីបញ្ហាដ៏មានសារៈសំខាន់ផ្សេងៗ រួមទាំងបញ្ហាដូចខាងក្រោមៈ

[១០:២៧:២៤]

ទី១) ទាក់ទងនឹងពួកក្បត់ទាំងប្រាំពីរនៅក្នុងទីក្រុងភ្នំពេញ សមាជជាតិបានសម្រេចដូចតទៅ ពួកក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, ហ្វៃណង់ដែស គឺពួកក្បត់និងជាប្រធានក្រុមធ្វើរដ្ឋប្រហារប្រឆាំងនឹងជាតិ ដែលបានផ្ដួលរំលំឯករាជ្យ សន្តិភាព អព្យាក្រិត របស់កម្ពុជា។ ពួកគេគឺជាអ្នកដែលអន្ទងជាមួយពួកចក្រពត្តិអាមេរិក ហើយទាក់ទងនឹងចក្រពត្តិអាមេរិកឲ្យចូលលុកលុយ រុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់នៅក្នុងអណ្ដាតភ្លើង ហើយនិងនាំបំផ្លិចបំផ្លាញដែលមិន

ដែលធ្លាប់មាន និងដែលមិនអាចពិពណ៌នាបាន។ ព្រមទាំងការឈឺចាប់ចំពោះប្រទេសកម្ពុជា និងសេចក្ដីមរណៈ ចំពោះព្រះសង្ឃ និងប្រជាជនជាច្រើននាក់ ទាំងបុរស ស្ត្រី និងកុមារ ក្នុងនាមរណសិរ្សរួមរួបជាតិកម្ពុជា និងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិបានប្រកាសថា វាជាការចាំបាច់ និងដាច់ខាតត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរ ហើយនិងចំពោះអំពើក្បត់របស់ពួកវាប្រឆាំងនឹងប្រជាជាតិ និងអំពើហ្វាស៊ីស ពុករលួយ ឧក្រិដ្ឋ ដែលមិនអាចធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ចំពោះមន្ត្រីថ្នាក់ទាប់ និងខ្ពស់ដទៃទៀតនៃក្រសួងផ្សេងៗ នាយទាហាន នគរបាល នគរបាលគ្រប់ប្រភេទ និងសមាជិកនៃផ្នែកស្វ័យការពារ និងផ្នែកប្រដាប់អាវុធនៃដទៃទៀត អ្នកនយោបាយ អ្នកមុខការធំៗ និងសមាជិកគ្រប់ប្រភេទ ក្នុងគ្រប់អង្គការនៃរបប--

[១០:២៩:០២]

លោកប្រធាន ខ្ញុំអាន ខ្ញុំនឹងបន្ថយ ព្រោះឃើញថាគេធ្វើសញ្ញាថាឲ្យបន្ថយ។

--អ្នកផ្សេងទាំងប៉ុន្មានដែលនៅតូចៗហ្នឹង អាចចូលបម្រើជាតិបាន ហើយនិងប្រជាជនខ្មែរ។ លើកលែងតែពួកអ្នកទាំងប្រាំពីរនាក់ហ្នឹងទេ។ ជាតិ និងប្រជាជនកម្ពុជា ហ្ញុង និងហ្គ្រុង នឹងទទួលអតីតយោធា ហើយនិងប៉ូលិសតូចតាចទាំងអស់នេះ ហើយមន្ត្រីរដ្ឋការ អ្នកនយោបាយ អ្នកមានមុខងារ ទាំងអស់ហ្នឹង ឲ្យតែគេប្រឆាំងនឹងពួកក្បត់ទាំងប្រាំពីរនាក់ហ្នឹង ហើយទម្លាក់អាវុធចុះ អាចនៅជាមួយយើងបាន។ អាស្រ័យហេតុដូច្នេះ តំណាងឲ្យហ្ញុង និងហ្គ្រុង ហើយនិងកងប្រដាប់អាវុធរំដោះជាតិ សមាជ --សូមជំរុញឲ្យប៉ូលិស ទាហាន ឈ្លប មន្ត្រីរដ្ឋការ អ្នកនយោបាយទាំងអស់ ហើយនិងអ្នកដែលផ្សេងៗទាំងអស់នៅក្នុងតំបន់ដែលនៅក្រោមអំណាចរបស់ខ្មាំងជាបណ្ដោះអាសន្ននោះ សូមឲ្យបោះបង់អ្នកប្រាំពីរនាក់នេះចោល ហើយនិងចូលរួមក្នុងចលនាប្រជាជននៅទីក្រុងភ្នំពេញ ហើយនិងនៅក្នុងតំបន់ផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង ហើយនិងត្រូវតែបន្តប្រឆាំងនឹងខ្មាំងដោយរកមធ្យោបាយគ្រប់យ៉ាងទាំងអស់ ដើម្បីបំផ្លាញរដ្ឋាភិបាលដ៏អាក្រក់របស់ពួកគេ បន្ទាយទាហាន និងប៉ុស្តិ៍ប៉ូលិស ហើយនិងឃ្លាំងរំសេវជាដើមឲ្យបានជាដាច់ខាត"។ បាទ សូមបញ្ចប់ការដកស្រង់។

[១០:៣០:៥០]

បាទ ជាបឋមអ្វីដែលច្បាស់លាស់នៅពេលដែលយើងសិក្សាលើសេចក្ដីប្រកាសតាមវិទ្យុនេះគឺថា មហាក្បត់ទាំងប្រាំពីរនាក់នេះនឹងត្រូវបានសម្លាប់នៅពេលដែលដណ្ដើមបានទីក្រុងភ្នំពេញ

ហើយអ្នកប្រាំនាក់ទៀតនោះត្រូវបាន -- បាទជាការល្អក្នុងការកត់សម្គាល់ថា អ្នកជំនាញ ហ្វីលីព ស្ហូត សង្ស័យថាសមាជខែកុម្ភៈ ឆ្នាំ១៩៧៥ នោះអាចមាន ឬក៏មិនអាចមាន។ ហើយគាត់ក៏បាននិយាយថា គាត់មិនដឹងថា តើលោក ខៀវ សំផន បានពិគ្រោះសេចក្តីប្រកាសនេះ ឬក៏អត់ទេមុននឹងគេចាក់ផ្សាយសេចក្តីថ្លែងការណ៍នេះនោះ។ នេះគឺគ្រាន់តែជាព័ត៌មានចង្អុលបង្ហាញ យើងខ្ញុំមិនចង់គេចវេះក្នុងការពិភាក្សាចំណុចនេះទេ ក៏ប៉ុន្តែយើងត្រូវតែសួរថា តើសុន្ទរកថានេះៗវាបង្ហាញអំពីការយល់ស្របរបស់លោក ខៀវ សំផន ដែរឬទេទាក់ទងនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនេះ? មិនមានទេ ហ្គ្រុង បានបង្ហាញអំពីការសម្លាប់របស់មហាក្បត់ទាំងប្រាំពីរនាក់នេះ។

[១០:៣២:១៣]

ប្រទេសកម្ពុជាត្រូវបានគេបំផ្លាញ បំភ្លេច ហើយយើងហ្នឹងរហូតដល់ថ្ងៃនេះគឺថា ជាប្រទេសដែលត្រូវបានគេទម្លាក់គ្រាប់បែកច្រើនជាងគេបំផុត ហើយកាលសម័យនោះៗយើងស្ថិតនៅក្នុងសង្គ្រាមនៅក្នុងបរិបទហ្នឹងគេបានប្រាប់ជាមុនថា អ្នកមហាក្បត់ទាំងប្រាំពីរនាក់ហ្នឹងនឹងត្រូវទទួលទារុណកម្ម ហើយលើសពីហ្នឹងទៀតគឺថាមានការឃោសនា ដែលគេហៅថាវាជាលក្ខណៈសង្គ្រាមចិត្តសាស្ត្រ។

អ៊ីចឹងបើយើងមើលទៅហ្នឹង មើលទៅថាក្នុងសម័យសង្គ្រាមជារឿងធម្មតាទេ ជាការប្រកាសបែបហ្នឹង។ អ៊ីចឹងឧទាហរណ៍ដូចជាយោបល់របស់ ប៉ែន នុត, ហ៊ូ យន់, ហ៊ូ នឹម ហើយនិងរបស់អ្នកផ្សេងទៀតដែលបាននិយាយដូចអ៊ីចឹងដែរ គំនិតដូចការប្រកាសផ្សាយហ្នឹង ហើយសម្តេច សីហនុ គាត់ធ្លាប់និយាយប្រភេទបែបហ្នឹងដែរ ក៏ខ្លឹមសារដូចគ្នាហ្នឹង ដែលនិយាយថា ហ្គ្រុងមិនសូវជាមានអំណាចសកម្មប៉ុន្មានទេ ព្រោះថាខ្លួនមិនប៉ាន់ឲ្យ មិនប៉ាន់តវ៉ាហ្នឹងទេ ព្រោះថាយើងមើលទៅ សីហនុ គាត់បន្ថែមឈ្មោះឡើងដល់១៥នាក់នោះ មិនត្រឹមតែប្រាំពីរនាក់ទេ។ អ៊ីចឹងថាតើមានអ្នកណាទៅតាមរករឿងគាត់ទេ? អ៊ីចឹងគេអាននៅ -- គេយល់គ្រាន់តែនេះជាស្នារតីតស៊ូប្រឆាំងនឹងខ្មាំង ដើម្បីមាតុភូមិតែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមអភ័យទោសលោកមេធាវី អាកទ្បូរ វែកគែន គាត់មកយឺតបន្តិចគាត់កំពុងតែប្រញាប់មកហើយ។ សូមអភ័យទោសឲ្យលោកប្រធានមេត្តារង់ចាំបន្តិច។

[១០:៥៤:១២]

**លោក អាកទ្បូរ វែកគែន៖**

សូមអភ័យទោសលោកប្រធាន។

មុនពេលឈប់សម្រាកខ្ញុំបានលើកឡើងអំពីសុន្ទរកថា ស្រដៀងគ្នាទៅនឹងសុន្ទរកថារបស់លោក ខៀវ សំផន ដែលបានថ្លែងប៉ុន្មានសប្តាហ៍ក្រោយមកដោយសម្តេច សីហនុ។ ខ្ញុំសូមអានសេចក្តីដកស្រង់មួយចំនួន៖ “សេចក្តីថ្លែងការណ៍របស់សម្តេចប្រមុខរដ្ឋ នរោត្តម សីហនុ ដើម្បីបរិហារ នូវកលល្បិចថ្មីៗរបស់ចក្រពត្តិអាមេរិកាំង និងបរិវាររបស់ពួកវានៅទីក្រុងភ្នំពេញ” គឺឯកសារ E3/1287។

“តាងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមទាញចំណាប់អារម្មណ៍ពិភពលោកទាំងមូលថា៖

ទី១) ពួកមន្ត្រីមានបុណ្យស័ក្តិ និងកម្មាភិបាលរបស់សាធារណរដ្ឋខ្មែរដែលមានអំនួតបោកប្រាស់ខុសគ្នាពីអ្នកជាតិនិយមខ្មែរក្រហម ដូចជាពណ៌ខ្មៅ ដែលខុសគ្នាពីពណ៌ក្រហម។ ពីព្រោះពួកសាធារណរដ្ឋនិយមក្លែងក្លាយទាំងនេះមានឯកគ្គតកម្មពិភពលោកជាងប្រាំឆ្នាំមកហើយ ខាងការក្បត់ជាតិ ខាងសេចក្តីថោកទាប ផ្នែកសីលធម៌ ភាពស្អុយរលួយក្នុងសង្គម និងអំពើពុករលួយ។ ប្រាកដណាស់ប្រជាជនកម្ពុជា នឹងកម្ទេចពួកវាឲ្យចេញអស់ពីសង្គមរបស់យើង។ នេះឯងគឺជាយុត្តិធម៌។

[១០:៥៦:៥៧]

ទី២) ឡុង បូរ៉េត ខ្លួនឯងត្រូវបានប្រជាជនកម្ពុជាផ្តន្ទាទោសប្រហារជីវិត បន្ទាប់ពីសម័យប្រជុំការងារសន្និបាតជាតិកាលពីថ្ងៃទី២៥ កុម្ភៈ ឆ្នាំ១៩៧៥ មក។ ចក្រពត្តិអាមេរិកពិតជាមានការភ័ន្តច្រឡំយ៉ាងខ្លាំងប្រសិនបើខ្លួននៅតែជឿថា ឡុង បូរ៉េត ចេះគ្រាន់បើជាង លន់ នល់ ដើម្បីធ្វើយ៉ាងណាឲ្យឆន្ទៈរបស់អ្នកជាតិនិយមខ្មែរក្រហមចុះខ្សោយ ហើយសូមចុះចូលជាមួយសាធារណរដ្ឋដ៏កខ្វក់របស់ខ្លួននោះ។ ថ្វីបើមិនត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយសន្និបាតជាតិរបស់ប្រជាជនកម្ពុជាក៏ដោយ ក៏ពួកជនក្បត់ជាតិដ៏អាក្រក់ជាងគេ ដូចជា ត្រង់នេះគឺសម្តេច សីហនុ បានផ្តល់ឈ្មោះប្រាំមួយនាក់ (សូមទោស) ១៦នាក់ ដែលបញ្ចប់ដោយ...។ល។”

ខ្ញុំសូមបន្តការដកស្រង់ “អ្នកទាំង១៦នេះ មានដូចជា -- អ្នកទាំង១៦នេះ ជាឧក្រិដ្ឋជនសង្គ្រាមសុទ្ធសាធ។ នៅពេលបន្ទាប់ពីក្រុងភ្នំពេញត្រូវបានរំដោះរួចហើយ ពួកគេសុទ្ធតែត្រូវឆ្លើយតបនៅចំពោះមុខតុលាការរដ្ឋ នៅរាល់អំពើអាក្រក់រាប់មិនអស់ និងឧក្រិដ្ឋកម្មដ៏សាហាវ ដែលប្រជាពលរដ្ឋ មាតុភូមិជាតិ និងរដ្ឋកម្ពុជាបានទទួលរងគ្រោះអស់រយៈពេលប្រាំឆ្នាំមកហើយ។

[១០:៥៧:៣៩]

ដោយបានប្រគល់ឋានៈជាដៃគូសន្ទនារបស់រណសិរ្សរួបរួមជាតិកម្ពុជា រដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរបស់កងកម្លាំងប្រដាប់អាវុធនៃប្រជាជន នៃរណសិរ្សរំដោះជាតិកម្ពុជាដោយជនក្បត់ហ្វាស៊ីសពុករលួយដ៏ក្រៃលែង ជាឧក្រិដ្ឋជនសង្គ្រាមដ៏ធំ និងជាឧក្រិដ្ឋជនដ៏កំសាក យោងតាមច្បាប់នោះ ចក្រពត្តិអាមេរិកធ្វើការប្រមាថមើលងាយដែលជាអំពើមិនអាចអត់ឱនឲ្យបានទៅលើវិញ្ញាណក្ខន្ធរបស់អ្នកជាតិនិយមខ្មែរទាំងប្រុសស្រីដែលបានបូជាជីវិតរបស់ខ្លួន ដើម្បីឧត្តមគតិដ៏ខ្ពង់ខ្ពស់ និងបរិសុទ្ធនៃប្រជាជនកម្ពុជា។ ខ្ញុំសូមឲ្យចក្រពត្តិអាមេរិកកាំងបញ្ឈប់ភ្លាមនូវល្បែងដ៏គួរឲ្យស្អប់ខ្ពើម ដ៏គួរឲ្យចង់សើច និងដូចក្មេងបៀមដៃនេះ។

ទី៣) រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ព្រមទាំងសម្តេចនរោត្តម សីហនុ សូមធ្វើសច្ចាប្រណិធានថា នឹងវាយប្រហារចក្រពត្តិអាមេរិករហូតដល់ក្ស័យជីវិត។ យើងសូមធ្វើសច្ចាប្រណិធានថា នឹងមិនព្រមទទួលការចរចា ឬសម្រុះសម្រួលគ្នាជាមួយចក្រពត្តិអាមេរិក និងបរិវាររបស់ពួកវាជាដាច់ខាត ដរាបណាយើងនៅមានដង្ហើម”។ សូមបញ្ចប់ការដកស្រង់។

តាមពិតទៅប្រសិនបើសេចក្ដីថ្លែងការណ៍ពាក់ព័ន្ធទៅនឹងជនក្បត់ទាំងប្រាំពីរនេះ ត្រូវបានលើកឡើងជាតម្រុយ បង្ហាញអំពីអត្ថិភាពនៃគោលនយោបាយមួយ គឺដោយសារតែជាមូលដ្ឋាននោះ ដោយមានការបកស្រាយតាមរបស់លោក ស្សូត ក្រោយពិសោធន៍។

លោក ស្សូត បានបញ្ជាក់ថា សុន្ទរកថា និងសេចក្ដីថ្លែងការណ៍ទាំងអស់ហ្នឹងមានខ្លឹមសារលាក់កំបាំង ដែលប្រាប់ទៅដល់ប្រជាជននៅតំបន់មិនទាន់រំដោះថា ប្រសិនបើពួកគេមិនចូលរួមភ្លាមៗជាមួយខ្មែរក្រហមទេ ពួកគេនឹងត្រូវចាត់ទុកថាជាជនមហាក្បត់ដែលនឹងត្រូវទទួលទោសប្រហារជីវិត។ ការបកស្រាយរបស់ ស្សូត នេះ ត្រូវបានលើកឡើងនៅថ្ងៃ -- ប៉ុន្មានថ្ងៃមុននេះ ដោយសហព្រះរាជអាជ្ញា។

[១១:00:00]

យើងសូមបញ្ជាក់ថា គឺមិនទទួលបានជោគជ័យអីទេ ការលើកឡើងនេះ។ ពីព្រោះថាសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងពាក់ព័ន្ធទៅនឹងការអំពាវនាវ នៅក្នុងសម័យសង្គ្រាមឲ្យមានការសម្លាប់ជនក្បត់ទាំងប្រាំពីរនេះ គឺថាមិនបញ្ជាក់អំពីភាពចាំបាច់សម្រាប់អ្នកដែលស្ដាប់ក្នុងចូលរួមជាមួយខ្មែរក្រហមភ្លាមៗទេ។ ក៏ប៉ុន្តែជាញឹកញាប់នោះ សារទាំងអស់នោះលើកឡើងអំពីលទ្ធភាពដែលអាចធ្វើបានតាមតម្រូវការ។

ជាក់ស្ដែងយើងគ្រាន់តែអាននូវសេចក្ដីអំពាវនាវ ឬក៏សារដែលបានផ្សព្វផ្សាយតាមវិទ្យុនោះយើងឃើញថាមានការបង្ហាញអំពីការចុះចូលតាមប្រភេទជាច្រើន។ មានការបង្ហាញអំពីការចូលគាំទ្រចលនាបដិវត្តន៍ ហើយប្ញកួរួមបញ្ចូលទាំងអំពើវិទ្ធេទកម្មៗនោះ គឺថាបញ្ជាក់ថាថារីមួយចំនួន ឧទាហរណ៍ដូចជាមន្ត្រីរដ្ឋការទាហានសាធារណរដ្ឋខ្មែរនោះ គេនៅតែមានមុខតំណែងដដែល។

ហើយនៅពេលដែលយើងអាននូវសេចក្ដីថ្លែងការណ៍ចុះហត្ថលេខាដោយលោក ខៀវ សំផន នោះគឺមានការគ្រោងឲ្យមានការចូលរួម និងតម្រូវឲ្យមានការបំបែកខ្លួនភ្លាមៗ។ យើងអាចភ្ជាប់ជាមួយនឹងចម្លើយរបស់លោក ស៊ីដនី ស្ដេនប៊ឹក នៅក្នុងសវនាការនេះដែលបានបញ្ជាក់ថា គាត់នៅភ្នំពេញ។ ដូច្នេះគាត់ដឹងច្បាស់ថា ខ្មែរក្រហមមានបណ្ដាញផ្ដល់ព័ត៌មានយ៉ាងល្អ ហើយនិងមានភ្នាក់ងារជាច្រើននៅទីក្រុងភ្នំពេញ។

[១១:0២:0៨]

បន្ទាប់មកទៀតយើងត្រូវគិតទៅលើសំណួរដែលចង់ដឹងថាតើសារទាំងអស់នេះ សារឃោសនាទាំងអស់នេះសំដៅទៅអ្នកណា? វាមិនមែនជាសារសម្រាប់ទាហានខ្មែរក្រហមដែលសហព្រះរាជអាជ្ញា

យល់ឃើញថា ត្រូវធ្វើការអនុវត្តគោលនយោបាយសម្លាប់រង្គាលនោះទេ។ ដូចលោក ស្សុត បានបញ្ជាក់រួចហើយ។ ខ្ញុំសូមដកស្រង់សម្ដីរបស់គាត់៖ "ទាហានខ្មែរក្រហមមិនស្ដាប់វិទ្យុរបស់រណសិរ្សទេ។ សារនោះគឺសម្រាប់ទៅឲ្យប្រជាជននៅទីក្រុងភ្នំពេញ"។ សូមបញ្ចប់ការដកស្រង់នូវសម្ដីរបស់ ស្សុត។

នៅពេលដែលពិនិត្យចំណុចទាំងអស់ យើងត្រូវចងចាំថា សារទាំងអស់នេះដែលពាក់ព័ន្ធទៅនឹងជនក្បត់ទាំងប្រាំពីរនេះ គឺបានផ្សព្វផ្សាយតាំងពីយូរមកហើយតាមវិទ្យុ។ ហើយព្រះរាជអាជ្ញាខ្លួនឯងក៏ជាអ្នកនិយាយដែរ។ ដូច្នេះយើងអាចសួរខ្លួនឯង ថាតើមានការរក្សានូវលក្ខណៈកាតព្វកិច្ចយ៉ាងម៉េចបានដូចតាមការស្រមើលស្រមៃរបស់ ស្សុត នោះ?

[១១:០៣:២០]

ជាចុងក្រោយនោះយើងពិនិត្យឃើញច្បាស់ថា ជាចុងក្រោយសារផ្សេងៗពាក់ព័ន្ធទៅនឹងប្រធានបទជនក្បត់ទាំងប្រាំពីរនោះ មិនមែនជាភស្តុតាងបង្ហាញអំពីចេតនារបស់ ខៀវ សំផន ក្នុងការសហការទៅនឹងការវាយប្រហារជាទូទៅ ឬក៏ជាប្រព័ន្ធសំដៅទៅលើអ្នកអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរនោះទេ។ ដូច្នេះតើសហព្រះរាជអាជ្ញាបាននិយាយអ្វីផ្សេងទៀតពាក់ព័ន្ធទៅនឹងការពិតនៃគោលនយោបាយនេះ? ដែលបើតាមសហព្រះរាជអាជ្ញានោះ គឺគ្របដណ្ដប់ទៅលើអង្គហេតុទាំងអស់ ដែលអង្គជំនុំជម្រះកំពុងតែកាត់សេចក្ដី។

ច្បាស់ណាស់ថា សហព្រះរាជអាជ្ញាព្យាយាមបង្កើតនូវអត្ថិភាពនយោបាយប្រឆាំងទៅនឹងអ្នកអតីតសាធារណរដ្ឋខ្មែរមុនទួលពោធិ៍ជ្រៃទៅទៀត។ ដូច្នេះពាក់ព័ន្ធទៅនឹងចំណុចនេះផងដែរ គឺថាអង្គហេតុនោះ គឺវាថយទៅដល់ទសវត្សរ៍ឆ្នាំ៦០ទៅទៀតឯណោះ។ នៅថ្ងៃទី១ នៃសេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាគឺថ្ងៃទី១៧ តុលា ឆ្នាំ២០១៣ លោកជំទាវសហព្រះរាជអាជ្ញាបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ហេតុការណ៍១៧ មេសា ៧៥ មិនមែនជាហេតុការណ៍ដាច់តែឯងដែលកើតនៅក្នុងសុញ្ញអាកាសនោះទេ។ វាបន្តអំពីគោលនយោបាយច្បាស់លាស់របស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការជម្លៀសចេញពីតំបន់ទីក្រុងដែលបាន -- ដែលរំដោះបាន។ ការដាក់ឲ្យក្លាយទៅជាទាសករនូវប្រជាជន។ ការសម្លាប់សមាជិករបបសាធារណរដ្ឋខ្មែរ និងសត្រូវផ្សេងទៀត។ ភស្តុតាងទាំងអស់នេះ នៅចុងទសវត្សរ៍ឆ្នាំ៦០ និងនៅដើមទសវត្សរ៍ឆ្នាំ៧០ គឺមានសារៈសំខាន់ណាស់។ ពីព្រោះវាបង្ហាញថា ហេតុការណ៍នៅខែមេសា ៧៥ គឺជាផ្នែកមួយនៃប្រព័ន្ធជាបន្តក្នុងការបង្កភាពហិង្សា ភាពសាហាវ ឃោរឃៅ និងការបង្ក្រាប ដែលបានលើកឡើងដោយជនជាប់ចោទ -- ដែលបានបង្កើតឡើងដោយជនជាប់ចោទ។

ទាំងអស់នេះ គឺមានន័យថា អ្នកទាំងអស់គ្នាត្រូវតែឈឺចាប់ ហើយនិងស្លាប់។ ភាពហិង្សានេះ គឺថាបានកើតឡើងពេញទំហឹង។ វាបានកំណត់បានអំពីអ្វីដែលពួកខ្មែរក្រហមបានចូលកាន់អំណាចហើយពួកគេបានអនុវត្តអំណាចនេះ ហើយព្យាយាមអនុវត្តអំណាចរបស់ខ្លួន ប្រឆាំងទៅអ្នកទាំងអស់ដែលមិនស្ថិតនៅក្នុងជួររបស់ពួកគេ"។ សូមបញ្ចប់ការដកស្រង់។

[១១:០៦:១៧]

លោកជំទាវសហព្រះរាជអាជ្ញាបានបន្ថែមទៀត ពាក់ព័ន្ធទៅនឹងដើមហេតុនៃអំពើហិង្សានេះ គឺថានៅការបង្កើតបក្សនៅឆ្នាំ៦០ ជាមួយនឹងការតស៊ូវណ្ណៈ និងទំនាស់ស្លាប់រស់រវាងកសិករ និងម្ចាស់ដី។ លោកជំទាវបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ទោះបីជាយ៉ាងណាក៏ដោយ ជនជាប់ចោទអះអាងថា វាមិនមែនជាការតស៊ូប្រឆាំងប្រជាជនទេ គឺប្រឆាំងនឹងប្រព័ន្ធជិះជាន់។ ដូច្នេះកុំជឿទៅលើការកុហកបែបនេះ។ មនុស្សរាប់ពាន់នាក់បានស្លាប់បន្ទាប់ពីការសម្រេចអំពាវអំនាវឲ្យការធ្វើហិង្សាបដិវត្តន៍ គឺមុនខែមេសា ៧៥។ ទស្សនៈទៅលើខ្មាំងទាំងអស់នេះ គឺផ្អែកទៅលើភាពភ័យខ្លាចជ្រៅ ជ្រាលជ្រៅ គឺថាមិនមានផ្អែកទៅលើការពិតនោះទេ។ ពួកគេរស់នៅក្នុងពិភពមួយ ដែលមានការស្អប់ខ្ពើម គុំកួនយ៉ាងខ្លាំង មិនមានភាពសមហេតុផល"។ សូមបញ្ចប់ការដកស្រង់។

បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានផ្តល់ឧទាហរណ៍ជាច្រើន ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រធ្វើទារុណកម្មដែលប្រើប្រាស់នៅក្នុងមន្ទីរ ម-១៣ ដែលដឹកនាំដោយ ឌុច។ គាត់និយាយអំពីការសម្លាប់ក្រៅផ្លូវតុលាការ។ និយាយអំពីសេចក្តីសន្និដ្ឋានរបស់ ស្បូត ដែលថាចាប់ពីឆ្នាំ៧៣មក កងកម្លាំងខ្មែរក្រហមសម្លាប់អ្នកទោសជាស្វ័យប្រវត្តិ ហើយនិងសម្លាប់អ្នកដែលបានសង្ស័យថាសហការណ៍ជាមួយនឹងពួកផ្តាច់ខ្លួន។ ហើយគាត់បានលើកឡើងអំពីការបោសសម្អាតខ្មែរ ដែលចូលពីហាណូយ នៅឆ្នាំ៧២។

[១១:០៨:១០]

បើតាមសហព្រះរាជអាជ្ញា ខៀវ សំផន មិនអាចមិនដឹងពីអ្វីដែលបានកើតឡើងនោះទេ។ ខ្ញុំសូមដកស្រង់នូវសម្តីរបស់សហព្រះរាជអាជ្ញា "គាត់ដឹងអំពីប្រវត្តិ និងវប្បធម៌របស់បក្សកុម្មុយនីស្តកម្ពុជា ហើយការសម្លាប់នោះ គឺសម្លាប់អ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំង"។ ក៏ប៉ុន្តែចំពោះយើងខ្ញុំ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញានេះ គឺមិនសមហេតុផលនោះទេ។

ចលនាខ្មែរក្រហម គឺជាចលនាតស៊ូ ជាចលនាប្រជាជន ដែលបានបង្កើតដើម្បីប្រឆាំងនឹងប្រព័ន្ធហិង្សា ប្រព័ន្ធសាហាវ ឃោរឃៅ និងការជិះជាន់គាបសង្កត់។ នេះគឺជាការពិតនៅសម័យនោះ។ ដូច្នេះ

នេះមិនមែនជាប្រវត្តិ និងវប្បធម៌របស់បក្សកុម្មុយនីស្តកម្ពុជា ដូចការអះអាងរបស់សហព្រះរាជអាជ្ញាទេ។ នេះគឺជាប្រវត្តិសាស្ត្រ និងវប្បធម៌របស់កម្ពុជាទាំងមូលតែម្តង។

សហព្រះរាជអាជ្ញាសូមឲ្យអង្គជំនុំជម្រះកុំឲ្យចាញ់បោកនឹងការកុហករបស់ខ្មែរក្រហម។ ការកុហកនេះគឺថាចំពោះយើង គឺជាការតស៊ូប្រឆាំងនឹងប្រព័ន្ធជិះជាន់នោះទេ។ ក៏ប៉ុន្តែអ្នកណាអាចបដិសេធនូវការពិតនៅទីនេះនោះ។

[១១:០៩:៤៦]

ទោះបីជាអង្គជំនុំជម្រះមិនបង្អែបង្អង់ក្នុងការវិនិច្ឆ័យនៅលើបរិបទក៏ដោយ។ យើងឃើញមានសាក្សីជាច្រើនដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ ដែលបានលើកឡើងអំពីប្រព័ន្ធជិះជាន់ដែលកើតមាននៅក្នុងរបប សីហនុ និងរបប លន់ នល់។

លើសពីនេះទៅទៀតសក្ខីកម្មក៏ត្រូវបានស្តាប់ពាក់ព័ន្ធទៅនឹង ដែលថាកសិករមិនស្អប់អ្នកទីក្រុង មិនស្អប់រដ្ឋាភិបាលភ្នំពេញទេ ហើយខ្មែរក្រហមក៏មិនមានអារម្មណ៍សងសឹកប្រឆាំងនឹងអ្នកទីក្រុងដែរ ហើយក៏មិនត្រូវបានចាត់ទុកអ្នកទីក្រុងថាជាខ្មាំងដែរ។

ឥឡូវនេះយើងពិនិត្យមើលអំពីអ្វីដែលបានឆ្លើយនៅក្នុងសវនាការនេះ។ ទី១ ពាក់ព័ន្ធទៅនឹងរបបរបស់សម្តេច សីហនុ។ របបនេះមិនមែនជារបបសន្តិភាព និងប្រជាធិបតេយ្យទេ យើងទាំងអស់គ្នាដឹងហើយ។ លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍, ដេវីដ ឆេនដ័ល័រ គាត់បានមកឆ្លើយជូនអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងភាពសាហាវឃោរឃៅរបស់របបនេះពាក់ព័ន្ធទៅនឹងការរើបម្រះរបស់អ្នកនយោបាយ។ លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ បាននិយាយនៅក្នុងសៀវភៅរបស់លោកអំពីរបបសម្តេច សីហនុ ហើយគាត់បង្ហាញអំពីភាពឃោរឃៅរបស់សម្តេច សីហនុ ចំពោះអ្នកដែលប្រឆាំងនឹងគាត់មានដូចជានិស្សិត មានអ្នកដែលម៉ៅនិយម ដែលត្រូវបានបៀតបៀន ត្រូវបានចាប់ដាក់មន្ទីរឃុំឃាំង គឺកាលពីខែ១០ ថ្ងៃ ខែមេសា -- ថ្ងៃទី ១០ ខែមេសា ២០១៣។ គឺហ្វ្រង់ស្វ័រ ប៉ុងសូដ៍ បាននិយាយអំពីរូបភាពនៃការប្រឆាំងនឹងរបបនយោបាយរបស់សម្តេចសីហនុ។

[១១:១១:៤៩]

ដូច្នេះមានការបញ្ចាំងនៅក្នុងខ្សែភាពយន្តតាមបញ្ជារបស់សម្តេច សីហនុ ហើយលោក ប៉ុងសូដ៍ ក៏បានរំឭកជូនអង្គជំនុំជម្រះអំពីរបៀបដែលសម្តេច សីហនុ បានចោទលោក ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ថាជាជនក្បត់ ហើយគាត់សម្តេច សីហនុ គាត់ដឹងច្បាស់ថា គឺមិនមែនជាការចោទប្រកាន់លេងៗ

 

ទេ។ ហើយលោក ខៀវ សំផន គាត់មានហេតុផលក្នុងការគេចខ្លួន ដើម្បីឲ្យរួចផុត -- រួចជីវិត។

ដូច្នេះយើងឃើញថារបប លន់ នល់ ក៏អ៊ីចឹងដែរមានអំពើហិង្សាយ៉ាងខ្លាំង។ មានសាក្សីជាច្រើនបានរៀបរាប់នៅសវនាការយើងនេះ លោក ហ្វ្រង់ស្វ័រ ប៉ុងស្វង់ បានពន្យល់ថា នៅពេលដួលរលំរបប សីហនុ នោះគឺមានការបាតុកម្មប្រឆាំងនឹងរបប លន់ នល់ ហើយមានការបោកគ្រាប់បែកទៅលើអ្នកដែលហ្វូងបាតុករដែលគ្មានអាវុធនោះ ហើយធ្វើឲ្យមានមនុស្សស្លាប់ជាច្រើន។

លោក ប៉ុងស្វង់ បានរៀបរាប់អំពីរបៀបដែលគេសម្លាប់មនុស្សអស់រាប់រយនាក់ដោយទាហានរបស់ លន់ នល់។ ហើយនេះគឺជាឧក្រិដ្ឋកម្មប្រឆាំង -- ឧក្រិដ្ឋកម្មសម្លាប់មនុស្សហើយនៅពេលនោះដែលមានសម្លាប់មនុស្សអស់ជាច្រើន។ គឺនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ ដែលលោកគាត់បានលើកឡើងបែបនេះនោះ។

លោក ស្សួត ក៏បានរៀបរាប់ជូនអង្គជំនុំជម្រះផងដែរថារបប លន់ នល់ នោះគឺខឹងគុំកួននឹងវៀតណាម។ ខ្ញុំសូមដកស្រង់នូវសម្ដីរបស់ ស្សួត៖ “បន្ទាប់ពីផ្ដួលរលំសម្ដេច សីហនុ មករបប លន់ នល់បានធ្វើគោលនយោបាយមួយដែលផ្ដោតទៅលើការគុំកួន គឺចេញមកពីថ្នាក់លើដែលនាំឲ្យមានការសម្លាប់ និងការនិរទេសជនជាតិវៀតណាមជាច្រើន”។ នេះគឺនៅក្នុងសវនាការថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ ទំព័រ១៦-១៧។

[១១:១៤:១១]

ទាហាន លន់ នល់ គឺមិនត្រូវគ្នាជាមួយនឹងប្រជាជនទេ ពួកគាត់មិនរស់នៅដោយមានភាពសុខដុមរមនាជាមួយប្រជាជនទេ។ ប៉ុងស្វង់ បានលើកឡើងថា៖ “បើចង់ដឹងថាតើទាហាន លន់ នល់ប្រព្រឹត្តចំពោះអ្នកភូមិយ៉ាងម៉េចនោះ ខ្ញុំអាចនិយាយពីស្ថានភាពមួយដែលថា ទាហានមួយចំនួនបានកាត់ក្បាលអ្នកភូមិ ហើយយកមកកាន់ ហើយសើចចំអកទៀតផង”។ គឺនៅក្នុងសវនាការថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ លោកប៉ុងស្វង់ គាត់បានឆ្លើយបែបនេះ។

គាត់បានរៀបរាប់អំពីការវាយចូលរបស់ទាហាន លន់ នល់ (សូមទោស) ទាហានវៀតណាមដែលចូលមកព្រំដែនកម្ពុជា និងការបង្កើតទាហានរំដោះជាតិកម្ពុជា។ គាត់ក៏បានឆ្លើយនៅក្នុងអង្គជំនុំជម្រះផងដែរ -- នៅក្នុងអង្គសវនាការផងដែរថា “អាមេរិកាំង វៀតណាម គឺជាទាហានសាហាវឃោរឃៅ ហើយពួកគេរំលោភប្រជាជនស៊ីវិល”។

[១១:១៥:១០]

លោក ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ បានលើកឡើងអំពីស្ថានភាពនៅសម័យនោះ “របៀបដែលយើងអាចសង្គ្រោះជីវិតបាន នោះគឺថាត្រូវតែទៅចូលជាមួយទាហានខ្មែរក្រហម។ ចំពោះខ្ញុំផ្ទាល់នៅក្នុងសៀវភៅកម្ពុជាឆ្នាំសូន្យរបស់ខ្ញុំ ខ្ញុំសរសេរនៅសម័យថា ខ្ញុំបានសុំអង្វរ ខ្ញុំបន់ស្រន់ឲ្យទាហានខ្មែរក្រហមចូលមក។ ក៏ប៉ុន្តែប្រជាជនបានបាត់បង់ -- ដោយសារប្រជាជនបាត់បង់ជំនឿទាំងស្រុងទៅលើរបប លន់ នល់។ ហើយសេចក្ដីសង្ឃឹមតែមួយគត់នោះគឺថា សង្ឃឹមថាខ្មែរក្រហមនឹងទទួលបានជ័យជម្នះ”។

លោក ដេវីដ ឆេនដ៍ល័រ ក៏បានបញ្ជាក់ពីចំណុចទាំងអស់នេះផងដែរនៅក្នុងតុលាការ ដោយគាត់បាននិយាយថា៖ “ទាហាន លន់ នល់ ត្រូវបានបង្កើតឡើងយ៉ាងលឿន ហើយមិនសូវមានការបណ្ដុះបណ្ដាល មិនមានការហ្វឹកហ្វឺនត្រឹមត្រូវទេ ពួកគេមានការដឹកនាំមិនបានល្អ។ ទាហាន លន់ នល់ គឺថាជាទាហានឃោរឃៅសាហាវ”។

[១១:១៦:១៦]

លោក ស៊ីដនី ស្កេនប៊ឺក បានរៀបរាប់អំពីរបៀបដែលទាហាន លន់ នល់ ដែលបានស៊ីថ្លើមរបស់គូសត្រូវ។ ចំពោះខ្មែរក្រហម ឆេនដ៍ល័រ បាននិយាយថា ខ្ញុំសូមដកស្រង់៖ “ខ្មែរក្រហមមានវិន័យច្រើនជាង។ ពួកគេមិនសម្លាប់ មិនប្រព្រឹត្តអំពើខុសនៅក្នុងភូមិទេ ហើយពួកគេមានក្រមសីលធម៌តាមបែបសាសនា។ ចំណុចនេះហើយ ដែលធ្វើឲ្យពួកគេមានប្រជាប្រិយជាមួយប្រជាជន”។ នេះគឺសវនាការនៅក្នុងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ទំព័រ៧៣។

ចំណុចនេះក៏ត្រូវបានបញ្ជាក់អះអាងដោយលោកឪពុក ប៉ុងស្វដ៍ ផងដែរ នៅពេលដែលគាត់លើកឡើងអំពីសក្ខីកម្មរបស់សាក្សីមួយចំនួនដែលបានលើកឡើងថា ទាហានខ្មែរក្រហមគឺជាទាហានចិត្តល្អ រួសរាយ ជួយប្រជាជន ចេះជួយយកអសារប្រជាជន ជួយដាំស្រូវឲ្យប្រជាជន។

[១១:១៧:២២]

យើងក៏បានស្ដាប់ឮអំពីការនិយាយអំពីហិង្សារបស់របប លន់ នល់ ហើយនិងអំពើពុករលួយនៅសម័យ លន់ នល់។ ពីព្រោះនេះជាលក្ខណៈសម្គាល់ដ៏សំខាន់នៃរដ្ឋាភិបាល លន់ នល់ ដែលជារដ្ឋាភិបាលពុករលួយ។ ហើយយើងមានឯកសារជាច្រើននៅក្នុងសំណុំរឿងដែលបង្ហាញពីចំណុចនេះ។

លោក ស៊ីដនី ស្កេនប៊ឺក នៅក្នុងសវនាការយើងនេះបានបញ្ជាក់ថា៖ “ភាពអមនុស្សធម៌ ភាពពុករលួយបានធ្វើឲ្យប្រជាជនក្ដៅក្រហាយ និងខឹងសម្បាយ៉ាងខ្លាំង”។ ដូច្នេះហើយខ្ញុំសូមដកស្រង់៖ “និស្សិតគ្រូមួយចំនួនបានចូលព្រៃតស៊ូ ដើម្បីចូលរួមជាមួយអ្នកបះបោរ តស៊ូប្រឆាំងនឹងរបប លន់ នល់”។

ហើយគាត់ក៏បានបញ្ជាក់ផងដែរថា៖ "អំពើពុករលួយគឺជាមូលហេតុសំខាន់នៃការធ្លាក់ចុះប្រជាប្រិយភាពរបស់រដ្ឋាភិបាល លន់ នល់"។ សូមបញ្ចប់ការដកស្រង់។

អំពើពុករលួយទាំងអស់នេះ គឺជាប្រភពដ៏ល្អដែលធ្វើឲ្យខាងទាហានអាមេរិកផ្ដល់ជំនួយជាច្រើន។ លោក ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ បានបញ្ជាក់ផងដែរថា៖ "មន្ត្រីរដ្ឋាភិបាល លន់ នល់ មួយចំនួនបានលក់ស្រូវអង្ករ លក់អាវុធទៅឲ្យខ្មែរក្រហម"។ គាត់ថា៖ "រដ្ឋាភិបាល លន់ នល់ នឹងដួលរលំដោយខានមិនបាន"។

គេនិយាយអំពីគោលនយោបាយឲ្យមានការស្អប់ខ្ពើមពីសំណាក់កសិករ ប្រឆាំងនឹងអ្នកទីក្រុង។ នៅក្នុងសៀវភៅរបស់លោក ឆេនដ៍ល័រ ហើយនៅក្នុងសវនាការគាត់បានបញ្ជាក់ថា៖ "ប្រជាជនរតនគិរី និងមណ្ឌលគិរី កាន់តែខឹងខ្លាំងជាមួយនឹងរដ្ឋាភិបាលភ្នំពេញពាក់ព័ន្ធទៅនឹងការសាងសង់ផ្លូវ ដែលយកដីរបស់គាត់ ហើយនិងការយកធ្វើចម្ការកៅស៊ូធ្វើឲ្យពួកគាត់មានការតស៊ូប្រឆាំង"។ បន្ទាប់មកទៀត លោក ប៉ុងស្វដ៍ បាននិយាយពីលក្ខណៈមនោគមន៍វិជ្ជា ឬក៏អត់ពីអ្វី ដែលបានកើតឡើងនៅប្រទេសកម្ពុជាក្នុងសម័យនោះ។

[១១:២០:០០]

ផ្ទុយពីអ្វីដែលអះអាងដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី បើតាមពួកគាត់ គឺថាមិនមានការសងសឹកជាមួយនឹងប្រជាជនទីក្រុងទេ។ ខ្ញុំសូមដកស្រង់នូវសម្ដីលោក ប៉ុងស្វដ៍ គឺថា៖ "មិនមែនជាការគុំកួនជាមួយនឹងអ្នកទីក្រុងរបស់កសិករទេ។ នេះគឺជាមនោគមន៍វិជ្ជា គឺការគុំកួនសងសឹកនេះប្រហែលជាអាចត្រូវបានប្រើដោយខ្មែរក្រហម ដើម្បីបម្រើឲ្យមនោគមវិជ្ជារបស់ខ្លួន ក៏ប៉ុន្តែពួកគេគឺធ្វើម៉េចកសាងសង្គមកុំឲ្យមានអ្នកមាន កុំឲ្យមានពួកកុំប្រាឌ័រ"។

ជាចុងក្រោយ នៅពេលយើងពិនិត្យមើលទៅលើធាតុផ្សំទាំងអស់នេះ ដែលបានបង្ហាញជូនដល់អង្គជំនុំជម្រះ ដោយគ្មានផលប្រយោជន៍ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញានោះ យើងមានអារម្មណ៍ថា អ្នកទាំងអស់នេះ គឺកំពុងតែបដិសេធប្រវត្តិសាស្ត្រកម្ពុជាហើយ។ ពួកគាត់អះអាងថា មុនខែមេសា -- ថ្ងៃទី១៧ មេសា ៧៥ នោះគឺស្ថានភាពល្អណាស់ ហើយប្រសិនបើខ្មែរក្រហមមិនចូលមកដោយមានចេតនាទុច្ចរិត ចេតនាអាក្រក់ទេ គឺថាស្ថានភាពនៅកម្ពុជា គឺល្អប្រសើរណាស់។ នេះគឺជាទស្សនៈខុសទាំងស្រុង គឺថាវាមិនត្រូវទៅតាមប្រវត្តិសាស្ត្រនៃកម្ពុជាទេ។ នេះគឺជាបដិសេធអំពីការពិតដែលសហព្រះរាជអាជ្ញាគាត់ប៉ានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់គាត់ ដែលគាត់បន្ទោសខ្មែរក្រហមថា បានធ្វើសង្គ្រាមប្រឆាំង លន់ នល់ រហូតដល់ធ្វើឲ្យរបបនេះដួលរលំ។

[១១:២១:៥៥]

គេបានលើកឡើងថា ពួកគេអាចយកទីក្រុងភ្នំពេញបានដោយមិនមានការទម្លាក់គ្រាប់បែកដោយមិនមានការកាត់ផ្តាច់ជាប្លុកៗ។ ហើយបើយើងស្តាប់សម្តីរបស់លោកជំទាវសហព្រះរាជអាជ្ញា នោះគឺថា នេះគឺជាកំហុសរបស់ខ្មែរក្រហមដែលធ្វើឲ្យប្រជាជននៅទីក្រុងភ្នំពេញ -- ប្រជាជនទីក្រុងភ្នំពេញអត់ឃ្លាននោះ គឺដោយសារខ្មែរក្រហមបានកាត់ផ្តាច់ទីក្រុងមិនឲ្យមានការផ្គត់ផ្គង់ស្បៀង។ នេះជាការលើកឡើងរបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានបដិសេធប្រវត្តិសាស្ត្រកម្ពុជា បដិសេធបរិបទប្រវត្តិសាស្ត្រនៃសំណុំរឿងរបស់យើង។ គាត់មិនបានឈានដល់ការអះអាងថា ដល់ថ្នាក់ថាទម្លាក់របប លន់ នល់ តាមរយៈការបោះឆ្នោតនោះទេ។ ទោះបីជាអង្គជំនុំជម្រះមិនកាត់សេចក្តីមុនឆ្នាំ៧៥ ក៏ដោយក៏មិនមែនមានន័យថា អង្គជំនុំជម្រះទទួលយកនូវគំនិតខុសពីការពិត ដែលបានរៀបចំនិងច្នៃប្រឌិតឡើងដោយសហព្រះរាជអាជ្ញា ដើម្បីបម្រើឲ្យប្រយោជន៍របស់ខ្លួននោះដែរ។

[១១:២៣:១១]

បាទ ហើយនៅទីបញ្ចប់ មុននឹងបញ្ចប់បទបង្ហាញខ្ញុំនេះ។ បាទ ដោយសារព្រះរាជអាជ្ញាចូលចិត្តយោងទៅលើអ្វីដែលនៅក្រៅវិសាលភាពនៃអង្គជំនុំជម្រះ ខ្ញុំនឹងក៏បានទៅពិគ្រោះឯកសារមួយ ហើយខ្ញុំសូមឲ្យយោងទៅឯកសារនេះ។ គឺឯកសារទង់បដិវត្តខែកញ្ញា ឆ្នាំ១៩៧៧ E3/11 ដែលនៅក្នុងនោះមានអត្ថបទដ៏វែងមួយនិយាយអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ នៅពេលដែលយើងអានអត្ថបទនេះ គឺថាយើងគឺមើលទៅឃើញថា បក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានអំពើហិង្សាណាស់។ ក៏ប៉ុន្តែយើងពិបាកនឹងទទួលយកបាន។ នៅក្រោមរបប សីហនុ មុនឆ្នាំ១៩៧០ គឺកសិករដែលបង្កឲ្យមានបដិវត្តន៍ ហើយលេខអត្ថបទទង់បដិវត្តនេះ សរសេរដូចតទៅនេះ៖

បាទ ខ្ញុំសូមដកស្រង់៖ “គោលបំណងរបស់យើងមិនមែនចង់ប្រឆាំងនឹងមនុស្សទេ បុគ្គលទេ ក៏ប៉ុន្តែរបបជិះជាន់ដោយផ្ទាល់ គឺរបស់សក្តិភូមិ ហើយនិងរបបម្ចាស់ដី”។ បដិវត្តន៍នោះកើតចេញពីប្រជាកសិករ ហើយគេបានព័ទ្ធប៉ុស្តិ៍ប៉ូលិស ទីបញ្ជាការ ហើយដោយប្រើកាំបិត ខ្វែវ ដំបង ហើយគេបានអនុវត្តអំពើហិង្សាបដិវត្តន៍នេះ ពីព្រោះថាគេមិនបានទទួលបាននូវអ្វីដែលគេត្រូវទទួលបាន គេរឹបអូសរបស់គេ។ អ៊ីចឹងកាលយល់ ឧត្តមគតិបដិវត្តន៍នេះ គឺថាគេធ្វើទទួលបានតាមរយៈការតស៊ូ ហើយតាមអំពើហិង្សាវណ្ណៈ ហើយនិងតាមគូបដិបក្ខវណ្ណៈដែលមិនអាចផ្សះផ្សាគ្នាបាន។

[១១:២៥:០៨]

ការពិតនៃចលនាខ្មែរក្រហមនោះ ហើយចលនាតស៊ូប្រឆាំងទៅនឹងការគាបសង្កត់ ការពិតនេះនៃសហព្រះរាជអាជ្ញាសុំឲ្យអស់លោក លោកស្រីចៅក្រមកុំគិតពីការពិតនេះ ដើម្បីឲ្យទៅជឿគាត់ ជារឿងប្រឌិតរបស់គាត់នោះ គឺថាអ្នកណាក៏ដោយ ដែលពេលគេពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងនេះមិនអាចគាំទ្រព្រះរាជអាជ្ញាបានទេ។ អ៊ីចឹងខ្ញុំសូមឲ្យអស់លោក លោកស្រីចៅក្រមបដិសេធរឿងប្រឌិតនេះចោលទៅ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំបន្ត ខ្ញុំសូមនិយាយអំពីសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយដែលថាមានការចូលរួមក្នុងសេចក្ដីសម្រេចរបស់លោក ខៀវ សំផន។ យើងដឹងថាការជម្លៀសហ្នឹងកើតមាននៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ហើយក៏ប៉ុន្តែពុំមានឯកសារកាលពីសម័យនោះដែលនិយាយអំពីការបរិច្ឆេទណាមួយ ដែលថាគេសម្រេចជម្លៀសនោះទេ។

[១១:២៦:៤៥]

ក្នុងដីកាដំណោះស្រាយ នៅកថាខណ្ឌ២៥១ កត់សម្គាល់ថាបើតាមសក្ខីកម្មមួយចំនួនសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ ប្រហែលជាធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ៧៥។ ហើយកាលបរិច្ឆេទដដែលនេះឯង ដែលទទួលយកដោយអ្នកជំនាញ ឆេនដ័ល័រ ឯកសារ E3/1686 ហើយគឺកាលបរិច្ឆេទដដែលនេះហើយ ដែល ប៉ុល ពត បានប្រាប់ដែរនៅក្នុងសន្និសីទកាសែតមួយនៅទីក្រុងប៉េកាំង ឆ្នាំ១៩៧៧ គឺឯកសារ E3/2072។

ខាងព្រះរាជអាជ្ញាគេយល់ឃើញខុសពីនេះ។ ជាបឋមគឺគេផ្អែកទៅលើសក្ខីកម្មតែមួយគត់របស់ ភី ភួន ដែលយើងនឹងនិយាយអំពីសក្ខីកម្មគាត់នេះនៅពេលក្រោយ ដើម្បីកំណត់កាលបរិច្ឆេទនៅដើមខែមេសា ឆ្នាំ១៩៧៥ ហើយតាមពេលកន្លងផុតមកទៅនេះ គឺថាព្រះរាជអាជ្ញាបានលើកឡើងថា ការសម្រេចនេះគឺថាធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៧៤ទេ នៅក្នុងទីបញ្ជាការរបស់ ប៉ុល ពត នៅក្បែរឧដុង្គ។

[១១:២៨:១០]

ហើយនៅក្នុងចំណោមឯកសារដែលសហព្រះរាជអាជ្ញាប្រើប្រាស់ហ្នឹងមានទង់បដិវត្ត កញ្ញា ឆ្នាំ១៩៧៧ យើងបានលើកឡើងអំពីខ្លឹមសារនៃទង់បដិវត្តនេះហើយក្នុងសវនាការយើងនេះជាច្រើន ដែលមានសរសេរដូចតទៅនេះ គឺឯកសារ E3/11 សមាជគណៈមជ្ឈិមកើតឡើងក្នុងរយៈពេល១៥ថ្ងៃ នៅខែ

មិថុនា ឆ្នាំ១៩៧៤។ ហើយដែលនៅក្នុងនោះមាននិយាយ សូមដកស្រង់៖ “ការវាយប្រហារផ្តាច់ព្រ័ត្រដើម្បីរំដោះទីក្រុងភ្នំពេញ និងប្រទេសទាំងមូលតែម្តង”។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ នេះជាចំណុចល្អណាស់ ជាចំណុចសំខាន់ណាស់ដែលពន្យល់អំពីភាពខុសគ្នានៃយោបល់ ហើយនិងសក្ខីកម្មផ្សេងៗនៅទីនេះ។ ព្រោះថាលេខពិសេសនេះមិនមានប្រើពាក្យ “ជម្លៀស” ណាមួយទេ មានតែនិយាយអំពីការវាយផ្តាច់ព្រ័ត្រតែប៉ុណ្ណឹងឯង។

ចំណុចមួយទៀតដែលអស់លោក លោកស្រីចៅក្រមមានដែរនោះ គឺចម្លើយរបស់លោក នួន ជា។ លោក នួន ជា ចាំថាគាត់បាននិយាយនៅទីនេះថ្ងៃទី១៤ ធ្នូ ឆ្នាំ២០១១ គាត់និយាយថា៖ “មានកិច្ចប្រជុំមួយនៃគណៈអចិន្ត្រៃយ៍ ហើយនិងសមាជិកមួយចំនួននៃគណៈមជ្ឈិមនៅពាក់កណ្តាលឆ្នាំ៧៤”។ ក៏ប៉ុន្តែអ្វីដែលលំបាកនោះ គឺថាការរៀបរាប់របស់លោក នួន ជា មិនមានបញ្ជាក់ពីថ្ងៃណាច្បាស់លាស់នៃសមាជគណៈអចិន្ត្រៃយ៍នេះទេ។ គាត់គិតថាកិច្ចសមាជនេះប្រព្រឹត្តទៅរយៈពេលបីថ្ងៃ។

[១១:៣០:០១]

ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោក នួន ជា នេះអ្វីដែលគួរចាប់អារម្មណ៍នោះគឺថា ខៀវ សំផន មិនមានវត្តមានទេនៅក្នុងកិច្ចប្រជុំហ្នឹង ហើយគាត់ពន្យល់មូលហេតុ។ គឺសវនាការថ្ងៃទី១៤ ធ្នូ ដដែល ទី១៤ ២០១១។ គាត់និយាយថា៖ “ក្រៅពីសមាជិកគណៈអចិន្ត្រៃយ៍ មានសមាជិកគណៈមជ្ឈិមមួយចំនួនដែលមានវត្តមាន”។ គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “អ្នកដែលត្រូវផ្សព្វផ្សាយព័ត៌មាននេះនៅក្នុងភូមិភាគរបស់ខ្លួន ហើយត្រូវតែបញ្ជូនសេចក្តីសម្រេចនេះទៅភូមិភាគរបស់ខ្លួន”។ នេះមានចំណុចសំខាន់មួយ គាត់ពន្យល់ថា ខៀវ សំផន មិនបាននៅក្នុងកិច្ចប្រជុំនេះទេ។ គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “គឺលេខាភូមិភាគហ្នឹងត្រូវសម្រេចថាអ្នកណាចូលរួមប្រជុំ”។ សូមបញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកទៀត គាត់លើកឡើងថា៖ “អវត្តមានរបស់លោក ខៀវ សំផន នោះគឺដោយសារដែលគាត់មិនមានផ្សាភ្ជាប់អីទៅនឹងភូមិភាគទេ”។ សូមបញ្ចប់កាដកស្រង់។ ហើយគាត់ក៏ពន្យល់ផងដែរថា “ខៀវ សំផន ជាបញ្ញវន្ត ដូច្នេះគឺ ប៉ុល ពត ទេ ជាអ្នកចាត់ចែងការងារទាំងអស់នេះ”។ ហើយក៏គាត់បានបញ្ជាក់ផងដែរគឺ ប៉ុល ពត សូមដកស្រង់៖ “ដែលជាអ្នកសម្រេចចំនួនអ្នកដែលចូលរួមប្រជុំ អាស្រ័យទៅតាមតម្រូវការនៃស្ថានភាព”។

[១១:៣១:៤១]

អ៊ីចឹងវាមានភាពសមហេតុសមផលនៅក្នុងចម្លើយរបស់ នួន ជា ដើម្បីពន្យល់ថា ហេតុអ្វីបាន

ជា ខៀវ សំផន មិនមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ? ហេតុអ្វីបានជាកិច្ចប្រជុំនេះមានរយៈពេលបីថ្ងៃ? ហើយវាទាក់ទងតែសមាជិកគណៈអចិន្ត្រៃយ៍ទេ ហើយនិងសមាជិកគណៈមជ្ឈិមមួយចំនួនដែលមានទំនួលខុសត្រូវលើភូមិភាគ។

ចំពោះបញ្ហានេះ យើងមានសាក្សីសំខាន់មួយរបស់សហព្រះរាជអាជ្ញាគឺលោក ភី ភួន, រ៉ាចម តុន ហៅ ភី ភួន។ គាត់បានមកផ្ដល់សក្ខីកម្មនៅទីនេះ។ គាត់បាននិយាយថា "ខៀវ សំផន មានវត្តមាននៅទីបញ្ជាការ ប៉ុល ពត នៅខែមេសា ឆ្នាំ១៩៧៥។ ហើយគាត់យល់ស្របនឹងសេចក្ដីសម្រេចជម្លៀសប្រជាជន"។ នេះគឺលោក ភី ភួន នេះពូកែនិយាយណាស់។ លោកប្រធាន ខ្ញុំចង់និយាយថា មិនចង់និយាយថា គាត់និយាយការពិតណាស់ គ្រាន់តែនិយាយថា គាត់ចូលចិត្តនិយាយ។

លោក ភី ភួន នេះ គឺជាប្រភពនៃការស្រាវជ្រាវច្រើនណាស់ នៅពេលដែលយើងសួរសំណួរទៅស្ទួត។ យើងដឹងថា គាត់ហ្នឹងជាប្រភពសំខាន់នៃសៀវភៅរបស់លោក ហ្វីលីព ស្ទួត។ ភី ភួន នៅពេលដែលអ្នកស៊ើបអង្កេតសម្ភាសគាត់ គាត់បាននិយាយថា និយាយអំពីកិច្ចប្រជុំនៅឆ្នាំ១៩៧៥ ដែលមានរយៈពេលច្រើនថ្ងៃ ដោយមិនបានពិពណ៌នាជាក់លាក់ទេ។ កិច្ចប្រជុំនុ៎ង ដែលគាត់ថាមានការសេចក្ដីសម្រេច គឺនៅដើមឆ្នាំ -- ដើមខែមេសា ឆ្នាំ១៩៧៥ នៅប-៥។ ហើយ ភី ភួន គាត់ឆ្លើយរហូតនៅក្នុងហ្នឹង គាត់នៅតែបែងចែកកិច្ចប្រជុំពីរហ្នឹងដាច់ពីគ្នា។

[១១:៣៣:៣៦]

នៅថ្ងៃទី២៣ កក្កដា ឆ្នាំ២០១២ នៅពេលដែលសហព្រះរាជអាជ្ញាចង់បង្ហាញឲ្យវាមានភាពស៊ីសង្វាក់គ្នា សួរថា៖ "តើការប្រជុំទី១ នៅឆ្នាំ១៩៧៤ តើមានបានពិភាក្សាពីបញ្ហានេះទេ នៅក្នុងកិប្រជុំហ្នឹងទេ?" ភី ភួន ឆ្លើយថា៖ "ទេ ខ្ញុំគិតថា អត់មានទេ"។ ហើយគាត់ឆ្លើយនេះ ដាច់អហង្ការ គាត់ច្បាស់ណាស់ គាត់បែងចែកពីកិច្ចប្រជុំពីរហ្នឹង។ កិច្ចប្រជុំទី១ អត់មាននិយាយពីរឿងជម្លៀសទេ។

សហព្រះរាជអាជ្ញា គេបានសង្កត់បន្ថែមទៀត។ នៅពេលដែល -- ទោះបីជាគេខំបោះព្រុយយ៉ុងប្រាប់ទៅគាត់ថា នៅកិច្ចប្រជុំទី១ ដែលថាមានរយៈពេល១៥ថ្ងៃ រឿងសមាជិកហ្នឹង ប្រហែលជាអាចលើកនិយាយពីរឿងជម្លៀសដែរនោះ។ គាត់ឆ្លើយនៅតែដាច់ណាត់ដដែល គឺនៅឆ្នាំ២០១២ថ្ងៃហ្នឹង គាត់ថា "ខ្ញុំបានឮនិយាយពីរឿងជម្លៀសហ្នឹងតែម្ដងនៅប-៥។ ខ្ញុំអត់មានព័ត៌មានលម្អិតអីទេ ទាក់ទងនឹងការជម្លៀសហ្នឹង"។ សូមបញ្ចប់ការដកស្រង់។

[១១:៣៤:៤៤]

នៅពេលដែលគាត់និយាយអំពីការពិភាក្សាលើការជម្លៀសហ្នឹងដដែល ដែលថាដែលនិយាយនៅក្នុងកិច្ចប្រជុំទី២ គឺដើមខែមេសា ឆ្នាំ១៩៧៥ លោក ភី ភួន និយាយលើសពីហ្នឹង។ គាត់ថា៖ “អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹងបាននិយាយអំពីការជម្លៀសទីក្រុង ក៏ប៉ុន្តែគេមិនបានផ្តល់ព័ត៌មានលម្អិតទេនៅពេលប្រជុំនោះនោះ”។ ក្រោយមកទៀតគាត់បញ្ជាក់ថា៖ “ព័ត៌មានលម្អិតដ៏តិចតួចនោះក៏មិនត្រូវបានលើកឡើងដែរ”។ សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងទោះជាយើងជឿ ឬមិនជឿក្តី ភី ភួន ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ទោះបីជាការជម្លៀសនេះប្រហែលជាទំនងជាត្រូវបានសម្រេចនៅខែមេសា ឆ្នាំ១៩៧៤ ដោយមានវត្តមានលោក ខៀវ សំផន ដែលលោក ខៀវ សំផន ជំទាស់។ ក៏យើងមិនបាននិយាយអំពីមធ្យោបាយក្នុងការអនុវត្តដែរ ហើយនៅពេលដែលយើងត្រូវពិភាក្សាអំពីការដែលថាតើ ខៀវ សំផន បានចូលរួមក្នុងការអនុវត្តការជម្លៀសនេះដែរឬអត់?

[១១:៣៥:៥៤]

បើសិនជាយើងពុំមានធាតុផ្សំថា ការអនុវត្តការជម្លៀសនេះត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំនោះ តើយើងអាចជាការសន្និដ្ឋានថាគាត់យល់ស្របនឹងការជម្លៀសនេះ ឬក៏អនុវត្តការជម្លៀសនេះយ៉ាងម៉េច។ អ៊ីចឹងខ្ញុំសូមលើកបញ្ហានេះឡើងដើម្បីឲ្យលោកតុលាការពិចារណា។

ក៏ប៉ុន្តែបញ្ហាគឺថា ចម្លើយរបស់លោក ភី ភួន នេះវាមានចោទជាបញ្ហា។ ទី១ គឺថា ភី ភួន មិនបានចូលរួមក្នុងកិច្ចប្រជុំនេះទេ។ យើងត្រូវចាំទាំងអស់គ្នាគឺ ភី ភួន គាត់គ្រាន់តែជាកងសន្តិសុខទេ កងការពារទេ គាត់បានប្រាប់យើងហើយនៅទីនេះស្រាប់។ សូមដកស្រង់៖ “ខ្ញុំមិនបានចូលរួមក្នុងកិច្ចប្រជុំនេះទេ ពីព្រោះខ្ញុំជាអ្នករក្សាសន្តិសុខនៅខាងក្រៅទេ ក៏ប៉ុន្តែទន្ទឹមនឹងនោះខ្ញុំឮគេនិយាយដែរ”។

ក៏ប៉ុន្តែ -- នេះត្រង់ចំណុចនេះ យើងត្រូវតែត្រឡប់ទៅក្រោយវិញនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅកាលពីឆ្នាំ២០០៨ លោក ភី ភួន បាននិយាយថាគាត់បានឮអ្វីដែលគេនិយាយពីព្រោះនៅក្នុងកិច្ចប្រជុំហ្នឹង ពីព្រោះថាគាត់នៅក្រោយជញ្ជាំងស្លឹកមួយដែលគេប្រជុំនៅខាងក្រោយជញ្ជាំងហ្នឹងគេប្រជុំ។

[១១:៣៧:១៥]

នៅក្នុងសវនាការនេះស្រាប់តែគាត់និយាយផ្សេងវិញ គាត់និយាយថា គាត់ឮគេនិយាយនៅក្នុងកិច្ចប្រជុំហ្នឹងនៅខែមេសា ឆ្នាំ១៩៧៥ នោះ ពីព្រោះគាត់នៅក្រោយដំបូកទេ ដំបូកមួយ។ អ៊ីចឹងនៅពេល

ដែលគាត់សួរ -- យើងសួរគាត់ទាក់ទងទៅនឹងភាពផ្ទុយគ្នានេះ ចម្រូងចម្រាសនេះ គាត់ឆ្លើយដូចតទៅនេះ សូមដកស្រង់៖ "អ៊ីចឹងអស់លោក លោកស្រីចៅក្រមយកពាក្យសម្ដីខ្ញុំយ៉ាងម៉េចក៏យកទៅ"។ អ៊ីចឹងបានន័យថាគាត់មិនចង់ឆ្លើយតបទៅនឹងខាងការពារក្ដីអ៊ីចឹង។ ហើយនៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ សួរគាត់ម្ដងទៀត សួរព័ត៌មានលម្អិតទាក់ទងនឹងកិច្ចប្រជុំហ្នឹងដែរនោះ គាត់ឆ្លើយដូចតទៅនេះ សូមដកស្រង់៖ "ខ្ញុំមិន -- ខ្ញុំគិតថាខ្ញុំមិនចង់ឆ្លើយនឹងសំណួរនេះទេ ពីព្រោះថាខ្ញុំមិនចង់និយាយជាន់កែងឯងទេ"។ បើយ៉ាងហោចណាស់ក៏ខ្ញុំចង់ -- គឺបើថានៅពេលដែលចប់សវនាការហ្នឹងៗ លោក វ៉ាម តុន ហៅ ភី ភួន នោះគាត់ក៏ប្រញាប់ទៅជួបអ្នកកាសែត ហើយឆ្លើយប្រាប់កាសែតខេមបូខាដេលីថាៗ ថាគាត់ដូចជាវង្វេងវង្វាន់អស់ហើយនៅក្នុងសវនាការនេះ។

[១១:៣៨:៣៧]

លោកប្រធាន អស់លោក លោកស្រីចៅក្រម សក្ខីកម្មដ៏សំខាន់របស់សហព្រះរាជអាជ្ញានេះ ទាក់ទងទៅនឹងការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងកិច្ចប្រជុំដែលមានការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះមានលក្ខណៈយ៉ាងដូច្នេះឯង។

ការពិភាក្សាទាក់ទងទៅនឹងកាលបរិច្ឆេទមានបញ្ហាមួយចំនួនដែរ ហើយសហព្រះរាជអាជ្ញាបានត្រឡប់មកនិយាយពីរឿងនេះ ដើម្បីព្យាយាមចង់ដឹងថា អ្នកជំនាញ ឆេនដ័ល័រ ហ្នឹងសួរថាតើខែកុម្ភៈ ឆ្នាំ ១៩៧៥ ហ្នឹងត្រឹមត្រូវដែរឬទេ? នៅក្នុងសវនាការនេះលោកបានរក្សាចម្លើយនេះ។ ហើយក្រោយមកគាត់បានបញ្ជាក់ថា សូមដកស្រង់៖ "សេចក្ដីសម្រេចជម្លៀសទីក្រុង ដែលធ្វើដោយអ្នកដឹកនាំរបស់អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមុន មេសា ១៩៧៥។ ក៏ប៉ុន្តែធ្វើដោយមេទាហានទេ ហើយធ្វើដោយសម្ងាត់ គឺជាសេចក្ដីសម្រេច--"។

[១១:៣៩:៥៣]

ហើយមានអ្នកជំនាញផ្សេងដែរមកកន្លែងនេះក៏គេរក្សាថា ចម្លើយនេះដែរ បញ្ជាក់អំពីចម្លើយកាលបរិច្ឆេទនេះដែរ។ នៅសវនាការនៅឆ្នាំ២០១៣ នេះមានសាក្សីមួយនិយាយពីកិច្ចប្រជុំមួយដែល សុន សេន ជាអ្នកដឹកនាំកិច្ចប្រជុំមុននឹងការវាយសម្រុកចុងក្រោយ គឺសាក្សី អ៊ុង រ៉ែន។ មានចំណុចទី៣ ក្នុងចំណោមចំណុច ដែលបានលើកឡើងទាំងអស់ហ្នឹង។ ខ្ញុំសូមដកស្រង់៖ "ប្រសិនបើយើងអាចឈ្នះនោះយើងត្រូវធ្វើយ៉ាងណា ដើម្បីរំដោះទីក្រុងឲ្យបានវាយលុក"។ ក៏ប៉ុន្តែគាត់មិនបាន -- គាត់និយាយតែរឿងវាយលុកដើម្បីដណ្ដើមយកដីទេ គាត់មិនបាននិយាយអំពីការជម្លៀសទេ។

សាក្សីមួយទៀតឈ្មោះ ស៊ុម ធី (*ស៊ីក*) សវនាការ ២០១២ ថ្ងៃទី០៥ វិច្ឆិកា។ គាត់និយាយថា ៖ “យើងមិនបានទទួលសេចក្ដីណែនាំអ្វីទេ គេឲ្យយើងវៃដើម្បីដណ្ដើមយកទីក្រុងភ្នំពេញឲ្យបាន ហើយក្រោយដែលយើងវៃបានភ្នំពេញហើយនោះ បានគេប្រាប់ឲ្យយើងជម្លៀសប្រជាជន”។ សូមបញ្ចប់ការដកស្រង់។

[១១:៤១:០៨]

ហើយត្រង់ចំណុចនេះ អ៊ីចឹងគោលជំហររបស់ នួន ជា ហ្នឹងមាន ខ្លឹមសារព្រោះថាបើមានមនុស្សដ៏តិចតួចដែលដឹងអំពីរឿងសេចក្ដីសម្រេចជម្លៀសនេះ។ បើសិនជាការបញ្ជាផ្នែកយោធានោះមិនត្រូវបានឲ្យភ្លាមៗទេ អ៊ីចឹងក៏អត់មានការនិយាយប្រាប់ឲ្យគេដឹងពីការជម្លៀសនេះទេ។ អ្នកដែលគេបានធ្វើសេចក្ដីសម្រេចនោះ គេធ្វើសេចក្ដីសម្រេចនេះ គេនៅរក្សាការសម្ងាត់ ហើយគេបានប្រាប់ហើយថាធ្វើដោយសម្ងាត់។

អ្នកជំនាញមួយទៀតគឺលោក ស្បួត គាត់បានកំណត់កាលបរិច្ឆេទថា សេចក្ដីសម្រេចជម្លៀសនេះនៅក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា “ប៉ុល ពត៖ សុបិនអាក្រក់”។ គាត់និយាយថាប្រហែលខែកញ្ញា ឆ្នាំ១៩៧៤ ពេលដែលយើងសួរគាត់ពីប្រភពនោះ ថាគាត់ -- គាត់និយាយថា ភី ភួន អ្នកប្រាប់គាត់ ហើយ ភី ភួន៖ “ប្រហែលច្រឡំកាលបរិច្ឆេទហើយ” ដែលគាត់ដែលបាននិយាយនៅទីនេះផងដែរថា “គេមិនបាននិយាយពីការជម្លៀសមុនខែមេសា ឆ្នាំ១៩៧៥ ទេ។ ភី ភួន និយាយអ៊ីចឹង។

[១១:៤២:២៥]

ដូច្នេះនេះហើយសាក្សីសំខាន់ ដែលយើងយកមកគិតហ្នឹងទាក់ទងទៅនឹងការចូលរួមរបស់លោក ខៀវ សំផន ក្នុងការសម្រេចជម្លៀសហ្នឹង។ វាមានបញ្ហាមួយចំនួន ដែលចោទឡើងថាដើមខែមេសា ឆ្នាំ៧៥ មុនពេលវាយផ្ដាច់ចុងក្រោយនោះ យើងថាពេលហ្នឹងយើងថាត្រូវប្រមូលមេបញ្ជាការទាំងអស់នៅក្នុងកន្លែងតែមួយ ដោយទុកឲ្យកូនទាហានហ្នឹងអត់មានមេកើយ ឬក៏យ៉ាងម៉េច? អានេះជាបញ្ហា។

អ៊ីចឹងសក្ខីកម្មរបស់លោក ភី ភួន នេះមិនត្រឹមតែថាមានភាពចម្រូងចម្រាសទេ ហើយដោយមិនគិតរឿងថាគាត់ជំទាស់មិនព្រមឆ្លើយសំណួរទេ ក៏ប៉ុន្តែមានសក្ខីកម្មរបស់អ្នកកងការពារផ្សេងៗទៀតរបស់ ប៉ុល ពត នៅកន្លែងទីបញ្ជាការហ្នឹងដែរ ដូចជាលោក សាឡុត បាន ជាដើមដែលជាក្មួយ ប៉ុល ពត នោះ។ ជាក្មួយ ជាកងការពារផង ហើយជាពេទ្យផង ហើយដើរតាមពូរបស់ខ្លួនរហូតដល់ពេលវៃបែកភ្នំពេញ។ គាត់និយាយថា គាត់បានធ្វើការជាមួយ ភី ភួន ស្គាល់ ភី ភួន ឈ្មោះ ជាម។ ហើយ សាឡុត

បាន គាត់បានលើកឡើងអំពីការជួបប្រជុំជាទ្រង់ទ្រាយតូច សមាជិកតិច ប្រជុំ មានមេពីរបីនាក់ទេម្តងៗ ពេលចូលប្រជុំម្តងៗនោះ។ អ៊ីចឹងខ្ញុំគិតថា នេះដូចជាសមរម្យជាងបើយើងគិតពីយុទ្ធសាស្ត្រយោធា។ គាត់និយាយថា ប៉ុល ពត បានជួបប្រធានភូមិភាគពីរបីនាក់ដោយបញ្ជាក់ថា សាឡុត បាន ហ្នឹងបាន ទាយថា ប្រហែលជា គាត់ហ្នឹងនិយាយអំពីផែនការវាយផ្តាច់ទីក្រុងភ្នំពេញ។ ហើយគាត់មិនដឹងច្បាស់ទេ គ្រាន់តែយកការសន្និដ្ឋាន ការទាយទេ។ អ៊ីចឹងវាតាមចម្លើយរបស់លោក សាឡុត បាន នេះក៏មានលក្ខណៈសម្ងាត់ដែរ។ គាត់និយាយថាមិនមានបាននិយាយអំពីការជម្លៀសអីទេ។ ដូច្នេះវាបញ្ជាក់អំពីពាក្យសម្តីដែលគេនិយាយនៅទីនេះដែល ថាឈរនៅលើអាថ៌កំបាំង ថាគេបិទបាំងរឿងរ៉ាវអ្វីទាំងអស់។ សាឡុត បាន បានចាំថា បានឃើញ លោក ខៀវ សំផន នៅមូលដ្ឋានហ្នឹង មូលដ្ឋានដែលខិតចូលមកទីក្រុងភ្នំពេញហើយ ក៏ប៉ុន្តែមិនបានឃើញគាត់នៅក្នុងកិច្ចប្រជុំអីមួយទេ។

[១១:៤៥:០៧]

អ៊ីចឹងយើង ជាការកត់សម្គាល់ណាស់ ដែលយើងត្រូវកត់សម្គាល់លើអ្វីដែលគាត់និយាយនៅក្នុងសវនាការនេះ។ សូមដកស្រង់៖ "ខ្ញុំឃើញ ខៀវ សំផន នៅកន្លែងនោះមិនមែនជាកិច្ចប្រជុំធំដុំអីទេ ឃើញគាត់សរសេរ ជួយសរសេរបញ្ជីមួយប្រហែលជាបញ្ជីស្បៀង គ្រាប់រំសេវ។ ក្រៅពីកិច្ចប្រជុំនេះ ខ្ញុំមិនបានដឹងទេ"។ សំណួរមួយទៀត ដែលគេសួរទៅគាត់ពេលនោះ "តើលោក ខៀវ សំផន មានទំនួលខុសត្រូវផ្នែកយោធាដែរឬទេ មុនវាយចូលទីក្រុងភ្នំពេញនេះ? ចម្លើយ៖ អត់ទេ។ សំណួរ៖ ហេតុអីបានជាគាត់គិតគូរពីបញ្ជីគ្រាប់រំសេវ បើគាត់អត់មានអ្វីពាក់ព័ន្ធនឹងផ្នែកយោធា? ចម្លើយ៖ ប្រសិនបើតាមខ្ញុំដឹងនេះ ដោយសារគាត់អ្នកចេះសរសេរ គាត់អ្នកចេះដឹងអ៊ីចឹងគេសូមឲ្យគាត់ជួយគេទេ"។ សូមបញ្ចប់ការដកស្រង់។

[១១:៤៦:០៦]

ចំណុចបន្ថែមមួយទៀត ដើម្បីរំឭកថា ឋានៈជាប្រធាន ថាមេបញ្ជាការនេះ ដូចវាអត់វាមានន័យអីទេ ម៉េចឲ្យប្រធាន -- មេអគ្គបញ្ជាការទៅសរសេរធ្វើបញ្ជីគ្រាប់រំសេវ ដូចជាអត់មានន័យ។ នៅក្នុងចម្លើយរបស់លោក សាឡុត បាន ដូចដែលគាត់បានលើកឡើងនៅទីនេះ គឺកិច្ចប្រជុំដែលមានសមាជិកចូលរួមតិចនេះមានន័យជាង។ ក៏ប៉ុន្តែ សាឡុត បាន មិនត្រឹមតែនិយាយប៉ុណ្ណឹងទេ គាត់ -- ហើយនិងចំណុចនេះ គឺថាវាអាចផ្ទុយនឹងអ្វីចម្លើយរបស់លោក ភី ភួន។ សាឡុត បាន និយាយដូចទៅនេះ "នៅក្នុងឋានៈគាត់ជាអ្នកយាម គឺថាមានចម្ងាយសន្តិសុខចាំបាច់ គឺថាពី១៥ទៅ៦០ម៉ែត្រ មិនត្រូវនៅជិតគេប្រជុំ

ទេ"។ ហើយ ភី ភួន ក៏យល់ស្របដែរត្រង់ចំណុចនេះពេលដែលគាត់មកផ្តល់សក្ខីកម្មនៅឆ្នាំ២០១២។ សាឡុត បាន ឆ្លើយទៀតថា នៅពេលដែលគេសួរគាត់ "ថាតើអ្នកយាមនុ៎ងមានលបស្តាប់គេទេ?" គាត់ថា "អ៎ូ! មិនអាចទេ ព្រោះថាអ្នកយាមហ្នឹងមិនអាចនៅជិតកន្លែងគេប្រជុំបានទេ"។ គាត់ពន្យល់ថា ការដែលទីបញ្ជាការ -- គាត់បានពណ៌នាពីទីបញ្ជាការ ហើយនិងខ្ទមអត់មានជញ្ជាំង។ គាត់និយាយថា៖ "គេឲ្យនៅឆ្ងាយហ្នឹងដោយសារគេមិនចង់ឲ្យឮហ្នឹងហើយ ជាការសម្ងាត់"។ ហើយមិនមែនត្រឹមតែ សាឡុត បាន ទេនិយាយអ៊ីចឹង និយាយជំទាស់នឹង ភី ភួន នោះមាន អឿន តាន ដែរជាកងការពារមួយ ដែរនៅសម័យខ្មែរក្រហមនោះ នៅសវនាការយើងឆ្នាំ២០១២នេះដែរ ១៣ មិថុនា ២០១២។ គាត់និយាយថា "នៅពេលដែលគាត់ធ្វើការបញ្ជារបស់អ្នកយាម អ្នករក្សាសន្តិសុខនុ៎ងថា ត្រូវនៅ២០ម៉ែត្រ ពីអ្នកប្រជុំ ហើយម្តែ--"។ គាត់បញ្ជាក់ទៀតថា "២០ម៉ែត្រហ្នឹង គឺថាយើងមិនអាចឮអ្វីដែលគេនិយាយក្នុងពេលប្រជុំទេ"។

[១១:៤៨:១៥]

អ៊ីចឹងយើងថា តាមសក្ខីកម្មរបស់គាត់នេះ គឺថាមុននឹងពេលវាយលុកទៅចូលទីក្រុងភ្នំពេញនោះ គេត្រូវតែរក្សាការសម្ងាត់ហើយ គេមិនចង់ឲ្យអ្នកណាស្តាប់ឮបានទេ។ អ៊ីចឹងគេមិនប្រថុយនឹងគ្រោះដែលថា ប្រថុយឲ្យការវាយលុកនេះបរាជ័យទេ មិនអាចឲ្យអ្នកណាដឹងបានទេ។

ខ្ញុំមិនដឹងថា បញ្ហាចម្រូងចម្រាសនេះនៅក្នុងចម្លើយរបស់សាក្សី របស់លោក ភី ភួន នោះបើធៀបទៅចម្លើយអ្នកផ្សេងៗទៀតហ្នឹង ក៏ប៉ុន្តែអង្គាល់ហ្នឹងបើយើងគិតទៅសហព្រះរាជអាជ្ញាត្រូវតែបង្ខំចិត្តហៅលោក នូ ម៉ៅ មកផ្តល់សក្ខីកម្មនៅទីនេះ។ ហើយលោក នូ ម៉ៅ នេះៗចង់បំពេញកង្វះខាតរបស់លោក ភី ភួន ។ សហព្រះរាជអាជ្ញាចង់ឲ្យគាត់ឆ្លើយបំពេញយ៉ាងដូច្នេះ។ ខ្ញុំសូមថា នូ ម៉ៅ នេះមិនមាននៅក្នុងបញ្ជីរបស់លោកសហព្រះរាជអាជ្ញាទេ គឺជាសាក្សីមួយដែលចៅក្រមស៊ើបអង្កេតមិនបានសម្ភាសទេ សួរចម្លើយទេ។ ហើយគឺជាសាក្សីដែលគេហៅមកដោយថាចេញសំណើបន្ថែមក្រោយនោះទេ នៅឆ្នាំ២០១៣ហើយទេ។ លោក នូ ម៉ៅ នេះគឺថាអស់លោក លោកស្រីចៅក្រមចាំហើយ គឺថាជាសាក្សីដែលគាត់បានប្រាប់ថា គាត់ហ្នឹងរបួសនៅលើទីលានប្រយុទ្ធ ដោយធ្លាក់ពីលើអង្រឹង។ នូ ម៉ៅ នេះបានមកផ្តល់សក្ខីកម្មនៅទីនេះតាមរបៀបណា។

[១១:៥០:០០]

បើតាមឯកសារសេរសេរដែររបស់ ប៉ែន យៀរនិន នោះដែលចុះថ្ងៃទី -- ដែលមានសរសេរ

ឈ្មោះលោក ខៀវ សំផន ដែរនៅជិត នៅទាក់ទងទៅនឹងការជម្លៀសនេះ។ នេះគឺជាបេសកកម្មដ៏ប្រញាប់របស់សហព្រះរាជអាជ្ញា ចង់ហៅគាត់មក ព្រោះគេចង់ដឹងថា តើគាត់ហ្នឹងជា ឬក៏មិនមែនគាត់ពីព្រោះថាលោកសាក្សី នូ ម៉ៅ បាននិយាយហើយ។ ហើយយើងបានលើកឡើងអំពីពាក្យពេចន៍របស់ នូ ម៉ៅ ក្នុងសារណាយើង។ យើងនិយាយអំពីលក្ខខណ្ឌដែលគាត់មកផ្តល់សក្ខីកម្មនោះ។ នូ ម៉ៅ និយាយម្តងអ៊ីចេះម្តងអ៊ីចុះ ផ្ទុយគ្នាទៅវិញទៅមក។ មួយថ្ងៃនិយាយអ៊ីចេះ មួយថ្ងៃនិយាយអ៊ីចុះ ឬក៏មួយនាទីនេះនិយាយអ៊ីចេះមួយនាទីក្រោយទៀតនិយាយអីផ្សេងទៀតផង។ នៅសវនាការថ្ងៃទី១៩ មិថុនា នេះគឺព្រះរាជអាជ្ញាមានការលំបាកណាស់ក្នុងការទទួលព័ត៌មានដែលខ្លួនចង់បានពីសាក្សីនេះ។

មានព័ត៌មានលម្អិតមួយដែលថា មានឈ្មោះ ខៀវ សំផន នៅក្នុងកំណត់សម្គាល់ហ្នឹង មិនមាននៅក្នុងកំណត់សម្គាល់របស់ ប៉ែន យៀរនិន ទេ។ មិនមានការថតកិច្ចសម្ភាសន៍របស់ នូ ម៉ៅ ហ្នឹងផងទេ។ អ៊ីចឹងយើងមិនដឹងថាហេតុអ្វីដែលថាលក្ខខណ្ឌអ្វីដែល ខៀវ សំផន មានឈ្មោះនៅក្នុងកំណត់ហេតុហ្នឹង។ ក៏ប៉ុន្តែដោយគ្រាន់គេឃើញតែឈ្មោះលោក ខៀវ សំផន ហ្នឹងអ៊ីចឹងត្រូវឲ្យលោក នូ ម៉ៅ ហ្នឹងមកផ្តល់សក្ខីកម្ម។

[១១:៥១:៤៥]

អ៊ីចឹងនៅក្នុងសក្ខីកម្មហ្នឹងនៅថ្ងៃ ខែមិថុនា ២០១៣ហ្នឹង គាត់មកម៉ោង១១:០៨នាទី គេសួរ នូ ម៉ៅ។ គេនិយាយពីឆ្នាំ១៩៧៤ ហើយគេសួរគាត់ថា “តើលោកមាននិយាយអំពីផែនការ តាម៉ុក ក្នុងការជម្លៀសទីក្រុងភ្នំពេញដែរឬទេ? លោកបាននិយាយអំពីយោបល់របស់ ជូ ជេត ដែរលើផែនការជម្លៀសនេះ ហើយលោកនិយាយពីយោបល់របស់អ្នកផ្សេងៗទៀតទេ អ្នកដឹកនាំផ្សេងៗទៀតទេ?” ចម្លើយថា “ខ្ញុំអត់ដឹងទេ អត់ដឹងអ្វីទាំងអស់ ខ្ញុំនៅថ្នាក់ឃុំ អ៊ីចឹងខ្ញុំមិនអាចដឹងអីលើសពីហ្នឹងទេទាក់ទងការជម្លៀសនេះ”។ ហើយនៅក្រោយមកទៀត គាត់ឆ្លើយថា “ខ្ញុំគ្រាន់តែជាសមាជិកឃុំកំប៉ិកកំប៉ុកទេ។ អ៊ីចឹងខ្ញុំមិនដឹងអីទេ”។

ថ្ងៃទី១៩ មិថុនា ឆ្នាំ២០១៣ ម៉ោង១១:១២នាទី បន្ទាប់ពីមានការលំបាកក្នុងការចោទសំណួរសហព្រះរាជអាជ្ញាក៏ដកស្រង់កំណត់ហេតុរបស់ ប៉ែន យៀរនិន ដែលមានឈ្មោះលោក ខៀវ សំផន។ “ម៉ុក និង ខៀវ សំផន គាំទ្រការជម្លៀសនៅឆ្នាំ១៩៧៤ លោក នូ មោក តើលោកចាំទេ នឹកឃើញទេឈ្មោះនេះ ហើយមាន ម៉ុក ហើយនិង ខៀវ សំផន នេះដែលគាំទ្រការជម្លៀសនៅឆ្នាំ១៩៧៩?” ចម្លើយនៅម៉ោង ១១:១៥:៥០ គាត់ឆ្លើយថា៖ “ខ្ញុំអត់ចាំទេ”។

[១១:៥៣:៣៣]

នៅថ្ងៃដដែល ម៉ោង១១:២៣នាទី សំណួររបស់សហព្រះរាជអាជ្ញា "ចុះអង្គាល់នោះតើលោកដឹងថាយោបល់របស់លោក ខៀវ សំផន យ៉ាងម៉េចដែរទាក់ទងនឹងការជម្លៀសនេះ?" ចម្លើយរបស់លោក នូ មោក "ខ្ញុំមិនស្គាល់ ខៀវ សំផន, ហ៊ូ នឹម ទេ។ ខ្ញុំសូមរកនឹកឈ្មោះសិន ហ៊ូ នឹម, ហ៊ូ យន់ ខ្ញុំអត់ចាំទេ។ អ្ហំ ប្រហែលជាមាន ហ៊ូ នឹម, ហ៊ូ យន់ និងខៀវ សំផន ហើយមើលទៅ"។

ក៏ប៉ុន្តែដល់ម៉ោង១១:២៥នោះ ខាងសហព្រះរាជអាជ្ញាគេសួរ -- ចម្លើយរបស់លោក នូ ម៉ៅ បើតាមឈ្មោះលោក ខៀវ សំផន។ គោលជំហររបស់ ខៀវ សំផន គាត់គាំទ្រការជម្លៀស ក៏ប៉ុន្តែមិនដឹងថាដឹងពីគោលជំហររបស់លោក ខៀវ សំផន ហ្នឹងក្នុងលក្ខខណ្ឌណាទេ។ ប៉ុន្តែកន្លែងនេះគឺថាបញ្ជាក់ពីបរាជ័យព្រះរាជអាជ្ញាហើយ។

ថ្ងៃបន្ទាប់មកទៀតហ្នឹងម៉ោង -- កាលនោះខ្ញុំអ្នកសួរទេ ម៉ោង១៤:១១នាទី សំណួរច្បាស់ណាស់កាលនុ៎ង។ ខ្ញុំសួរគាត់ថា "តើលោកអាចពន្យល់ជូនតុលាការបានដែរឬទេ ថាតើលោកដឹងពីគោលជំហររបស់លោក ខៀវ សំផន ដែរឬទេទាក់ទងថាការជម្លៀសចេញពីទីក្រុងភ្នំពេញ? ចម្លើយ៖ ខ្ញុំមិនដឹងពីគោលជំហររបស់គាត់ទេ។ ដូចខ្ញុំដឹងហើយថា ខ្ញុំដឹងតែពីគោលជំហររបស់ ហ៊ូ យន់ នោះទេ។ គាត់និយាយថាមិនត្រូវជម្លៀសប្រជាជនចេញទេ។ ក៏ប៉ុន្តែ ខៀវ សំផន ហើយ ហ៊ូ នឹម ខ្ញុំអត់ស្គាល់គាត់ទេ"។ សូមបញ្ចប់ការដកស្រង់។

[១១:៥៥:១៤]

ហើយត្រង់ចំណុចនេះ ខ្ញុំសូមរំឭកថា ដោយហេតុថា យើងបានរៀបរាប់ហើយនៅក្នុងសារណារបស់យើង។ ខ្ញុំសូមរំឭកថា ពុំមានភាពស្រពេចស្រពិល ឬក៏ច្របូកច្របល់ទេទាក់ទងទៅនឹងពាក្យថា "គោលជំហរ" ជាភាសាខ្មែរនេះ។ "គោលជំហរ" គេនិយាយជាភាសាខ្មែរ–*ប៉ូស៊ីស្យុង*។ អ៊ីចឹងគោលជំហររបស់លោក ខៀវ សំផន ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញ។ សាក្សី នូ ម៉ៅ នោះ ទោះបីជាគាត់ពន្យល់ប្រាប់យើង ក្រោយពេលគេឲ្យកំណត់ហេតុរបស់ ប៉ែរ យៀរនិន ហើយក៏ដោយ គាត់កាលណោះ ទោះបីជាគាត់ខំប្រឹងឲ្យចាំៗរត់មាត់នោះ អង្គាល់នោះគាត់នៅតែឆ្លើយថា គាត់អត់ដឹងទេ។ អ៊ីចឹងនេះហើយជាសាក្សីដែលគេហៅមក កោះមកទីនេះ ដើម្បីឲ្យជួយ ភី ភួន បំពេញចម្លើយរបស់ ភី ភួន។ អ៊ីចឹងបើយើងចង់កំណត់សេចក្តីសម្រេចនៃការ -- កំណត់កាលបរិច្ឆេទនៃការសម្រេចជម្លៀសនៅឆ្នាំ១៩៧៤នោះ នេះមិនមែនជាចម្លើយ -- ទាំងឡាយនេះ ក៏ដោយមិនមែនជា --

សូមទោស-- ខែមិថុនា ដែលថា ខៀវ សំផន មានប្រជុំ មានវត្តមាននៅក្នុងប្រជុំនោះ យើងត្រូវរំឭក នឹកទៅដល់ការធ្វើទស្សនកិច្ចរបស់លោក ខៀវ សំផន ដែលធ្វើនៅខែ ចន្លោះខែមេសា ហើយនិងមិថុនា ឆ្នាំ១៩៧៤ ដែលគាត់ទៅជួប អៀង សារី នៅប្រទេស -- ជួប សីហនុ នៅប្រទេសចិន។

[១១:៥៦:៥៣]

គឺឯកសារ E3/3315 ហើយបន្ទាប់មកទៀត គាត់ទៅធ្វើទស្សនកិច្ចនៅរ៉ូម៉ានី នៅខែឧសភា ទៅអាល់ហ្សេរី។ អ៊ីចឹងមានប្រភពជាច្រើនថានៅខែមិថុនា ឆ្នាំ១៩៧៤ គាត់នៅប្រទេសឡាវទេ គឺឯកសារ E3/13 (*ស៊ុីក*)-- អតីតលេខាទី១នៃស្ថានទូត គាត់ចាំថា ខៀវ សំផន គាត់បានធ្វើទស្សនកិច្ចនេះមែន។ ហើយយើងទាំងអស់គ្នាក៏ត្រូវចាំផងដែរថា ទោះបីជាខាងព្រះរាជអាជ្ញានេះ ខំព្យាយាមបង្កឲ្យ មានភាពអាស្រូវ ថាសុំឲ្យគេដាក់ទណ្ឌកម្មលើសហភាតាខ្ញុំ–លោក គង់ សំអុន នោះ– ដែលគាត់គ្រាន់តែ -- កាលណោះ គង់ សំអុន គ្រាន់តែសុំឲ្យគេជួយបញ្ហាដោះស្រាយបកប្រែនោះទេ។ ហើយខាងសហព្រះរាជអាជ្ញានោះសុំ -- ហើយកាលនោះគាត់និយាយថា -- ហើយកាលណោះទាក់ទងនឹងនេះ ទាក់ទងនឹងរឿងថា គាត់ទៅទស្សនកិច្ចនៅចិនហើយ ប្រពន្ធគាត់ឆ្លងទន្លេ គាត់អត់នៅទីនេះផងទេ។

ថាគេថា -- ខៀវ សំផន នៅក្នុងសៀវភៅរបស់គាត់, ឯកសារ E3/18, គាត់និយាយថា "គាត់ដឹងពីការជម្លៀសនេះនៅថ្ងៃហ្នឹងតែម្តងទេ ថ្ងៃដែលគេជម្លៀសទេ ដូចតែយោធាផ្សេងទៀតដែរទេដែលគេដឹង ដល់គេចេញបញ្ជាឲ្យហើយបានដឹង"។

[១១:៥៨:៤៦]

អ៊ីចឹងយើងអាចជឿមិនជឿ វាតាមតែយើងទេ ប៉ុន្តែ ហ្វីលីព ស្សូត អត់ជឿគាត់ទេ នៅពេលដែលសម្ភាសលោក ខៀវ សំផន នោះ។ ហើយជឿក៏បាន មិនជឿក៏បាន ក៏ប៉ុន្តែដូចសហភាតាខ្ញុំបានរំឭកអ៊ីចឹង គឺថានៅកាលបរិច្ឆេទហ្នឹង លោក ខៀវ សំផន មិនមែនជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមទេកាលណោះនោះ។

យើងអាចមានគោលជំហរដូចលោក ហ្វីលីព ស្សូត ដែរដែលនិយាយថា ទោះយ៉ាងណាក្តី នៅពេលនោះនោះ យើងមិនអាចជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ថ្នាក់លើ ដោយពុំមានបញ្ហានោះទេ។

លោកប្រធាន អស់លោក លោកស្រីចៅក្រម ជាទីគោរព! ភស្តុតាងដែលអស់លោក លោកស្រីមានព័ន្ធពាក់ទៅនឹងសេចក្តីសម្រេចជម្លៀសប្រជាជន ខ្ញុំមិនដឹងថា ជាការចាំបាច់ក្នុងការរំឭកភស្តុតាងទាំងអស់នេះទេ។ ក៏ប៉ុន្តែវាជាគោលការណ៍ ព្រោះនៅក្នុងច្បាប់ព្រហ្មទណ្ឌ ព្រោះថាកាលណា យើង

លើកឡើងពីបញ្ហាភស្តុតាងទាំងអស់នេះ វាជាប្រយោជន៍ដល់ជនជាប់ចោទ។

ខ្ញុំឃើញថាម៉ោង ដល់ម៉ោងស្រស់ស្រូបអាហារពេលថ្ងៃត្រង់ហើយលោកប្រធាន គិតយ៉ាងម៉េចដែរ?

[១១:៥៩:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ សូមភាគី និងសាធារណជនជ្រាប។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំ នៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន នូវឱកាសក្នុងការបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១ របស់ខ្លួន។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ នៅពេលមុនឈប់សម្រាកនោះ ខ្ញុំបាននិយាយបញ្ចប់អំពីការពិនិត្យមើលភស្តុតាងពាក់ព័ន្ធនឹងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដំណាក់កាលទី១។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកក្រោយបន្តិច។ ខ្ញុំចង់និយាយអំពីការចូលរួមជាទូទៅក្នុងការជម្លៀសប្រជាជនតាមការ

ចោទប្រកាន់ គឺការចោទប្រកាន់ទៅលើលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការចូលរួមក្នុងការជម្លៀស។

[១៣:៣២:៤០]

កថាខណ្ឌមួយនៃដីកាដំណោះស្រាយ ហើយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាផងដែរបានបញ្ជាក់ថា តាមរយៈតួនាទីផ្សេងៗគ្នាដែលបាន -- ដែលអនុវត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ហើយនិងពីទីក្រុង ពីតំបន់ជនបទទៅកាន់ភូមិភាគផ្សេងទៀត ទៅកាន់តំបន់ផ្សេងទៀត គឺកថាខណ្ឌ១១៥៣ នៃដីកាដំណោះស្រាយ។

សហភាតារបស់ខ្ញុំបានលើកឡើងអំពីតួនាទីរបស់លោក ខៀវ សំផន រួចមកហើយ។ ជួនកាលទៅគឺតួនាទីគ្រាន់តែមានតែជាឈ្មោះ តួនាទីឧបកិច្ចតែប៉ុណ្ណោះ។ ហើយឥឡូវនេះខ្ញុំចង់និយាយអំពីតួនាទីផ្សេងទៀត ដែលត្រូវបានលើកឡើងនៅក្នុងសវនាការយើងនេះ។ ជាពិសេសគឺតួនាទីរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបង្រៀនក្នុងវគ្គរៀនសូត្រ ទំនាក់ទំនងជាមួយពាណិជ្ជកម្ម និងទស្សនៈរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងមន្ទីរ៨៧០។

[១៣:៣៣:៥៤]

ខ្ញុំនិយាយដោយខ្លីទេ នៅពេលដែលខ្ញុំនិយាយថានិយាយដោយខ្លីនោះ លោក លោកស្រីចៅក្រមដឹងច្បាស់ហើយ គឺថាគោលជំហររបស់មេធាវីការពារក្តីបានបញ្ជាក់រួចមកហើយ គឺថានៅក្នុងក្របខ័ណ្ឌនៃការបំបែកនីតិវិធី ក៏ដូចជាការនិយាយធៀបទៅនឹងការសម្រេចអំពីការជម្លៀស និងការអនុវត្ត គឺយើងនឹងមិននិយាយហួសពីឆ្នាំ៧៦ទេ។ គឺអង្គជំនុំជម្រះជាអ្នកកំណត់ថាមិនឲ្យនិយាយហួសពីឆ្នាំ៧៦ ពាក់ព័ន្ធនឹងការពិនិត្យមើលតួនាទីរបស់លោក ខៀវ សំផន ដើម្បីចង់ដឹងថាតើគាត់ទំនងជាកាន់កាប់តំណែងអ្វីខ្លះ និងតួនាទីអ្វីខ្លះដែលអាចចូលរួមចំណែកក្នុងការបង្ហាញអំពីអង្គហេតុនោះ។

ទស្សនៈរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹង៨៧០ គឺស្របគ្នាទៅនឹងទស្សនៈរបស់គាត់ផ្អែកទៅលើពាណិជ្ជកម្ម ពាក់ព័ន្ធទៅនឹងប្រធានបទទាំងអស់នេះ។ ក៏ប៉ុន្តែជាបឋម ខ្ញុំចង់ពិនិត្យមើលពាក្យពេចន៍នៅក្នុងដីកាដំណោះស្រាយ ដែលដីកានេះបានកំណត់ថាជាធាតុផ្សំពាក់ព័ន្ធទៅនឹងការចូលរួមចំណែកក្នុងការធ្វើនយោបាយ ជាពិសេសគឺការថ្លែងសុន្ទរកថាជាសាធារណៈ។

កថាខណ្ឌ១០៦១ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានលើកឡើងជាអាទិ៍អំពីកិច្ចសម្ភាសន៍កាលពីឆ្នាំ១៩៨២ ជាមួយលោក ខៀវ សំផន។ នៅក្នុងអំឡុងកិច្ចសម្ភាសន៍នោះ គាត់ទំនងជាបានប្រកាសថា ការសម្រេចជម្លៀសនេះគឺធ្វើឡើងជារួម ហើយគាត់ទំនងជាបានចូលរួម។

[១៣:៣៥:៥៧]

នេះមិនមែនជាការភ្ញាក់ផ្អើលទេ ពីព្រោះថា ទាំងអស់នេះគឺជាធាតុផ្សំដែលយើងត្រូវបានលើកឡើងរួចមកហើយក្នុងក្របខ័ណ្ឌនៃការសួរសំណួរលោក ស្ទីវ ហេដឌ័រ ហើយនិងនៅក្នុងឱកាសផ្សេងៗទៀត។ នៅពេលដែលយើងនិយាយអំពីអ្នកនយោបាយ ឬនៅពេលដែលយើងនិយាយអំពីការថ្លែងសុន្ទរកថាជាសាធារណៈ យើងអ្វីដែលយើងចង់ដឹងនោះគឺថា តើយើងអាចនិយាយបានអ្វីខ្លះនៅពេលដែលលោក ខៀវ សំផន និយាយនោះ។

នេះគឺជាចំណុចសំខាន់ដែលត្រូវបានរំឭកជាច្រើនដងដោយលោក ខៀវ សំផន ខ្លួនឯងផ្ទាល់តែម្តង ក្រោយឆ្នាំ៧៩។ ថ្វីត្បិតតែអង្គហេតុមិនត្រូវបានប្តឹង ក៏ប៉ុន្តែអង្គជំនុំជម្រះបានដឹងពីអ្វី ដែលបានកើតឡើងហើយ គឺគ្រប់សំណុំរឿងយើងបញ្ចប់នៅពេលដែលវៀតណាមចូល គឺយើងមិននិយាយហួសពីពេលដែលវៀតណាមចូលទេ។ ហើយបន្ទាប់មកទៀតមានការបន្តសង្គ្រាមតទៅទៀត ហើយនៅឆ្នាំ៨២ លោក ខៀវ សំផន បាននិយាយជាសាធារណៈ គឺខ្ញុំចង់និយាយពាក់ព័ន្ធនឹងបរិបទនេះ។

[១៣:៣៧:៣០]

យើងនឹងនិយាយផងដែរអំពីតួនាទីផ្សេងទៀត គឺខ្ញុំនិយាយដោយខ្លីទេ ចំពោះចំណុចនេះគឺនិយាយអំពីតួនាទីជាប្រធាន -- ជាអគ្គមេបញ្ជាការកងទ័ព។ យើងដឹងហើយថាសាក្សីជាច្រើន និងអ្នកជំនាញបានបញ្ជាក់នៅទីនេះរួចមកហើយថាលោក ខៀវ សំផន គាត់មិនមានអំណាចខាងផ្នែកយោធាទេ ហើយតួនាទីជាអគ្គមេបញ្ជាការនេះ គឺគ្រាន់តែដាក់នៅពេលដែលគាត់កាន់រណសិរ្សតែប៉ុណ្ណោះ។

នេះជាធាតុផ្សំដ៏សំខាន់ នៅពេលដែលយើងលើកឡើងនៅក្នុងសវនាការកាលពីប៉ុន្មានថ្ងៃមុននេះ គឺថាទាហានជាអ្នកអនុវត្តការជម្លៀសដោយបង្ខំដំណាក់កាលទី១ ដោយខ្លួនឯង។ ហើយចំពោះដំណាក់កាលទី២ បើតាមសក្ខីកម្មតិចតួចនោះ គឺគេបានពន្យល់ច្បាស់រួចមកហើយ គឺថាគឺយោធាភូមិភាគជាអ្នកធ្វើ ហើយយើងក៏បាននិយាយរួចទៅហើយ អំពីតើយោធាភូមិភាគនោះមានអំណាចប៉ុនណា។ ដូច្នេះខ្ញុំមិនត្រឡប់មកនិយាយដដែលៗវិញទេ។

អង្គជំនុំជម្រះបានដឹងរួចមកហើយ ខាងសហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានចូលរួមនៅក្នុងការជម្លៀស ក៏ប៉ុន្តែយើងឃើញថាគាត់មកភ្នំពេញហ្នឹងក្រោយពេលរំដោះបានបន្តិច។ ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទចូលមកដល់ទីក្រុងភ្នំពេញ គឺថាវាមិនមែនជារឿងសាមញ្ញទេ វាតាំងពី -- ហេតុការណ៍បានកើតឡើងយូរណាស់មកហើយ ហើយយើងមានចម្លើយផ្សេងៗគ្នា អាស្រ័យទៅតាម

ភស្តុតាងដែលអង្គជំនុំជម្រះបានស្តាប់នៅក្នុងសវនាការ។

[១៣:៤០:០២]

យើងមានចម្លើយរបស់ ភី ភួន របស់លោក ស្បូត មានចម្លើយរបស់ ប៉ុល ពត ដែលគាត់បានប្រកាសនៅក្នុងសន្និសីទសារព័ត៌មានថ្ងៃទី២៤ ខែមេសា។ នៅមានការ -- បើលោក ខៀវ សំផន គាត់ថាគាត់ចូលមកភ្នំពេញគឺថាប្រហែលជា ៧ ឬ ១០ថ្ងៃក្រោយ ១៧ មេសា។ ដូច្នេះយើងមានកាលបរិច្ឆេទនេះ យើងមើលទៅគឺថាត្រូវរូវ យើងឯកភាពគ្នាទៅលើចំណុចនេះគឺថាគាត់ចូលមកក្រោយពេលដែលគេសម្រេចជម្លៀសហើយ។

យើងក៏មានផងដែរនូវភស្តុតាងដែលបង្ហាញថា មេដឹកនាំ និង ខៀវ សំផន មិនបានចូលមកភ្លាមៗទេ ពីព្រោះថាត្រូវឲ្យទីក្រុងមានសន្តិសុខល្អសិនបានចូល។ ដូច្នេះខ្ញុំនឹងរំឭកអំពីធាតុផ្សំទាំងអស់នេះនៅពេលដែលខ្ញុំនិយាយអំពីការជម្លៀសប្រជាជន ហើយនិងហានិភ័យនៃការវាយបកពីសំណាក់កងទ័ព លន់ នល់ ដែលនៅសេសសល់។ នេះជាធាតុផ្សំដែលយើងត្រូវចងចាំពាក់ព័ន្ធទៅនឹងបរិបទ និងពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនៃការចូលមកដល់ទីក្រុងភ្នំពេញរបស់លោក ខៀវ សំផន និងមេដឹកនាំខ្មែរក្រហមផ្សេងទៀត។

[១៣:៤១:៣២]

អម្បាញ់មិញនេះខ្ញុំបានលើកឡើងរួចមកហើយ អំពីប្រតិកម្មរបស់លោក ខៀវ សំផន នៅពេលដែលគាត់បានដឹងពីការជម្លៀស។ តើហេតុអ្វីបានជាមានភាពចាំបាច់ក្នុងការនិយាយអំពីចំណុចនេះ? ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលឯកសាររបស់គាត់ គឺឯកសារលេខ E3/18 ដែលគាត់បានលើកឡើងអំពីការសន្ទនាជាមួយ ប៉ុល ពត ដែល ប៉ុល ពត បានឆ្លើយប្រាប់គាត់ថា ខ្ញុំសូមដកស្រង់ “អស់លោកជាអ្នកបញ្ញវន្ត លោកមិនដែលដាក់ជើងជាន់ដីទេ ហើយពួកអស់លោកមិនដឹងការពិតទេ ក្នុងឋានៈជាបញ្ញវន្តនោះ”។

ខ្ញុំសូមបន្តពីការលើកឡើងរបស់លោកមេធាវី វែកគែន កាលពីព្រឹកមិញ។ ពាក់ព័ន្ធទៅនឹងចំណុចដែលថាសុន្ទរកថា ដែលបានផ្សព្វផ្សាយនោះគឺគេចោទថាជារបស់លោក ខៀវ សំផន។ ហើយគាត់ជាតំណាងឲ្យរណសិរ្សនៅពេលនោះ។ ហើយបើតាមចៅក្រមស៊ើបអង្កេតនោះ ធាតុផ្សំទាំងអស់នោះវាចូលរួមចំណែកជួយដល់ការជម្លៀសប្រជាជនដំណាក់កាលទី១ គឺមានសុន្ទរកថាមុនថ្ងៃទី១៧ មេសា ៧៥។ សហភាតារបស់ខ្ញុំបាននិយាយរួចមកហើយ ខ្ញុំមិននិយាយដដែលវិញទេ។ ក៏ប៉ុន្តែនៅពេលដែល

យើងនិយាយអំពីពេលដែលកំពុងតែមានសង្គ្រាមនោះ ជាទូទៅគេនិយាយអំពីខ្មាំង ហើយជាទូទៅនោះគេជៀសវាងកុំឲ្យ -- គឺយើងធ្វើម៉េចឲ្យយើងមានការឈ្នះ។

[១៣:៤៣:៤១]

ចំណុចមួយទៀត ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត គឺកថាខណ្ឌ១១៦១ ថា "លោក ខៀវ សំផន រីករាយ ហើយប្រកាសពីជ័យជម្នះនៃរបបឆ្វេងនិយមរបស់គាត់"។ ដូច្នេះត្រង់ចំណុចនេះទៀតខ្ញុំកត់សម្គាល់ឃើញថា ការរីករាយដែលបានឈ្នះគំនិតនយោបាយដែលថាអាចឲ្យគំនិតនយោបាយរបស់គាត់លេចជារូបរាងឡើងនោះវាមិនមែនជាឧក្រិដ្ឋកម្មទេ។

ដីកាដំណោះស្រាយក៏បានលើកឡើងផងដែរ នូវសេចក្តីថ្លែងការណ៍មុនៗដែលផ្សាភ្ជាប់ទៅនឹងការប្រកាន់ជំហរជាសាធារណៈនេះ។ ជាពិសេសសុន្ទរកថាផ្សាយក្នុងវិទ្យុចិននៅថ្ងៃទី១៣ ខែសីហា ឆ្នាំ៧៥ ឯកសារ E3/119 និងមានសុន្ទរកថាថ្ងៃទី១៨ សីហា ឆ្នាំ៧៦ នៅទីក្រុង -- នៅសន្និសីទកូឡុំបូសន្និសីទរបស់ប្រទេសមិនចូលរួមបក្សសម្ព័ន្ធ គឺឯកសារលេខ E3/549។

ខ្ញុំចង់និយាយពាក្យពេចន៍មួយចំនួនពាក់ព័ន្ធទៅនឹងការថ្លែងសុន្ទរកថានេះ តាមរបៀបដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញនោះ វាគ្រាន់តែបង្ហាញរបៀបជាលក្ខណៈថ្លុកតែប៉ុណ្ណោះ ជាលក្ខណៈបំផ្លើស។ ដូច្នេះការសរសេរនៅក្នុងដីកាដំណោះស្រាយនេះគឺថា បង្ហាញឲ្យឃើញអំពីទស្សនៈរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន និងស្ថានភាពទូទៅនៅកម្ពុជា។ នៅពេលដែលយើងពិនិត្យមើលធាតុផ្សំទាំងអស់នោះ យើងឃើញថាវាមិនមែនសាមញ្ញដូច្នេះទេ។

[១៣:៤៥:៤៣]

ការសម្ភាសនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៥ គឺប៉ុន្មានសប្តាហ៍ក្រោយពីការជម្លៀស គឺបង្ហាញអំពីស្ថានភាពលំបាកនៅកម្ពុជា។ វារំឭកអំពីធាតុផ្សំទាំងអស់ដែលខ្ញុំបានលើកឡើងពាក់ព័ន្ធទៅនឹងស្ថាន-ភាពនៃប្រទេសកម្ពុជានៅសម័យនោះ។ ហើយនៅពេលនោះលោក ខៀវ សំផន មានតួនាទីតំណាង ធ្វើយ៉ាងណាឲ្យប្រទេសជាមិត្តគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងការកសាង និងស្តារសេដ្ឋកិច្ចជាតិ។ ហើយពាក្យ "ស្តារសេដ្ឋកិច្ច" នេះគឺថាមានសរសេរនៅក្នុងឯកសារសុន្ទរកថា E3/119។ ដូចគ្នាផងដែរសុន្ទរកថានៅសន្និសីទកូឡុំបូនៅឆ្នាំ១៩៧៦នោះ ក៏មានលក្ខណៈបន្ទរបន្ថែមផងដែរ។ នេះគឺជាបរិបទប្រវត្តិសាស្ត្រនៅក្នុងអំឡុងពេលចន្លោះឆ្នាំ៧៥-៧៩ ក្នុងអំឡុងសម័យសង្គ្រាមត្រជាក់ គឺយើងមានប្រទេសមិនចូលបក្សសម្ព័ន្ធដែលបានសម្រេចថា នៅឯករាជ្យ គឺពួកគេរួមគ្នាសម្រេចថា មិនដើរតាមពួកប្រទេស

មហាអំណាចធំៗនោះទេ។

[១៣:៤៧:១៣]

នេះជាចំណុចសំខាន់ ទោះបីជាវាមិនមានក្ខណៈមិនសូវច្បាប់លាស់ក៏ដោយ។ វាជាចំណុចសំខាន់សម្រាប់លោក ខៀវ សំផន ពីព្រោះថានៅពេលដែលគាត់ឡើងថ្លែងមតិនៅក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនោះ គឺត្រូវតែធ្វើយ៉ាងណាបង្ហាញឲ្យឃើញថា មានការទំនាក់ទំនងគ្នារវាងប្រទេសជាមិត្តទាំងអស់នោះ ដែលអាចនឹងផ្តល់ជំនួយ ហើយនិងកម្ពុជានឹងទទួលយកជំនួយប្រសិនបើប្រទេសទាំងអស់នោះស្នើផ្តល់ជំនួយដល់កម្ពុជា។

នេះជាអ្វីដែលលោក ខៀវ សំផន បានថ្លែងសុន្ទរកថានៅក្នុងឆ្នាំ១៩៧៦ នៅក្នុងសន្និសីទកំពូលនៅកូឡុំបូ។ ខ្ញុំសូមដកស្រង់៖, ជាភាសាបារាំងគឺ 00912031, "ក្រោយរំដោះមកប្រជាជននិងរដ្ឋាភិបាលយើងខ្ញុំត្រូវប្រឈមមុខនឹងបញ្ហាធ្ងន់ៗជាច្រើន បណ្តាលមកពីសង្គ្រាមឈ្លានពានដ៏សែនព្រៃផ្សៃយង់ឃ្នងរបស់ចក្រពត្តិអាមេរិក។ កម្លាំងប្រជាជនត្រូវអន្តរាយជាង១លាននាក់ក្នុងប្រជាជនជាង៨លាននាក់។ កម្លាំងខាងពលកម្មជាសត្វពាហនៈរាប់សែនក្បាលត្រូវវិនាសអន្តរាយខ្ទេចខ្ទី។ រោងចក្រ ស្រែចម្ការ ភូមិករជាច្រើនត្រូវអន្តរាយ។ ផ្លូវគមនាគមន៍ទាំងអស់ត្រូវ -- ខ្លះត្រូវអន្តរាយទាំងស្រុង ខ្លះទៀតត្រូវអន្តរាយពី ៧០ ទៅ៨០ភាគរយ បញ្ហាស្បៀងចោទឡើងជាខ្លាំង"។ សូមបញ្ចប់ការដកស្រង់។

[១៣:៤៨:៥៤]

ដូច្នេះវាបង្ហាញអំពីស្ថានភាពពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងនៅកម្ពុជា។ នៅក្នុងសុន្ទរកថានេះលោក ខៀវ សំផន ទោះបីជាគាត់ជាអ្នកសរសេរ ឬមិនមែនជាអ្នកសរសេរក៏ដោយ ពីព្រោះយើងដឹងហើយថា សុន្ទរកថាភាគច្រើននោះគឺ ប៉ុល ពត ជាអ្នកសរសេរឲ្យលោក ខៀវ សំផន ទេ។ សុន្ទរកថានេះគឺបានថ្លែងទៅកាន់ប្រទេសជាមិត្ត ជាប្រទេសជាសម្ព័ន្ធមិត្តរបស់កម្ពុជា ហើយមានបង្ហាញអំពីឆន្ទៈក្នុងការចង់បានការជួយជ្រោមជ្រែងតាមផ្លូវការទូត។ ពេលនោះគឺគាត់ធ្វើហ្នឹង ការងារហ្នឹងគឺយើងអាចហៅថាជាការងារការទូត ដើម្បីធ្វើយ៉ាងណាឲ្យមានការផ្តល់ជំនួយដល់ប្រទេសកម្ពុជា នៅពេលដែលកម្ពុជាកំពុងតែត្រូវការជំនួយនោះ។

ដូច្នេះវាផ្ទុយអំពីទស្សនៈរបស់ចៅក្រមស៊ើបអង្កេត សុន្ទរកថានេះ គឺមិនមែនជាការបង្ហាញអំពីការជម្លៀសទេ គឺវាបង្ហាញអំពីការចង់បានជំនួយពីបរទេសខណៈដែលប្រទេសកម្ពុជាកំពុងតែត្រូវការនោះ។ ដូច្នេះវាមិនបានបង្ហាញឲ្យឃើញថាលោក ខៀវ សំផន ចូលរួម ឬក៏ជួយជំរុញឲ្យមានការប្រព្រឹត្ត

ឧក្រិដ្ឋកម្មនោះទេ។ យើងមិនអាចទាញការសន្និដ្ឋានចេញពីសុន្ទរកថានេះទៅរកចំណុចថា គាត់បានចូលរួមក្នុងការជួយជ្រោមជ្រែងឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។

[១៣:៥០:១៧]

ពាក់ព័ន្ធទៅនឹងការចូលរួមចំណែកតាមការចោទប្រកាន់ទៅក្នុងការជម្លៀសនោះ យើងនឹងពិនិត្យមើលឯកសារពាក់ព័ន្ធទៅនឹងការជម្លៀសទី២។ យើងដឹងហើយថានៅសម័យនោះ ហើយសហព្រះរាជអាជ្ញាខ្លួនឯងក៏ទទួលស្គាល់ដែលថា ខៀវ សំផន និងអៀង សារី គាត់នៅបរទេសឯណោះទេ។ យើងដឹងច្បាស់ហើយថា គាត់មិនត្រឹមតែនៅបរទេសទេ គឺគាត់ទៅតាំងពីមុនពេលដែលមានការប្រជុំទៅទៀត។

ខ្ញុំសូមរំឭកឯកសារមួយគឺ សេចក្តីផ្សាយតាមវិទ្យុថ្ងៃទី២០ ខែសីហា ឆ្នាំ៧៥ ឯកសារ E3/119 ដែលក្នុងឯកសារនោះលើកឡើងអំពីទស្សនកិច្ចនៅប្រទេសកូរ៉េ ខ្ញុំសូមដកស្រង់៖ "ខៀវ សំផន ឧបនាយករដ្ឋមន្ត្រីបានចេញពីប៉េកាំងទៅព្យុងយ៉ាងនៅថ្ងៃទី១៩ សីហា ឆ្នាំ៧៥ ដើម្បីទៅទស្សនកិច្ចនៅប្រទេសកូរ៉េ"។ សូមបញ្ចប់ការដកស្រង់។ គាត់នៅប្រទេសចិន ហើយគាត់ចេញពីចិនទៅកូរ៉េ។ ដូច្នេះមានន័យថាគាត់មិនបាននៅក្នុងកិច្ចប្រជុំនោះទេ។

យើងក៏ចង់បាន និយាយអំពីកិច្ចប្រជុំដែលនិយាយអំពីកិច្ចប្រជុំ ដែលលើកឡើងដោយ អៀង សារី ហើយសហព្រះរាជអាជ្ញាបានលើកឡើងគួរភ្ញាក់ផ្អើល គាត់ជឿលើអៀង សារី តែមិនជឿលើខាងក្រុមយើងខ្ញុំ។ ពិតណាស់ថា សេចក្តីប្រកាសរបស់ អៀង សារី ត្រូវបានយកមកប្រើប្រាស់នៅក្នុងតុលាការនេះ គ្រាន់តែជាការដាក់បន្ទុក គឺមិនមែនយកមកដើម្បីដោះបន្ទុកនោះទេ។ យើងនឹងនិយាយអំពីចំណុចនេះនៅពេលក្រោយ។

[១៣:៥២:២៣]

ទោះជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធទៅនឹងការចូលរួមចំណែករបស់លោក ខៀវ សំផន ក្នុងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២។ ទឡ្ហីករណ៍ថ្មីៗរបស់សហព្រះរាជអាជ្ញានោះគឺថា តាមរយៈការងាររបស់លោក ខៀវ សំផន នៅក្នុងក្រសួង-- (សូមទោស) គឺនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម គាត់ពិតជាបានចូលរួមក្នុងការឲ្យមានជម្លៀសប្រជាជនដំណាក់កាលទី២។

មុននឹងនិយាយអំពីសកម្មភាពរបស់លោក ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការពាណិជ្ជកម្ម។ ខ្ញុំនិយាយថា នៅក្នុងក្របខ័ណ្ឌជាគណៈកម្មាធិការ ខ្ញុំមិនមែននិយាយថាក្នុងឋានៈគាត់ជាប្រធានគណៈកម្មាធិការពាណិជ្ជកម្មទេ។ ខ្ញុំចង់និយាយពីពាក់ព័ន្ធទៅនឹងបញ្ហារៀនសូត្រមួយចំនួន។ វគ្គ

រៀនសូត្រគឺជាបញ្ហាសំខាន់ដែលត្រូវលើកឡើង ពីព្រោះថាវគ្គរៀនសូត្រមួយចំនួននោះ គឺកើតឡើងមុនខែមេសា ឆ្នាំ៧៥ គឺតាំងពីគាត់នៅក្នុងព្រៃឯណោះ ហើយលោក គង់ សំអុន ក៏បានលើកឡើងពីចំណុចនេះរួចមកហើយដែរ។ ហើយវគ្គរៀនសូត្រទៀត គឺកើតឡើងនៅពេលក្រោយ។

[១៣:៥៣:៤៥]

ដូច្នេះយើងឃើញថា តាមអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះគឺថា គឺជាការកេងចំណេញពីភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលខ្ញុំនិយាយអំពីភស្តុតាងនោះ ខ្ញុំមិននិយាយអំពីអ្វីដែលមានសរសេរនៅលើក្រដាស ពាក់ព័ន្ធទៅនឹងសេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត ឬក៏ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ខ្ញុំនិយាយអំពីភស្តុតាងដែលចេញមកពីចម្លើយនៅពេលដែលភាគីបានប្រឈមមុខតទល់គ្នានៅក្នុងក្របខ័ណ្ឌ នៃសក្ខីកម្មរបស់សាក្សីណាមួយ។ ដូច្នេះខ្ញុំនិយាយហួសពីអ្វីដែលមានជាលាយលក្ខណ៍អក្សរ គឺខ្ញុំនិយាយពាក់ព័ន្ធនឹងសក្ខីកម្មផ្ទាល់មាត់របស់សាក្សី។

ដូច្នេះនៅក្នុងធាតុផ្សំនៃភស្តុតាងដែលបានដាក់បង្ហាញជូនអង្គជំនុំជម្រះ មិនមានធាតុផ្សំណាមួយដែលបង្ហាញពីចេតនាឧក្រិដ្ឋ ឬការជំរុញឲ្យមានការការប្រព្រឹត្តឧក្រិដ្ឋកម្មដោយលោក ខៀវ សំផន នោះទេ។

កាលបរិច្ឆេទនៃវគ្គរៀនសូត្រ គឺពេលខ្លះទៅមានភាពស្រពេចស្រពិលមិនច្បាស់លាស់ទេ។ កាលបរិច្ឆេទគឺមានសារៈសំខាន់ណាស់ វាពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធី។ ពីព្រោះយើងមិនអាចសម្រេចថាហេតុការណ៍ថ្ងៃស្អែកអាចមានឥទ្ធិពលមកហេតុការណ៍ពីម្សិលមិញនោះទេ។ ក៏ប៉ុន្តែយើងនៅតែនិយាយអំពីវគ្គរៀនសូត្រមួយចំនួន ក៏ដូចជាលើកឡើងអំពីសាក្សីពីររូប ដែលនិយាយច្របូកច្របល់ ហើយដែលសហព្រះរាជអាជ្ញាព្យាយាមស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកនូវទស្សនៈដែលថា លោក ខៀវ សំផន មានឆន្ទៈឧក្រិដ្ឋ។ ខៀវ សំផន មានចេតនាឧក្រិដ្ឋ ពីព្រោះថានៅក្នុងវគ្គរៀនសូត្រទាំងអស់នោះ គាត់ទំនងជាបានថ្លែងសុន្ទរកថា ឬក៏បានធ្វើបទឧទ្ទេសនាមប្រឆាំងនឹងខ្មាំង។ គាត់ទំនងជាបាននិយាយអំពីគោលនយោបាយដែលជាគោលនយោបាយឧក្រិដ្ឋ។

[១៣:៥៦:១៤]

សាក្សីទី១ ដែលជាសាក្សីមានភាពច្របូកច្របល់និយាយមិនច្បាស់លាស់នោះ គឺឈ្មោះ ឯក ហេន -- ឯក ហែន។ ឯក ហែន(*ស៊ីក*) បានលើកឡើងវគ្គសិក្សាពីរ ដែលគាត់បានចូលរួម។ មួយគឺ

បង្រៀនដោយ នួន ជា មួយទៀត គឺបង្រៀនដោយលោក ខៀវ សំផន។ ហើយនៅក្នុងក្របខ័ណ្ឌនៃសក្ខីកម្មរបស់គាត់នៅថ្ងៃទី០៣ កក្កដា ឆ្នាំ២០១៣ យើងកត់សម្គាល់ឃើញថា គាត់ផ្តល់ចម្លើយបញ្ច្រាសផ្ទុយគ្នា ពាក់ព័ន្ធទៅនឹងបទអន្តរាគមន៍របស់ជនជាប់ចោទ នៅក្នុងពេលវគ្គបង្រៀននោះ។ គាត់ច្រឡំគ្នារវាងបទអន្តរាគមន៍របស់ ខៀវ សំផន និង នួន ជា។ ជាពិសេស គឺច្រឡំកាលបរិច្ឆេទតែម្តង។ គាត់បានឆ្លើយនៅក្នុងសវនាការថា៖ "លោក ខៀវ សំផន ទំនងជាបានលើកឡើងនៅក្នុងវគ្គរៀនសូត្រ អំពីការចាប់ខ្លួន ប៉ង់ ដែលគាត់គិតថា នៅឆ្នាំ៧៦"។ ក៏ប៉ុន្តែយើងដឹងច្បាស់ហើយ អស់លោក លោកស្រីចៅក្រម លោកប្រធាន ប៉ង់ មិនត្រូវបានចាប់ខ្លួន -- ប៉ង់ ត្រូវបានចាប់ខ្លួននៅឆ្នាំ៧៨ឯណោះទេ។

[១៣:៥៧:៣៨]

ពាក់ព័ន្ធនឹងការច្របូលច្របល់ភ័ន្តច្រឡំនេះ យើងសូមរំឭកអំពីចម្លើយរបស់សាក្សីនេះផ្ទាល់តែម្តង គឺនៅថ្ងៃទី០៣ កក្កដា ឆ្នាំ២០១៣ ប្រហែលជាម៉ោង១៤:១៥នាទី គាត់បានលើកឡើងថា៖ "ប្រហែលជាខ្ញុំឆ្លើយច្របូកច្របល់។ ខ្ញុំមិនសូវចាំដូចកាលពីអតីតកាលទេ ពីព្រោះថារឿងហេតុវាកើតឡើងយូរណាស់មកហើយ។ ក៏ប៉ុន្តែអ្នកទាំងពីរនោះ បានបង្រៀនវគ្គរៀនសូត្រ ហើយខ្ញុំបានចូលវគ្គទាំងពីរនោះដែលមានអ្នកទាំងពីរធ្វើជាអធិបតី"។

លោក លោកស្រីចៅក្រម! នៅពេលដែលខ្ញុំឃើញនៅក្នុងសារណារបស់សហព្រះរាជអាជ្ញាអំពីការបញ្ជាក់យុត្តកម្មដែលថា ឯក ហែន (*ស៊ីក*) មិនច្រឡំទេ។ ហើយបើតាមទស្សនៈរបស់សហព្រះរាជអាជ្ញា គឺថាៗការិយាល័យសហចៅក្រមជាអ្នកច្រឡំទេ ជាអ្នកធ្វើឱ្យច្រឡំ។ យើងអាចឯកភាពបាន ក៏ប៉ុន្តែយើងបានជជែកគ្នាពាក់ព័ន្ធទៅនឹងបញ្ហានេះ។ អ៊ីចឹងហើយបានជាយើងទាមទារថាកុំឱ្យមានយកតែឯកសារជាលាយលក្ខណ៍អក្សរ កំណត់ហេតុ យើងព្យាយាមចង់ឱ្យមានការកោះហៅ ដើម្បីឱ្យមកសួរដេញដោលតទល់គ្នា។

[១៣:៥៩:០៩]

សាក្សទី២ ក៏ជាសាក្សីដែលឆ្លើយច្របូលច្របល់ដែរ។ នៅពេលដែលខ្ញុំនិយាយពាក្យថា ច្របូកច្របល់នោះ-- (សូមអភ័យទោស) គាត់មិនមែនជាសាក្សីទេ គឺជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ គាត់ឈ្មោះ អែម អឿន គាត់មិនបានស្បថទេ នៅពេលដែលគាត់ផ្តល់សក្ខីកម្មនោះ ពីព្រោះគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។ អែម អឿន ជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកនិយាយពីការថ្លែងសុន្ទរកថារបស់លោក ខៀវ សំផន នៅក្នុងវគ្គរៀនសូត្រ ហើយដែលក្នុងទំនងជាគាត់បាននិយាយអំពីខ្មាំង។

E1/235.1

ខ្ញុំចង់និយាយថា នៅក្នុងសារណារបស់សហព្រះរាជអាជ្ញាក៏បានលើកឡើងអំពីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយគាត់លើកឡើងនេះធ្វើហាក់ដូចជាមេធាវីការពារក្តីមិនបានសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអ៊ីចឹង។ អែម អឿន នេះគាត់មានការច្រឡំច្របូកច្របល់ គាត់និយាយផ្ទុយគ្នាចម្រូងចម្រាសគ្នា គឺប្រហែលជាដូច នូ ម៉ៅ ដែរ គឺសាក្សីទាំងពីរហ្នឹងគឺនិយាយស្រដៀងគ្នា។ នៅពេលគាត់និយាយថាហេតុការណ៍នោះវាបានកើតឡើងជាយូរមកហើយ ដូច្នេះគាត់អាចមានការច្រឡំ។ ដូច្នេះយើងមិនដឹងថាវគ្គរៀនសូត្រនុំងនៅឆ្នាំ៧៥, ៧៦ ឬក៏៧៧ នោះទេ។ យើងមិនអាចទាញសន្និដ្ឋានច្បាស់លាស់អំពីកាលបរិច្ឆេទ។ លោកប្រធានក៏បានកាត់អន្តរាគមន៍ជាច្រើននៅពេលដែលសាក្សីលើកឡើងអំពីកាលបរិច្ឆេទមិនច្បាស់លាស់នេះលោកប្រធាន។

[១៤:០១:១៤]

ពិតណាស់ គាត់អាចច្រឡំ គាត់អាចភ្លេចកាលបរិច្ឆេទ ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវតែមានភាពស៊ីសង្វាក់គ្នាចំពោះហេតុការណ៍ដែលបានកើតឡើង ហើយគាត់និយាយគ្មានភាពស៊ីសង្វាក់គ្នាទេ។ យើងព្យាយាមស្វែងរកឡូស៊ីក ស្វែងរកភាពសមហេតុផលរបស់ អែម អឿន ក៏ប៉ុន្តែយើងរកមិនឃើញទេនៅក្នុងចម្លើយរបស់គាត់។ ចម្លើយរបស់គាត់មិនមានភាពសមហេតុផល ពីព្រោះថាគាត់និយាយថាឪពុកគាត់ស្លាប់នៅឆ្នាំ៧៤។ គឺនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ គាត់ថាឪពុកគាត់ស្លាប់នៅឆ្នាំ១៩៧៤។ ហើយនៅពេលដែលគាត់ចូលរួមវគ្គរៀនសូត្រដែលអះអាងថាលោក ខៀវ សំផន ជាអ្នកបង្រៀន និង នួន ជា។ ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ហើយគាត់ថាឪពុករបស់គាត់គឺបានបង្រៀនលោក ខៀវ សំផន ឲ្យកាន់តំណែងនុំង។

ដូច្នេះយើងឃើញហើយថា លោក ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានគឺនៅខែមេសា ឆ្នាំ៧៦។ ដូច្នេះវាមិនអាចទៅរួចទេដែលឪពុករបស់គាត់ដែលស្លាប់តាំងពីឆ្នាំ៧៤ ទៅហើយនោះអាចមកៗបង្រៀនលោក ខៀវ សំផន ឲ្យកាន់តួនាទីជាប្រធានគណៈប្រធានរដ្ឋនោះ។ អ៊ីចឹងគឺវាមិនអាចទៅរួចទាំងស្រុង។

[១៤:០២:៤៤]

ព័ត៌មានមួយទៀត គេឲ្យយើងជឿថា អែម អឿន អាចចាំបានពាក្យពេចន៍មួយពាក្យម្តងៗរបស់លោក ខៀវ សំផន តាំងពី៤០ឆ្នាំមុន។ ក៏ប៉ុន្តែនៅពេលដែលឲ្យគាត់និយាយអំពីកាលៈទេសៈនៃមរណភាពរបស់ម្តាយរបស់គាត់នោះ គឺយើងមានចម្លើយបីផ្សេងគ្នា។ ម្តងទៅគាត់ថាស្លាប់ដោយសារ

សោកស្តាយ យំសោកខ្លាំងពេក ក្រោយពីឪពុករបស់គាត់ -- ក្រោយពីប្តីរបស់គាត់ស្លាប់នៅឆ្នាំ៧៤។ ម្តងទៅគាត់ឆ្លើយថា ម្តាយគាត់ហ្នឹងត្រូវបានគេសម្លាប់នៅក្នុងវត្តមួយដោយ ប៉ុល ពត គឺដោយពួកខ្មែរក្រហម នៅពេលដែលគាត់កំពុងតែសូត្រធម៌នៅក្នុងវត្ត។ ហើយម្តងទៀតទៅគាត់ឆ្លើយថា គឺគ្រាប់បែក បេ-៥២ទេ ដែលជាអ្នកសម្លាប់ម្តាយរបស់គាត់។

ដូច្នេះយើងឃើញហើយថា មិនដឹងថាតើចម្លើយមួយណាត្រឹមត្រូវទេ យើងរកការពិតមិនឃើញទេ ក្នុងចំណោមចម្លើយដែលចម្រូងចម្រាសគ្នាបែបនេះនោះ។ យើងឃើញថាមានចម្លើយបីបួន ហើយខ្ញុំអាចដឹងច្បាស់ថាអង្គជំនុំជម្រះមិនអាចផ្តោតលើសក្ខីកម្មទាំងអស់នេះ ដើម្បីយកជាភស្តុតាងមកបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីនេះអាចចាំពាក្យពេចន៍អ្វីដែលលោកបាន ខៀវ សំផន បាននិយាយតាំងពី៤០ឆ្នាំជាងមុននៅក្នុងវត្តរៀនសូត្រតាមការសន្មតនេះនោះ។ វាមិនអាចទៅរួចទេ។ ត្រង់ចំណុចនេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ និងភាគីមើលចម្លើយរបស់ អែម អឿន នៅថ្ងៃទី២៩ សីហា ឆ្នាំ២០១២។

[១៤:០៥:៤០]

ដើម្បីបញ្ចប់ទៅលើចំណុចនេះ ខ្ញុំសូមរំឮកថា ក្នុងក្របខ័ណ្ឌនៃការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់បានឆ្លើយថា ការរៀនសូត្រនេះគឺថាកើតឡើងតែបួនថ្ងៃទេ គឺសវនាការថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២។ ដូច្នេះដើម្បីយល់ឲ្យបានច្បាស់អំពីចំណុចនេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះកុំផ្អែកមូលដ្ឋានលើសក្ខីកម្មបែបនេះនោះ ដើម្បីពិភាក្សាសម្រេចនោះ។ បើសិនបើខ្ញុំផ្តល់ឧទាហរណ៍នេះគឺថា ខ្ញុំចង់បង្ហាញឲ្យឃើញអំពីការសួរដេញដោលនៅសវនាការ។ ការសួរដេញដោលនៅក្នុងសវនាការនេះមានសារៈសំខាន់ណាស់ ពីព្រោះថាបើយើងពិនិត្យ -- បើសិនជាយើងមិនមានសួរ អែម ហឿន *(ស៊ីក)* ទេ យើងមិនអាចដឹងទេ។ ហើយយើងឃើញថាអង្គជំនុំជម្រះបានទទួលយកឯកសាររាប់ពាន់ ដែលជាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដោយមិនមានការសួរដេញដោល។ ហើយវាអាចមានសក្ខីកម្មផ្សេងៗទៀតដូច អែម ហឿន (*ស៊ីក*) អ៊ីចឹងដែរដែលអាចមាននៅក្នុងកំណត់ហេតុទាំងអស់នោះ។

[១៤:០៦:០៤]

ហេតុនេះហើយ ទោះបីជាមានភាពប្រហាក់ប្រហែលគ្នានៃចម្លើយរបស់សាក្សីនោះ គឺថាវាបង្ហាញឲ្យឃើញអំពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់ខ្លួន។ ដូច្នេះយើងឃើញថាព្រះរាជអាជ្ញាគាត់ចង់ធ្វើយ៉ាងម៉េចឲ្យតែសាក្សីនិយាយអំពីអរិជ្ជមានពាក់ព័ន្ធនឹងលោក ខៀវ សំផន។ ដូចលោក គង់

សំអុន បានលើកឡើងហើយពាក់ព័ន្ធទៅនឹងអត្តចរិតរបស់គាត់ របស់លោក ខៀវ សំផន គឺមិនមែនជាសាក្សីរបស់មេធាវីការពារក្តីទេ។ ហើយមានអ្នកខ្លះគាត់និយាយអំពីអត្តចរិតវិជ្ជមានរបស់លោក ខៀវ សំផន។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលភស្តុតាងពាក់ព័ន្ធទៅនឹងវគ្គរៀនសូត្រ។

ទី១) លោក ខៀវ សំផន កម្រនឹងនិយាយនៅក្នុងវគ្គរៀនសូត្រណាស់។ កាលពីសវនាការខែកញ្ញា ឆ្នាំ២០១២ គឺថ្ងៃទី២០ គេនិយាយថា៖ "លោក ខៀវ សំផន កម្រនិយាយណាស់នៅក្នុងវគ្គរៀនសូត្រគឺមានតែ នួន ជា ទេ ដែលច្រើនជាអ្នកធ្វើបទឧទ្ទេសនាមនោះ។ នៅពេលដែលខ្ញុំចូលរៀននោះគឺថាខ្ញុំជួបបានតែម្តងគត់ លោក ខៀវ សំផន នោះ ហើយក្រៅពីហ្នឹងគឺសុទ្ធតែលោក នួន ជា ទាំងអស់ដែលជាអ្នកបើកវគ្គបង្រៀននោះ និងជាអ្នកបង្រៀន"។ ដូច្នេះវាបញ្ជាក់ឲ្យឃើញច្បាស់អំពីតួនាទីរបស់លោក នួន ជា ដែលគាត់មាននៅក្នុងការបង្រៀន។

[១៤:០៧:៥៣]

សាក្សីផ្សេងមួយទៀតគឺលោក សួង ស៊ីគឿន គឺថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២ គាត់បាននិយាយថា គាត់ចាំថា គាត់បានចូលរួមក្នុងវគ្គរៀនសូត្រនៅបុរីកីឡា ហើយគាត់ឃើញលោក ខៀវ សំផន ពីចម្ងាយក៏ប៉ុន្តែគាត់បានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ "ប៉ុល ពត និង នួន ជា ជាវាគ្មិននៅក្នុងវគ្គនោះ"។ ហើយនៅក្នុងសវនាការដដែលទាក់ទងទៅនឹងខ្លឹមសារនៃវគ្គរៀនសូត្រហ្នឹង ហើយពុំមានអ្វីទេដែលអាចធ្វើឲ្យយើងសន្និដ្ឋាន ដែលព្រះរាជអាជ្ញាសន្និដ្ឋានបាននោះទេ ពីព្រោះថាកាលណោះគេនិយាយអំពីស្ថានភាពទំនាក់ទំនងអន្តរជាតិនោះទេ។

នៅថ្ងៃទី០៦ សីហា ២០១២ ដដែល សួង ស៊ីគឿន បាននិយាយថា៖ "កាលណោះគេនិយាយពីការវិវត្តន៍នៃស្ថានភាពពីបដិវត្តន៍ប្រជាតិប្រជាជនទៅដល់បដិវត្តន៍សង្គមនិយម ហើយនិងការវិវត្តន៍ស្ថានភាពអន្តរជាតិ"។ សូមបញ្ចប់ការដកស្រង់។ អាហ្នឹងគេនិយាយពីការលើកឡើងរបស់ ខៀវ សំផន នៅក្ងុំបូ កាលណោះគឺថាយើងស្ថិតនៅក្នុងស្ថានភាពមួយដែលយើងត្រូវការបង្កើតនិចលភាពមួយផ្សេង។ មិនមែនមានត្រឹមតែ សួង ស៊ីគឿន ទេដែលនិយាយអំពីការកិច្ចប្រជុំបែបនេះនោះ។

[១៤:០៩:៣១]

មានសាក្សីផ្សេងទៀតដែលបាននិយាយផងដែរ ភី ភួន ដែលយើងស្គាល់ទាំងអស់គ្នា ហើយ គង់ សំអុន គាត់បាននិយាយអំពីលោក ភី ភួន នេះហើយ។ គាត់ក៏បាននិយាយដែរនៅសវនាការនៅថ្ងៃទី២៦ សីហា ២០១២ គាត់និយាយថា "អ្នកដែលដឹកនាំកិច្ចប្រជុំនោះមានតែ ប៉ុល ពត ហើយនិង នួន ជា ទេ"។

សូមបញ្ចប់ការដកសស្រង់។ គាត់បាននិយាយផងដែរ ក្រោយពេលដែលសហព្រះរាជអាជ្ញាបានសួរទៅគាត់ គាត់ថាគាត់មិនដែល -- គាត់ដូចជាមិនចាំពាក្យថា "កម្ទេច" ទេទាក់ទងនឹងខ្មាំងនេះ។ ពាក្យ "កម្ទេច" គាត់មិនចាំទេ។ នៅថ្ងៃទី៣០ហ្នឹងនៅថ្ងៃទី៣០ កក្កដា ឆ្នាំ២០១៣។

បន្ទាប់មកទៀតមាន ជីបសេ គាត់បាននិយាយថា នៅក្នុងវគ្គប្រជុំនេះមិនមានការជំរុញឲ្យធ្វើ សូមដកស្រង់៖ "ថាធ្វើអ្វីដែលមិនល្អនោះទេ ក៏ប៉ុន្តែមានការលើកទឹកចិត្តឲ្យ"។ សូមដកស្រង់៖ "ត្រូវតែខំកសាងខ្លួនដើម្បីកសាងប្រទេសជាតិ"។

[១៤:១០:៥១]

គាត់បានបន្ថែមផងដែរថា សូមដកស្រង់៖ "ត្រូវតែគិតពីចំណុចល្អៗដែលគេចង់បំពាក់បំប៉ន ដូចជាធ្វើតែល្អទៅលើអ្នកដទៃ កុំឲ្យធ្វើបាបលើអ្នកដទៃ ហើយនិងជួយអ្នកដទៃទៅតាមអ្វីដែលខ្លួនអាចធ្វើបាន។ ហើយ ឯក ហេន នោះគាត់ចាំមិនសូវច្បាស់ទេ គាត់ថាគាត់មិនដែលចាំរឿងចំណុចអាក្រក់ដែលលោក ខៀវ សំផន បាននិយាយប្រាប់ទេ។ សវនាការថ្ងៃទី២៣ ខែ៨ ឆ្នាំ២០១២ ខ្ញុំសូមដកស្រង់៖ "លោក ខៀវ សំផន បាននិយាយអំពីការតស៊ូ ហើយយើងត្រូវតែចេះជួយគ្នាទៅវិញទៅមក។ នេះសុទ្ធតែជាដំបូន្មានល្អនោះទេ"។ សូមបញ្ចប់ការដកស្រង់។

មានសាក្សីឈ្មោះ រស់ ស៊ុយ ដែលនិយាយអំពីដំបូន្មានបច្ចេកទេស គាត់និយាយអំពីអ្វីដែលលោក ខៀវ សំផន និយាយទាក់ទងទៅនឹងឃ្លាំង។ គាត់ថាគាត់និយាយថា៖ "លោក ខៀវ សំផន មិនដែលនិយាយ -- មិនដែលធ្លាប់ធ្វើវគ្គប្រជុំនយោបាយទេ គឺថាគាត់ធ្លាប់តែផ្តល់ព័ត៌មានផ្នែកបច្ចេកទេសឲ្យទេ។ នៅពេលដែលគាត់បានចូលរួមពេលប្រជុំនោះ ខៀវ សំផន មកនិយាយត្រឹមតែថាឲ្យថែរក្សាសម្ភារៈឲ្យបានល្អនោះទេ"។ សូមបញ្ចប់ការដកស្រង់។

[១៤:១២:២២]

លោក សៅ សារុន សវនាការថ្ងៃទី០៦ សីហា ឆ្នាំ ២០១២ ជាវគ្គសិក្សាដែលលោក ខៀវ សំផន ហើយ នួន ជា ហើយ ខៀវ សំផន ហ្នឹងបានចូលមកដំបូងបន្តិច ហើយចុងបន្តិច។ ហើយសវនាការថ្ងៃទី ០៦ មិថុនា ឆ្នាំ២០១២ នៅម៉ោង ០៩:៥៨។ "សំណួរ៖ តើលោកចាំទេថា គាត់បាននិយាយអំពីអ្វីដែលនៅពេលគាត់និយាយពីខាងផ្នែកសេដ្ឋកិច្ចនោះ? ចម្លើយ៖ គឺថាត្រូវដឹកនាំ ហើយនិងជំរុញឲ្យគេបង្កបង្កើនផលដើម្បីជៀសវាងទុរភិក្ស"។ សូមបញ្ចប់ការដកស្រង់។

នេះគឺជាការនិយាយដដែលៗគឺថា ធ្វើយ៉ាងម៉េចឲ្យជៀសវាងទុរភិក្សឲ្យបាន ហើយដែលយើង

ទាំងអស់គ្នាដឹងហើយថា មិនអាចចៀសវាងបាន។ នេះមិនមែនត្រឹមតែខ្មែរក្រហមទេបានលើកឡើងដូច្នេះនោះ របាយការណ៍អាមេរិកាំងទាក់ទងនឹងការផ្ដល់ជំនួយក៏អ៊ីចឹងដែរ។ សៅ សារុន ក៏បានបញ្ជាក់ដូចគ្នាអ៊ីចឹងដែរនៅឆ្នាំ២០១២ ដែលពេលដែលគាត់បានមកផ្ដល់សក្ខីកម្មនៅទីនេះ។ នៅកាលនោះនៅម៉ោងប្រហែលជា០៩:១៤នាទី សេចក្ដីណែនាំទាក់ទងទៅលើការអប់រំ ដឹកនាំប្រជាជន ហើយឲ្យគេខំបង្កបង្កើនផលក្នុងឋានៈជាប្រជាពលរដ្ឋ។ មានតែប៉ុណ្ណឹងទេ។

[១៤:១៤:០០]

អ៊ីចឹងមានធាតុផ្សំតិចណាស់ទាក់ទងទៅនឹងវគ្គរៀនសូត្រនេះ ដែលលោក ខៀវ សំផន បានផ្ដល់ជូនទៅអ្នកដែលចូលរួម មានទៅបញ្ញវន្តជាដើមនោះដូចលោក អុង ថុងហឿង ដែលរៀបរាប់អំពីពាក្យសម្ដីរបស់ប្រពន្ធគាត់។

ខ្ញុំសូមត្រឡប់បកមកក្រោយវិញទាក់ទងនឹង ភី ភួន ដដែល។ ការត្រឡប់មកក្រោយនេះសំខាន់ណាស់ ពីព្រោះថាសហព្រះរាជអាជ្ញាបាននិយាយថា សូមប្រយ័ត្នត្រង់ចំណុចនេះ៖ "គោលនយោបាយវាយប្រហារលើប្រជាជនថ្មី គោលនយោបាយវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលមានតាំងពីមុនឆ្នាំ១៩៧៥ យូរហើយ"។ ក៏ប៉ុន្តែនៅសម័យរណសិរ្ស ភី ភួន នៅថ្ងៃទី២៥ កក្កដា ឆ្នាំ២០១២ បានឆ្លើយថាសូមដកស្រង់៖ "បើតាមដែលខ្ញុំចាំនោះ ចំពោះកម្លាំងរណសិរ្សត្រូវតែប្រមូលផ្តុំកម្លាំងបញ្ញវន្ត ប្រមូលផ្តុំវាទាំងអស់គ្នា។ ហើយបន្ទាប់មកទៀត ត្រូវតែប្រមូលផ្តុំកម្លាំងនៅក្នុងប្រទេស ហើយវាមានការបែងចែកវណ្ណៈ អ៊ីចឹងត្រូវតែប្រមូលផ្តុំវណ្ណៈទាំងអស់តាមដែលធ្វើទៅបាន ដោយមិនប្រកាន់ថា កម្មករ កសិករអ្វីទេ ត្រូវប្រមូលវណ្ណៈទាំងអស់ហ្នឹងបញ្ចូលគ្នា"។ គាត់និយាយថា៖ "កម្លាំងជាតិត្រូវតែប្រមូលផ្តុំកម្លាំងផ្សេងៗ ហើយយើងត្រូវមានកម្លាំងប្រមូលផ្តុំមួយ ហើយត្រូវការកម្លាំងពីខាងក្រោមកផងដែរ"។ សូមបញ្ចប់ការដកស្រង់។

[១៤:១៥:៥៣]

ដូច្នេះអានេះប្រហែលជា -- នេះទំនងជា ខៀវ សំផន បាននិយាយយ៉ាងដូច្នេះនៅពេលដែលព្រះរាជអាជ្ញា និយាយថា៖ "ខៀវ សំផន នោះមានផែនការវាយប្រហារលើប្រជាជនថ្មីនេះ"។ អ៊ីចឹងនេះជាភស្តុតាងដែលមាននៅក្នុងសំណុំរឿង ហើយ ភី ភួន បានលើកឡើងដូចតទៅនេះ គឺថាប្រមូលកម្លាំងទាំងអស់ ដើម្បីគាំទ្របដិវត្តន៍ នេះពិតជាត្រឹមត្រូវហើយ និយាយអ៊ីចឹងមែន។

មាន ភិន គិន (*ស៊ីក*) ដែរសវនាការថ្ងៃទី១៧ ឧសភា ឆ្នាំ២០១២។ គាត់និយាយនៅម៉ោង

១០:១៣នាទី៖ "យើងធ្វើយ៉ាងណាឲ្យរីកចម្រើន ហើយធ្វើយ៉ាងណាឲ្យប្រជាជនមានអាហារគ្រប់គ្រាន់" អានេះនៅក្នុងឯកសារមាន។ សូមបញ្ចប់ការដកស្រង់។ ហើយនៅចំណុចនេះ គឺខ្ញុំសូមឲ្យលោក លោកចៅក្រមមើលជាភាសាខ្មែរ ព្រោះមានបញ្ហាបកប្រែជាភាសាបារាំង។ គឺឈ្មោះ ពាន ឃាន។

[១៤:១៧:០២]

ហើយមួយទៀតមាន អុង ថុងហឿង ដែលបាននិយាយអំពីសន្និសីទមួយដែល ខៀវ សំផន បានផ្តល់ជូននៅពេលដែលប្រពន្ធគាត់ត្រូវបាន -- ប្រពន្ធគាត់បានលើកឡើងដូចតទៅនេះ នៅឆ្នាំ២០១២ ខៀវ សំផន បាននិយាយថា៖ "យើងសុទ្ធតែជាអ្នកស្នេហាជាតិ ព្រោះថាយើងបានត្រឡប់ចូលមកប្រទេសខ្មែរវិញ ព្រោះថាប្រទេសត្រូវតែអភិវឌ្ឍ ហើយត្រូវការធនធានមនុស្ស ហើយយើងត្រូវតែលត់ដំខ្លួន"។ សូមបញ្ចប់ការដកស្រង់។

នេះគឺជាឧទាហរណ៍ដែលអ្វី ដែលទំនងជាសាក្សីទាំងអស់នេះបានលើកឡើង -- ដែល ខៀវ សំផន បានលើកឡើង។ នេះគឺជាអ្វីដែលខ្ញុំមិនបានលើកឡើងអង្គាល់ពីថ្ងៃសុក្រនោះ ខ្ញុំបញ្ចប់នៅថ្ងៃនេះ។ ហេតុអ្វីបានជាខ្ញុំនិយាយអំពីវគ្គប្រជុំទាំងអស់នេះ ពីព្រោះថាវាជាការសំខាន់ណាស់ទាក់ទងទៅនឹងបញ្ហាសហឧក្រិដ្ឋកម្មរួម ពីព្រោះថាវាជាសំខាន់ក្នុងការបង្ហាញអំពីចេតនាឧក្រិដ្ឋ។ បើសិនជាគំនិតទាំងអស់នេះ ខៀវ សំផន បាននិយាយហើយ ក៏ប៉ុន្តែមិនត្រូវបានអនុវត្ត។ អ៊ីចឹងយើងមិនអាចយកចាត់ទុកថា ខៀវ សំផន មានចេតនាឧក្រិដ្ឋនោះទេ។

[១៤:១៨:២៩]

វគ្គសិក្សាចុងក្រោយ គេហៅ "ការរៀនសូត្រ" កាលសម័យនោះ គឺនៅថ្ងៃទី០៥ កុម្ភៈ ឆ្នាំ១៩៧៩ -- មករា ឆ្នាំ១៩៧៩ វាហួសវិសាលភាពហើយ ក៏ប៉ុន្តែវាផ្តល់ព័ត៌មានមួយចំនួន។ អ៊ីចឹងខ្ញុំសូមនិយាយដោយសង្ខេប។ គេនិយាយថា មានសាក្សីបីនាក់បានលើកឡើងអំពីកិច្ចប្រជុំនៅខែមករា ឆ្នាំ៧៩នេះ មាន ស៊ឹម ម៉ៅ (*ស៊ឹក*), រស់ ស៊ុយ ហើយនិង ឌុច។ គាត់និយាយអំពីកិច្ចប្រជុំហ្នឹង ប៉ុន្តែឃើញមានកិច្ចប្រជុំពីរខុសគ្នា ក៏ប៉ុន្តែយ៉ាងណាក្តីយើងដឹងថា នៅថ្ងៃនោះ ខៀវ សំផន ទំនងជាបានប្រាប់អំពីការដែលវៀតណាមជិតមកដល់ហើយ។ កិច្ចប្រជុំនេះបានលើកឡើងដោយសហព្រះរាជអាជ្ញាដើម្បីនិយាយថា ខៀវ សំផន ប្រហែលជាបាននិយាយប្រឆាំងនឹងខ្មាំងវៀតណាម។

ត្រង់ចំណុចនេះ ខ្ញុំគ្រាន់តែចោទសួរខ្លួនឯងទេថា ឥឡូវយើងនៅថ្ងៃទី០៥ មករា ឆ្នាំ១៩៧៩ យើងដឹងថា វៀតណាមជិតមកដល់ហើយ គេនឹងគេមកវ៉ៃនៅថ្ងៃបន្ទាប់ហ្នឹងមួយថ្ងៃហ្នឹង ក្រោយហ្នឹងមួយ

ថ្ងៃ។ អ៊ីចឹងនៅពេលដែលកងទ័ពវ៉ៃប្រហារលើប្រទេសមួយនោះ ខ្ញុំមិនដឹងថា ហៅថាយ៉ាងម៉េចទេ ប្រហែលជាវាធម្មតា កាលណាយើងទៅវ៉ៃប្រទេសគេ អ្នកដែលនៅក្នុងប្រទេសហ្នឹងគេថា យើងជាខ្មាំងហើយ។

[១៤:១៩:៥៦]

ចំណុចមួយទៀតសំខាន់ដែរ ខុសពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺថាជាភស្តុតាងដែលបង្ហាញថា គាត់ឲ្យគេគិតពីខ្មាំងផ្ទៃក្នុង។ ប៉ុន្តែ ស៊ឹម ហោ បាននិយាយថា "ខៀវ សំផន ប្រហែលជាឲ្យគាត់ជីកត្រង់សេវិញទេ ឲ្យពួកគាត់ជីកត្រង់សេការពារខ្លួនទេ"។ ឈ្មោះ ស៊ឹម ហោ៖ "ខ្ញុំមិនដឹងថាដើម្បីវ៉ៃប្រហារ ឬដើម្បីអ្វីទេ ក៏ប៉ុន្តែគាត់ណែនាំឲ្យជីកត្រង់សេដើម្បីការពារខ្លួនយើង ហើយដើម្បីជៀសកុំឲ្យត្រូវគ្រាប់ផ្លោង។ តើយើងទៅវ៉ៃអ្នកណាបើយើងគ្រាន់តែជាកម្មករ ហើយយើងអត់មានកាំភ្លើងផងនោះ"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងជីកត្រង់សេដើម្បីការពារខ្លួនពីគ្រាប់តែប៉ុណ្ណឹងទេ។

មានចំណុចមួយទៀតសំខាន់ដែរ នៅក្នុងទំនាក់ទំនងអង្គហេតុដែល ស៊ឹម ហោ បានលើកឡើង៖ "ថ្ងៃនោះ ខៀវ សំផន ទំនងជាបាននិយាយថា អ្នកទាំងអស់គ្នាហ្នឹងត្រូវចេញទៅបាត់ហើយ នៅតែ ខៀវ សំផន ទេ"។ គាត់បានផ្តល់សក្ខីកម្មនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។ ដូច្នេះសហព្រះរាជអាជ្ញាកំពុងតែនិយាយថា ពេលដែលកំពុងតែបាក់ទ័ពនេះថា ខៀវ សំផន ហ្នឹងមានអំណាចខ្លាំងនៅមជ្ឈិមនៅអ៊ីអ៊ីចឹង។ អ៊ីចឹងគួរឲ្យឆ្ងល់ណាស់ អ៊ីចឹងព្រះរាជអាជ្ញាលើកឡើងនេះដូចមិនត្រូវទេ។

[១៤:២១:៣៣]

ឥឡូវខ្ញុំបញ្ចប់ទាក់ទងទៅនឹងវគ្គរៀនសូត្រនេះ ហើយខ្ញុំចូលទៅនិយាយអំពីកិច្ចការពាណិជ្ជកម្មវិញ។ សកម្មភាពរបស់ ខៀវ សំផន ក្នុងឋានៈជាប្រធានពាណិជ្ជកម្មទេ ប៉ុន្តែទាក់ទងនឹងពាណិជ្ជកម្ម។ ខៀវ សំផន តែងតែរៀបរាប់អំពីការងាររបស់ខ្លួននៅក្នុងមន្ទីរ៨៧០ ក្នុងឋានៈខ្លួនជាអ្នកដែលធ្វើការទាក់ទងនឹងពាណិជ្ជកម្មទេ។ ហើយវាជាការគួរឲ្យចាប់អារម្មណ៍ណាស់ ដែលដូចគ្នាដែរដែលព្រះរាជអាជ្ញាសុំឲ្យយើងបកស្រាយតែផ្តេសតែផ្តាសដើម្បីបង្ហាញឲ្យឃើញថា ខៀវ សំផន នោះជាប្រធានមន្ទីរ៨៧០។ អ៊ីចឹង គឺថាមានការបំភ្លៃភស្តុតាងផងដែរដើម្បីឲ្យគេនិយាយថា ខៀវ សំផន ជាប្រធានពាណិជ្ជកម្មទៀតផង។

ដូចសហភាតា អាកទួរ វែកគែន របស់ខ្ញុំបានលើកឡើងហើយ គឺថាបន្ទាប់ពីពេលដែលគាត់ជំនួស ឌឿន ហ្នឹងគឺថាធ្វើឡើងនៅឆ្នាំ១៩៧៧ទេ។ អ៊ីចឹងវាហួសវិសាលភាពហើយទាក់ទងនឹងតួនាទី

របស់ ខៀវ សំផន ហ្នឹងចំពោះអង្គហេតុដែលយើងត្រូវជម្រះសេចក្ដីនៅទីនេះ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ យើងត្រូវតែចាប់អារម្មណ៍ទៅលើសកម្មភាពរបស់គាត់ ទាក់ទងនឹងពាណិជ្ជកម្ម ពីព្រោះថាសហព្រះរាជអាជ្ញាបានលើកឡើងថា វាគឺជាគន្លឹះនៃការអនុវត្តការជម្លៀសប្រជាជនវគ្គទី២។

[១៤:២៣:០៥]

ក៏ប៉ុន្តែយើងជាខាងការពារក្ដី សូមលើកឡើងថា ខៀវ សំផន គ្រាន់តែធ្វើការងារបច្ចេកទេសនៅក្នុងផ្នែកពាណិជ្ជកម្មប៉ុណ្ណឹងទេ។ ហើយមានធាតុផ្សំមួយទៀតសំខាន់ណាស់ដែលគាត់មានតំណែងដាច់ដោយឡែក ហើយគេនិយាយថាគាត់នៅមជ្ឈិម គាត់នៅស្នូល។ សហភាតាខ្ញុំបានលើកឡើងហើយ គឺថាគាត់ដូចអ្នកដទៃផ្សេងទេ គាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ។ បើសិនជាគាត់នៅមជ្ឈិម ហើយបើនិយាយថា គាត់ហ្នឹងជាស្នូលនៃអំណាច តើហេតុអ្វីបានជានៅពេលដែលយើងនិយាយអំពីការតែងតាំងនៅឆ្នាំ១៩៧៥ នៅក្នុងគណៈពាណិជ្ជកម្មនោះ ថាម៉េចក៏មិនមែនជាអ្នកតែងតាំងទេ?

អ៊ីចឹងព្រះរាជអាជ្ញាមិនព្រមឆ្លើយទេចំណុចនេះ ព្រោះថាៗយើងត្រូវតែ -- បើកាលណាឆ្លើយនឹងសំណួរនេះ យើងត្រូវតែមានទស្សនៈផ្សេងហើយទាក់ទងទៅនឹងតំណែងរបស់ខៀវ សំផន នោះ។ អ៊ីចឹងត្រូវទុកចំណុចនេះចោលដោយឡែក។

[១៤:២៤:១២]

នៅឆ្នាំ១៩៧៥ យើងដឹងហើយថា ចំណុចសំខាន់គឺត្រូវស្ដារសេដ្ឋកិច្ចឡើងវិញ និងស្ថានភាពពាណិជ្ជកម្មឡើងវិញ ក៏ប៉ុន្តែពុំមានអ្នកណាដែលមានលទ្ធភាពក្នុងការបំពេញការងារបច្ចេកទេសនេះទេ។ ខ្ញុំសូមយោងទៅឯកសារគណៈអចិន្ត្រៃយ៍មួយ E3/230, E3/238 ដែលនៅក្នុងឯកសារទាំងអស់នេះសហភាតាខ្ញុំបាននិយាយហើយចំណុចទាំងនេះ។ និយាយអំពីការផ្លោះប្ដូររវាងមិត្តភក្ដិ -- ប្រទេសជាមិត្តថ្នាំ ហើយនិងស្បៀងអាហារជាដើម ហើយនិងការបែងចែងស្បៀងអាហារទៅតាមមូលដ្ឋាន។

នួន ជា ក៏បាននិយាយពីចំណុចហ្នឹងដែរ ហើយ ស៊ីគៀន, ស្បូត ក៏អ៊ីចឹងដែរ។ គាត់និយាយថា សេចក្ដីសម្រេចទាំងអស់នោះត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍។ ហើយស្នួង ស៊ីគៀន បាននិយាយនៅថ្ងៃទី០៨ សីហា ឆ្នាំ២០១២ ហើយថា៖ “ក្រសួងជាច្រើនមានតែនៅលើក្រដាសទេ ហើយមិនមានរចនាសម្ព័ន្ធអីច្បាស់លាស់នោះទេ”។

ហ្វីលីព ស្បូត ក៏លើកឡើងយ៉ាងដូច្នេះដែរ នៅសវនាការថ្ងៃទី០៦ ឧសភា ២០១៣ គាត់និយាយដូចតទៅនេះ៖ “សិទ្ធិសម្រេចនោះនៅក្នុងគណៈអចិន្ត្រៃយ៍ ទោះបីជាមានក្រសួងក៏ដោយ ក៏ក្រសួងទាំង

អស់នេះពុំមានសិទ្ធិសម្រេចអីទេ គ្រាន់តែមានសិទ្ធិបញ្ជូនសេចក្ដីសម្រេចបន្តតែប៉ុននុ៎ងទេ”។

[១៤:២៦:០៤]

ឯកសារ E3/182 ជាកំណត់ហេតុកិច្ចគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែ១០ ឆ្នាំ៧៥។ គណៈអចិន្ត្រៃយ៍តែងតាំងសមមិត្ត ហែម ជាប្រធានរណសិរ្សនៃរាជរដ្ឋាភិបាល ហើយពាណិជ្ជកម្ម បញ្ជី និងតម្លៃ។ ឯកសារចុះថ្ងៃទី១៣ ខែ៣ ឆ្នាំ៧៦ គណៈអចិន្ត្រៃយ៍សម្រេចបង្កើតគណៈពាណិជ្ជកម្មដើម្បីពិនិត្យហើយនិងរៀបចំទំនិញដែលត្រូវទិញ។

លោក លោកប្រធាន! ឯកសារ E3/234 នេះ មិនមែនជា ខៀវ សំផន ទេ ខៀវ សំផន គ្រាន់តែសមាជិកទេ។ អ៊ីចឹងនៅក្នុងកិច្ចប្រជុំនោះ ខៀវ សំផន ត្រូវបានគេតែងតាំងឲ្យធ្វើជាប្រធានដើម្បីដោះស្រាយបញ្ហាធនាគារ ហើយ សគឹម ល្អុត គាត់ដឹងពីរឿងហ្នឹងសម្បើមណាស់។

នៅថ្ងៃទី១៤ មេសា ឆ្នាំ១៩៧៦ ឯកសារ E3/262 គេដឹងថា ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ។ ក៏ប៉ុន្តែផ្ទុយទៅវិញ តើគាត់គ្រាន់តែជា -- តើអ្នកណាជាអ្នក -- តាមពិត វន វ៉េត ទេ ដែលជាអ្នកទទួលបន្ទុកខាងសេដ្ឋកិច្ចនោះ ជាឧបនាយករដ្ឋមន្ត្រី គាត់កាលណោះ។ អ៊ីចឹងសារណារបស់សហព្រះរាជអាជ្ញា គាត់និយាយថា ខៀវ សំផន នោះជាសមាជិកគណៈអចិន្ត្រៃយ៍ពេញសិទ្ធិទៀតផង។ នេះមិនត្រឹមត្រូវទេ។ វន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច ហើយគាត់ -- ថាគាត់ជាប្រធាន --។ អ៊ីចឹងគឺ វន វ៉េត ទេ ដែលបន្ទុកខាងគ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ចនេះទាំងអស់។

[១៤:២៨:២៤]

ពីរបីថ្ងៃក្រោយមកទៀត ឯកសារ E3/236 គឺជាសេចក្ដីសង្ខេបនៃកិច្ចប្រជុំនៅថ្ងៃទី១៩, ២០, ២១ មេសា ឆ្នាំ៧៦ គឺថាមានអង្គការលេខ និងគណៈដែលគណៈទាំងប៉ុន្មានដែលនៅក្រោម៨៧០។ គឺកាលនុ៎ងមានតែឈ្មោះ វិត, ញ៉ែម ហើយនិង ឈឿន ទេ អត់មាន ខៀវ សំផន ទេ។ ហើយ ខៀវ សំផន ត្រូវបានតែងតាំងនៅថ្ងៃទី២១ មេសា ឆ្នាំ១៩៧៦ទេ គឺក្នុងឯកសារហ្នឹងមានសរសេរថា គាត់ត្រូវតែងតាំងដោយ អ៊ំ វ៉ាន់ គឺ អៀង សារី។ ខ្ញុំសូមលើកឧទាហរណ៍ ទាក់ទងទៅនឹងបញ្ហាពាណិជ្ជកម្ម និងឧស្សាហកម្ម។ ហើយនៅអម ទូច ហើយផ្នែកការិយាល័យ ហើយនិងផ្នែកនិងជំនួយការបច្ចេកទេស។ ហើយគឺត្រង់ចំណុចនេះហើយ អស់លោក លោកស្រីចៅក្រម គឺថានេះទំនាក់ទំនងរបស់លោក ខៀវ សំផន ជាមួយ ៨៧០ នេះគឺថាគាត់មិនមែនជាប្រធានទេ។ មិនមែនថាគាត់គ្រប់គ្រងលើ៨៧០ទេ គឺថាគាត់ព្រោះថាដល់ឆ្នាំ-- ខែ៤ ៧៦ ហើយទេ ដែលគាត់មក គេតែងតាំងគាត់ឲ្យមកជួយខាងផ្នែកបច្ចេកទេស

ទេ។ ហើយគាត់បានជួយមែន ផ្នែកបច្ចេកទេសនេះ ហើយមានសាក្សីជាច្រើនបានបង្ហាញថា គាត់បានជួយផ្នែកបច្ចេកទេសមែន។

[១៤:២៩:៥៧]

ហើយនៅខែឧសភា ឆ្នាំ១៩៧៦ ឯកសារ E3/220 គឺ ខៀន ទេ ដែលជាអ្នកបង្កើតគណៈកម្មាធិការមួយដើម្បីពាណិជ្ជកម្មក្រៅប្រទេសនោះ មិនមែនលោក ខៀវ សំផន ទេ។ ដូច្នេះការងាររបស់លោក ខៀវ សំផន នៅមន្ទីរ៨៧០ ហ្នឹងគឺថាមានផ្ទុះបញ្ចាំងនៅក្នុងនេះ សក្តីកម្មទាំងអស់នេះ ឯកសារទាំងអស់នេះ។

សហព្រះរាជអាជ្ញាបាននិយាយថា ផ្នែកពាណិជ្ជកម្ម ទូរលេខបានបង្ហាញថា ខៀវ សំផន មានជាអ្នកគ្រប់គ្រងគណៈពាណិជ្ជកម្មនេះ។ គឺឯកសារ E3/340 មិថុនា ឆ្នាំ១៩៧៧ ដែលនិយាយអំពីការលក់សម្ភារៈទៅយូហ្គោស្លាវី ហើយមានស៊ីញ៉េរបស់លោក វ៉ាន់ រិទ្ធ ហើយឯកសារនេះ សគឹម លុត បានធ្វើអត្ថាធិប្បាយ។ ខ្ញុំសូមដកស្រង់ ERN ជាភាសាបារាំងគឺ 00167627 មានលើកឡើងថា៖ "បងហែមបានឲ្យយើងដឹង -- បានប្រាប់យើងថា បងវន មិនចង់ទិញសម្ភារៈទាំងអស់នេះទេ ហើយសូមឲ្យយើងសូមទោសដល់ៗក្រុមហ៊ុនរុនណាប់"។ អ៊ីចឹងគាត់និយាយថា បងហែម ថាបងវន មិនចង់ទេ អ៊ីចឹងអានេះបានបញ្ជាក់ថា មិនមែនបញ្ជាក់ថា វន វេត ទេជាមេនោះ។

[១៤:៣១:៣៧]

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅពេលដែលរបាយការណ៍ទៅជំនួបជាមួយនឹងកូរ៉េ ចម្លងជូនទៅលោក ខៀវ សំផន នេះ មិនមែនផ្ញើជូនទេ ចម្លងជូន។ គឺឯកសារ E3/2040 -- 2041 (សូមទោស) ៖"គំនិតយោបល់របស់យើងៗរង់ចាំសេចក្តីសម្រេចរបស់អង្គការ"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងពាក្យដែលថា "យោបល់" នេះគឺថាអ្នកសរសេររបាយការណ៍នេះទេ ហើយក្រោយមកទៀតអង្គការជាអ្នកសម្រេច មិនមែន ខៀវ សំផន ទេជាអង្គការ មិនមែនគេ -- គេមិនចាំសេចក្តីសម្រេចលោក ខៀវ សំផន ទេ។ ហើយឯកសារផ្សេងទៀត ក៏បញ្ជាក់យ៉ាងដូច្នេះដែរ។ ឯកសារ E3/2038, E3/2040, E3/2041 ហើយខាងព្រះរាជអាជ្ញានោះគេធ្វើជាមិនដឹងមិនឮថា គេថាដូចថាឯកសារណាដែលត្រូវបញ្ជូនទៅ ខៀវ សំផន បញ្ជូនទៅអង្គការអីជាដើមនេះ។

អ៊ីចឹងចំណុចមួយទៀតដែលយើងត្រូវតែកត់សម្គាល់នោះ គឺថា ឯកសារទាំងអស់នេះសុទ្ធតែចម្លងជូនទៅ ខៀវ សំផន។ ហើយកាលនោះ ខៀន ជាប្រធានពាណិជ្ជកម្មហើយ ហេតុអីបានចម្លងជូន

ឲ្យ ខៀវ សំផន? ពីព្រោះអី? ពីព្រោះគាត់គ្រាន់តែជាអ្នកជំនួយការផ្នែកបច្ចេកទេសនៃការិយាល័យ -- នៃមន្ទីរ៨៧០នេះទេ។

[១៤:៣៣:០៧]

ចំណុចសំខាន់មួយទៀត នេះវាហួសពីវិសាលភាពហើយ ក៏ប៉ុន្តែយើងអាចនិយាយដើម្បីបំបាត់តម្លៃអំណះអំណាងរបស់ព្រះរាជអាជ្ញាបាន។ កុម្ភៈ ឆ្នាំ១៩៧៧ មានគណៈប្រតិភូយូហ្គោស្លាវីបានមកប្រទេសកម្ពុជា ខែកុម្ភៈ ឆ្នាំ១៩៧៥ -- ៧៧ ហើយគាត់ ខៀវ សំផន បានទទួលតែងតាំងជាប្រធានគណៈប្រធានរដ្ឋ មិនមែនគាត់ទេជាអ្នកទៅជជែករឿងពាណិជ្ជកម្មនោះ កាលនោះជា វន វេត ទេ។ ហើយដោយកាលនោះស្ថានទូតយូហ្គោស្លាវីបានរៀបចំពិធីជប់លៀងមួយ ដើម្បីជាកិត្តិយសដល់ វន វេត ទេ មិនមែនជាកិត្តិយសដល់លោក ខៀវ សំផន ទេ។

ហើយមានឯកសារមួយ គឺឯកសារ E3/1485 កន្លែងនេះចង់បង្ហាញថា ព្រះរាជអាជ្ញាមានអំណះអំណាងខុសហើយ។ មានឧទាហរណ៍ផ្សេងទៀត ពីព្រោះថាក្រោយពី វន វេត ទៅ ខៀវ សំផន មកជំនួសខាងពាណិជ្ជកម្ម។ នៅខែធ្នូ ឆ្នាំ១៩៧៨ គឺ អៀង សារី ជាអ្នកដឹកនាំការចរចាជាមួយប្រទេសជាមួយចិន។ ដូចមានឯកសារ E3/1639 ដែលជាកំណត់ហេតុនៃកិច្ចប្រជុំពិភាក្សាចរចាខាងពាណិជ្ជកម្ម។

[១៤:៣៤:៤៨]

ឯកសារមួយទៀត E3/829 ដែលនិយាយជារបាយការណ៍នៃជំនួបនេះ មិនមែនជា ខៀវ សំផន ជាអ្នកដឹកនាំការចរចាតម្លៃនោះ កាលនោះ គឺ អៀង សារី ហើយនិង វ៉ាន់ រិទ្ធ ទេ។ អ៊ីចឹងយើងកត់សម្គាល់ថា អ៊ីចឹងគឺថាទស្សនៈរបស់ព្រះរាជអាជ្ញានេះមិនត្រឹមត្រូវទេដែលថា ខៀវ សំផន ហ្នឹងបានជំនួស ខឿន នោះ។មានចំណុចមួយទៀត ដែលសំខាន់ ពីព្រោះថាសហព្រះរាជអាជ្ញានៅក្នុងពេលដែលខ្លួនបង្ហាញឯកសារគន្លឹះទាក់ទងនឹងពាណិជ្ជកម្មនោះ គាត់ព្យាយាមក្នុងការធ្វើឲ្យច្របូកច្របល់ មានលក្ខណៈជាប្រព័ន្ធ ហើយនិងគឺថាឯកសារមួយចំនួនផ្ញើទៅ ខៀវ សំផន ហើយផ្ញើទៅគេផង។ អ៊ីចឹងគាត់ច្របូកច្របល់ឯកសារទាំងអស់នោះ ធ្វើហាក់ដូចជាយើងមិនអាចបែងចែកបានអ៊ីចឹង។ អ៊ីចឹងយើងសង្កេតឃើញថាលិខិតមួយចំនួនដែលបានផ្ញើទៅ ខៀវ សំផន ចំឈ្មោះនោះមានទាក់ទងតែយូហ្គោស្លាវី ហើយនិងកូរ៉េទេ។ ដោយសារគាត់មានឋានៈជាអ្នកជំនួយការផ្នែកបច្ចេកទេស ហើយដើម្បីសម្រេចលើអ្វីដែលត្រូវទិញ អ្វីដែលត្រូវមិនទិញនោះ។ ឯកសារមួយទៀត E3/2040, E3/2041

ទាំងអស់នេះសុទ្ធតែជូនទៅ បងហែម ជាទីស្រឡាញ់។

[១៤:៣៦:២១]

អ៊ីចឹងនៅពេលដែលយើងពិនិត្យមើលចំណុចដែលស្មុគ្រស្មាញជាងហ្នឹង យើងពិនិត្យមើលឯកសារដែលមានលក្ខណៈសម្ងាត់ជាងហ្នឹង ហើយឬក៏សំខាន់ទាក់ទងទៅនឹងការគ្រប់គ្រងនោះមិនមែនគេផ្ញើឲ្យ ខៀវ សំផន ទេឯកសារទាំងអស់នេះគេផ្ញើទៅអង្គការទេ។ អ៊ីចឹងហើយបានឃើញមានភាពខុសគ្នា។

លោកប្រធានខ្ញុំចង់ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមបញ្ចប់ត្រង់ចំណុចនេះ ហើយមុននឹងសម្រាកលោកប្រធាន បើសិនលោកប្រធានអនុញ្ញាត។

ឯកសារដែលមិនឃើញមានឈ្មោះ ខៀវ សំផន ទេគឺឯកសារ E310/1902 ហើយគេផ្ញើឯកសារនេះទៅអង្គការជាទីស្រឡាញ់។ ហើយចម្លើយទៅនឹងឯកសារនេះ គឺថាអត់មានអីច្បាស់លាស់ទេ គ្រាន់តែដាក់ថាគណៈពាណិជ្ជតែប៉ុណ្ណឹង។

[១៤:៣៧:២៣]

អ៊ីចឹង ខៀវ សំផន គាត់មិនមែនជាប្រធានពាណិជ្ជកម្មទេ។ ឯកសារ E3/875 ខ្ញុំដឹងតាមរយៈអង្គការ។ ឯកសារ E3/1907 អង្គការបានជូនដំណឹងមកយើងអំពីសំបុត្រនេះហើយ។ អ៊ីចឹងអ្វីៗទាំងអស់ត្រូវបានជូនដំណឹងដោយអង្គការ ការគ្រប់គ្រងរបស់អង្គការមិនមែនដោយ ខៀវ សំផន ទេ។ ក៏ប៉ុន្តែទន្ទឹមនឹងហ្នឹង សហព្រះរាជអាជ្ញានោះចង់ធ្វើឲ្យយើងធ្វើការសន្និដ្ឋានដោយងាយពេក ទាញការសន្និដ្ឋានងាយពេក បើតាមយើងមើលឯកសារអស់នេះ វាច្បាស់លាស់ហើយមានការបែងចែករវាងអង្គការ និង ខៀវ សំផន។

លោកប្រធានខ្ញុំសូមសម្រាកត្រង់នេះ បើសិនជាលោកប្រធានអនុញ្ញាតមុននឹងចូលទៅចំណុចថ្មី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដល់សមល្មមសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ លោកប្រធាន។ មុនពេលឈប់សម្រាកខ្ញុំបាននិយាយដល់ត្រឹមការពិនិត្យឯកសារដែលសហព្រះរាជអាជ្ញាចង់ផ្សាភ្ជាប់ទៅនឹងលោក ខៀវ សំផន ទោះបីជាមិនមានភស្តុតាងអ្វីមួយដែលផ្សាភ្ជាប់ក៏ដោយ។ ហើយមូលហេតុដែលខ្ញុំនិយាយអំពីបញ្ហាឯកសារនេះដោយសារថា នេះជារបៀបមួយនៃការច្របូកច្របល់គ្នារវាងឯកសារផ្សេងៗ ដែលហាក់ដូចជាមើលទៅដូចអត់មានព្រំដែនកម្រិតឯកសារអ៊ីចឹង គឺថាឯកសារយកមកដាក់ច្របូកច្របល់ដូចជាអត់មានការខណ្ឌចែក បែងចែកឲ្យបានត្រឹមត្រូវ ដូចអត់មានការគោរពតាមវិសាលភាពនៃការកំណត់របស់អង្គជំនុំជម្រះ។

ដូច្នេះហើយគឺខាងសហព្រះរាជអាជ្ញាដាក់ថា ខៀវ សំផន ជាប្រធានគណៈពាណិជ្ជកម្ម ទោះបីជាឯកសារបានបង្ហាញថា គាត់មិនមែនជាប្រធានក៏ដោយ។ គឺថាគាត់បានអះអាងថាដោយសារតែលោក ខៀវ សំផន បានបង្រៀននៅក្នុងវគ្គរៀនសូត្រអំពីពាណិជ្ជកម្មជាដើម និយាយអំពីការចាប់ខ្លួនជាដើម ឬក៏ការបាត់ខ្លួន គាត់ចោទថាលោក ខៀវ សំផន ជាប្រធានគណៈពាណិជ្ជកម្ម។ ដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញនៅក្នុងពេលសវនាការអំពីឯកសារគន្លឹះអ៊ីចឹង គឺជាការបំភ័ន្តទាំងស្រុង ពីព្រោះថាឈ្មោះលោក ខៀវ សំផន មិនមានលេចឡើងនៅក្នុងឯកសារទេ។ ឧទាហរណ៍ ដូចជាឯកសារលេខ E3/962, E3/174 និង E3/846 ដែល ចេញផ្ទាល់ពីគណៈពាណិជ្ជកម្មនោះ យើងក៏អត់មានឃើញឈ្មោះលោក ខៀវ សំផន ជាប្រធានដែរ។

[១៥:០៣:៣៥]

ចំណុចសំខាន់មួយទៀតដែលបង្ហាញអំពីការសន្និដ្ឋានសរុបទូទៅ ដែលជាការបំប្លែងតាំងពីពេលស៊ើបអង្កេតមកម្ល៉េះ។ យើងមើលឃើញច្បាស់ណាស់នៅពេលដែលលោក សគឹម ល្មុត បានមកផ្តល់សក្ខីកម្ម។ គាត់ជាសាក្សីដ៏សំខាន់ពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម។ លោក សគឹម ល្មុត បានឆ្លើយនៅក្នុង

សវនាការកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២។ ខ្ញុំសូមដកស្រង់៖ “នៅសម័យនោះអត់មានទំនាក់ទំនងជាមួយ ហែម ទេ។ ធនាគារមិនធ្វើរបាយការណ៍ទៅ ហែម ទេ ហើយក៏មិនមានទំនាក់ទំនងជាមួយ ហែម ដែរធនាគារនោះ”។ សំណួរសួបញ្ជាក់៖ “ដើម្បីជាការបញ្ជាក់នោះ គឺមានន័យថាលោកមិនដែលធ្លាប់ជួប ហែម ទេមែនទេ នៅពេលដែលលោកជាអនុប្រធានធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជានោះ?” ចម្លើយរបស់គាត់គឺ៖ “បាទ ពិតណាស់គឺមិនដែលបានជួបទេ”។ សូមបញ្ចប់ការដកស្រង់។

នេះបញ្ជាក់ថា សតឹម ល្មុត គាត់បាននិយាយយ៉ាងច្បាស់កាលពីសវនាការនោះ។ គេសួរគាត់ថា “តើនៅក្នុងពេលនុ៎ងលោកធ្លាប់ជួប ឬក៏ធ្វើការជាមួយលោក ខៀវ សំផន ទេ?” គាត់ឆ្លើយថា “អត់ទេ”។ នេះជាសាក្សីគន្លឹះពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម ដែលអាចនិយាយអំពីសកម្មភាពរបស់លោក ខៀវ សំផន បាន។ គាត់ៗជាអ្នកបកប្រែឯកសារឲ្យលោក ខៀវ សំផន ក៏ប៉ុន្តែនៅពេលដែលយើងបង្ហាញឯកសារឲ្យគាត់ផ្តល់មតិអត្ថាធិប្បាយ ហើយខ្ញុំបានជំទាស់នោះ អង្គជំនុំជម្រះបានបដិសេធការជំទាស់របស់ខ្ញុំ។ គាត់និយាយថា គាត់ឃើញឯកសារទាំងអស់នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតទេ គឺថាអ្នកស៊ើបអង្កេតបានបង្ហាញឯកសារទេ បានគាត់ដឹងថាមានឯកសារនោះ។ ហើយគេសួរគាត់ដូចជាគាត់អ្នកជំនាញអ៊ីចឹង មិនមែនសួរក្នុងនាមជាសាក្សីទេ។

[១៥:០៥:៥៣]

ហើយគាត់បាននិយាយយ៉ាងទៀងត្រង់នៅក្នុងសវនាការ។ សំណួរគេបានសួរថា “ខ្ញុំសូមសង្ខេបអ្វីដែលលោកអាន លោកទើបតែនិយាយ គឺលោកមិនដឹងអំពីទំនាក់ទំនងរបស់ឈ្មោះ ហែម ជាមួយនឹងគណៈសេដ្ឋកិច្ច និងពាណិជ្ជកម្មមុនពេលដែលអ្នកស៊ើបអង្កេតបង្ហាញឯកសារលោកទេមែនទេ?” ចម្លើយរបស់គាត់នៅពេលនោះ៖ “បាទ ពិតណាស់។ ការស្មាននេះ ខ្ញុំសូមកត់សម្គាល់សង្កត់ធ្ងន់ទៅលើពាក្យស្មាន គឺថាដោយខ្ញុំផ្អែកទៅលើឯកសារដែលចៅក្រមស៊ើបអង្កេតបានបង្ហាញខ្ញុំទេ ទើបខ្ញុំទាញការស្មាននោះ”។ នេះជាភស្តុតាងបង្ហាញឲ្យឃើញច្បាស់ ដែលជាការបំភ្លៃចំពោះឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។

ក៏ប៉ុន្តែមានចំណុចមួយដែលលោក សតឹម ល្មុត បានបញ្ជាក់ ហើយជាចំណុចសំខាន់គួរឲ្យចាប់អារម្មណ៍ ហើយវាមិនស៊ីគ្នាទៅនឹងទស្សនៈរបស់សហព្រះរាជអាជ្ញានោះ គឺថា វ៉ាន់ រិទ្ធ បន្តពី ខៀន ជាប្រធានពាណិជ្ជកម្ម។ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ ក្នុងសវនាការ លោក សតឹម ល្មុត បានពន្យល់ថា ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលឯកសារច្បាប់ដើមជាភាសាខ្មែរ ពីព្រោះថា ប្រហែលជាមានបញ្ហា

បកប្រែ។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំមិនបានជួប វ៉ាន់ រិទ្ធ ភ្លាមទេនៅពេលដែលខ្ញុំមកដល់ភ្នំពេញនោះ ក៏ប៉ុន្តែគឺជួបនៅពេលដែលមានកែប្រែរចនាសម្ព័ន្ធពាណិជ្ជកម្ម ហើយគេដក ឌឿន ចេញ។ ពេលហ្នឹងហើយបានខ្ញុំជួប វ៉ាន់ រិទ្ធ នោះនៅពេលគាត់មកជំនួស ឌឿន”។ សូមបញ្ចប់ការដកស្រង់។

[១៥:០៧:៣៣]

ដូច្នេះ សគីម ល្មុត បាននិយាយថា គាត់បានជួប វន វ៉េត, គាត់បានជួប វ៉ាន់ រិទ្ធ ក៏ប៉ុន្តែគាត់មិនដែលជួបលោក ខៀវ សំផន នោះទេ។

ដូច្នេះយើងឃើញថាវាមិនអាចទទួល -- យើងមិនអាចទទួលយកបានទេ ដែលអ្នកស៊ើបអង្កេតគាត់ជំរុញឱ្យសាក្សីនេះឆ្លើយស្មាន ហើយសហព្រះរាជអាជ្ញាតវ៉ាថា ទេ! អត់ទេ សាក្សីនេះជាសាក្សីសំខាន់ ដូច្នេះយើងអាចបង្ហាញឯកសារឱ្យគាត់មើលបាននៅក្នុងកិច្ចដំណើរការនីតិវិធីយើងនោះ។ ក៏ប៉ុន្តែសាក្សីគាត់ឆ្លើយរបៀបស្មានៗទេ។

ក៏ប៉ុន្តែមានសាក្សីដែលមកឆ្លើយបញ្ជាក់ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន ដែលស្របទៅនឹង -- ដូចដែរនឹងចម្លើយរបស់លោក ខៀវ សំផន ដែរ។ អង្គជំនុំជម្រះបានស្តាប់ចម្លើយរបស់លោក រស់ ស៊ុយ រួចទៅហើយ។ ហើយយើងមានអ្នកធ្វើការមួយទៀតនៅខាងទូរលេខ គាត់ជាអ្នកទទួលបន្ទុកក្នុងការបកប្រែសារទូរលេខ។ តើគាត់បានជម្រាបអ្វីខ្លះជូនអង្គជំនុំជម្រះនៅពេលនោះ?

[១៥:០៨:៤៥]

គឺឈ្មោះលោក នង សុផង់ គាត់បាននិយាយថា៖ “ឯកសារផ្ញើជូនលោក ខៀវ សំផន នោះគឺមិនដែលមានពាក់ព័ន្ធទៅនឹងសន្តិសុខទេ ពាក់ព័ន្ធតែខាងផ្នែកសម្ភារៈទំនិញ ឬក៏ស្បៀង”។ នៅក្នុងសវនាការគាត់បាន -- គេបានសួរគាត់ថា៖ “លោកបាននិយាយថា លោក ខៀវ សំផន ទទួលបន្ទុកខាងស្បៀងខាងសម្ភារៈ តើហេតុអីបានជាលោកដឹងថា គាត់ទទួលបន្ទុកខាងហ្នឹង?” ចម្លើយរបស់ នង សុផង់៖ “លោក ខៀវ សំផន មិនមែនជាមនុស្សដែលពិបាកស្គាល់ទេ។ នៅពេលដែលមានទស្សនកិច្ចរបស់ប្រមុខរដ្ឋ ឬមន្ត្រីជាន់ខ្ពស់របស់ប្រទេសផ្សេងៗនោះ គឺគាត់ហ្នឹងហើយជាអ្នកទទួលគណៈប្រតិភូបរទេសនោះ។ ធម្មតាមុនពេលផ្ញើសម្ភារៈទៅឱ្យមូលដ្ឋាននោះ គាត់ផ្ញើទូរលេខមកឱ្យខ្ញុំសិន ហើយខ្ញុំបន្ទាប់មក ខ្ញុំបញ្ជូនសារនោះទៅឱ្យមូលដ្ឋានដែលនឹងទទួល -- ត្រូវទទួលចំនួនសម្ភារៈ ឬក៏ស្បៀងដែលត្រូវទទួល ដែលត្រូវចែកនោះ។ ដូច្នេះរាល់ឯកសារទាំងអស់ គឺតែត្រូវឆ្លងកាត់តាមមន្ទីរទូរលេខរបស់ខ្ញុំ”។ សូមបញ្ចប់ការដកស្រង់។

[១៥:០៩:៥០]

នៅថ្ងៃទី០៣ សីហា ឆ្នាំ២០១២ លោក នង សុផង់ ដដែលគាត់បានបញ្ជាក់ថា៖ "មានការបែងចែក -- មានការចែកជូនស្បៀងទៅដល់មូលដ្ឋាន។ នេះគឺជាភារកិច្ចរបស់លោក ខៀវ សំផន ហើយក្រៅពីសកម្មភាពរបស់គាត់ក្នុងឋានៈជាអ្នកការទូត ក្នុងឋានៈជាអ្នកតំណាងឲ្យរដ្ឋកម្ពុជា ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋនោះ"។

ដូច្នេះយើង បើសិនជាយើងមើលឯកសារ E3/64 យើងអាចឃើញថាចម្លើយរបស់លោក នង សុផង់ គឺពិតជាត្រឹមត្រូវមែនគឺពាក់ព័ន្ធទៅនឹងផ្នែកដែលគាត់ដឹង។ "សំណួរ៖ ចុះ ខៀវ សំផន? ចម្លើយ៖ មានសារពីលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបែងចែកអំបិល ស្រូវ អង្ករ ក្រណាត់ សម្លៀកបំពាក់ ស្បែកជើង ហើយនិងសម្ភារៈផ្សេងៗសម្រាប់អង្គភាពនីមួយៗ ដើម្បីឲ្យអង្គភាពទាំងអស់នេះ ចែកជូនទៅដល់ប្រជាជន។ គាត់ទទួលខុសត្រូវខាងការបែងចែកសម្ភារៈទៅឲ្យប្រជាជន។ ខ្ញុំមិនទទួលសារពីលោក ខៀវ សំផន ញឹកញាប់ទេ។ ក្រៅពីសារនេះ ខ្ញុំបកប្រែសារមួយចំនួនរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងសេចក្តីណែនាំ ឧទាហរណ៍ដូចជានៅពេលមានបុណ្យជាតិធំៗម្តងៗ។ សំណួរ៖ ដូច្នេះនេះជាអ្វីដែលសង្ខេបពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន មែនទេ? ចម្លើយ៖ បាទ គឺពិតជាអ៊ីចឹងមែន"។ សូមបញ្ចប់ការដកស្រង់។

[១៥:១១:១៩]

ហើយ នង សុផង់ នៅពេលដែលគេសួរថា តើចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ សាររបស់គាត់ដែលពាក់ព័ន្ធទៅនឹង ខៀវ សំផន មានការវិវត្តន៍ដែរឬទេ? គាត់បានឆ្លើយថានៅក្នុងសវនាការថ្ងៃទី០៥ តុលា ២០១២។ "សំណួរ៖ ខ្ញុំចង់ដឹងថា តើបើតាមបទពិសោធន៍របស់លោកនោះ ក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ លោកមានកត់សម្គាល់ឃើញមានការវិវត្តន៍នៃប្រធានបទនៅក្នុងសារដែលលោក ខៀវ សំផន បានសុំឲ្យលោកបកប្រែដែរឬទេ? លោកបានឆ្លើយបញ្ជាក់អំពីប្រធានបទមួយចំនួន លោកនិយាយអំពីការបែងចែកសម្ភារៈ លោកនិយាយអំពីបុណ្យជាតិ។ តើនៅក្នុងអំឡុងឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ លោកមានកត់សម្គាល់ឃើញមានការវិវត្តន៍ ឬក៏ការផ្លាស់ប្តូរប្រធានបទនៃសារដែលលោក ខៀវ សំផន បានផ្ញើឲ្យលោកដើម្បីឲ្យលោកបកប្រែដែរឬទេ? ចម្លើយរបស់គាត់ អត់មានអ្វីថ្មីទេ គឺដដែលៗ អត់មានការវិវត្តន៍អ្វីទេ គឺថាដូចពីមុនៗអ៊ីចឹង សារហ្នឹង"។

[១៥:១២:១៨]

ខាំ ផាន់ ដែលជាសាក្សីមួយទៀតនៅខាងទូរលេខដែរ គាត់បានបញ្ជាក់ថា នៅក្នុងសវនាការថ្ងៃទី១៤ ធ្នូ ២០១២។ គេសួរគាត់ថា៖ “តើក្នុងអំឡុងសម័យដែលលោកធ្វើការនៅផ្នែកទូរលេខ លោកមាននឹកឃើញថាទទួលបានបញ្ជាពី ហែម ទេ? ជាពិសេសគឺពាក់ព័ន្ធទៅនឹងអង្ករ ស្រូវ? ចម្លើយ៖ ខ្ញុំនឹកឃើញថាស្រូវត្រូវបញ្ជូនទៅផ្នែកមួយផ្សេងទៀត ហើយ ហែម ជាអ្នកបញ្ជូនស្រូវនោះទៅ។ សំណួរ៖ បាទ អរគុណ។ តើ ហែម (ខៀវ សំផន) នេះ គាត់ទទួលការពាក់ព័ន្ធទៅនឹងបញ្ហាសារសន្តិសុខ ឬក៏មានការចាប់ខ្លួន ឬក៏ប្រភេទផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងផ្នែកសន្តិសុខនៅតំបន់ ឬក៏ផ្នែករបស់លោកទេ? ចម្លើយ៖ អត់មានទេ គាត់អត់មានធ្វើអីពាក់ព័ន្ធខាងសន្តិសុខទេ។ ខ្ញុំមិនដែលឃើញឈ្មោះគាត់ផ្សាភ្ជាប់ទៅនឹងផ្នែកសន្តិសុខទេ។ សារដែលផ្ញើដោយលោក ខៀវ សំផន ហ្នឹងគឺពាក់ព័ន្ធតែរឿងទំនិញ ឬក៏សម្ភារៈដែលត្រូវបញ្ជូនទៅតាមជនបទតែប៉ុណ្ណោះ”។ នង សុផង់ គាត់បានថា គាត់ធ្លាប់ផ្ញើសារដោយមិនចាំបាច់បកប្រែសម្ងាត់ ពីព្រោះថាវាមិនពាក់ព័ន្ធអីនឹងផ្នែកសន្តិសុខទេ។ យើងមានសាក្សីផ្សេងទៀតដែលបាននិយាយអំពីសកម្មនៅឃ្លាំង សកម្មភាពនាំចេញនាំចូល។

[១៥:១៣:៤៧]

អម្បាញ់មិញនេះ ខ្ញុំបង្ហាញអំពីភស្តុតាងនៃការបញ្ជូនស្រូវ និងអង្ករទៅកាន់តំបន់មួយចំនួន ហើយក៏មានភស្តុតាងនៃការនាំចេញផងដែរ។ ហេតុអ្វីបានជាមានការនាំចេញ? ដូច្នេះ គឺពេលនោះគឺថាយើងស្ថិតនៅក្នុងប្រទេសកម្ពុជាក្រោយសង្គ្រាម គឺមិនមានឧស្សាហ៍កម្មទេ។ ដូច្នេះធ្វើម៉េចដើម្បីឲ្យមានលុយ យើងត្រូវនាំចេញ យើងនាំចេញ។ យើងនាំចេញដើម្បីទទួលបានស្បៀង ដើម្បីយកលុយនោះទៅទិញស្បៀង។ ហើយនៅថ្ងៃទី១៣ កក្កដា ២០១៣ គឺសាក្សីបានបញ្ជាក់ថា វ៉ាន់ រិទ្ធ គឺជាប្រធានពាណិជ្ជកម្ម។ ហើយគាត់ថា វ៉ាន់ រិទ្ធ នេះធ្វើការពិនិត្យឃ្លាំងនៅមុនពេលដែលលោក ខៀវ សំផន មកដល់ឃ្លាំង ហើយមានទំនិញសម្រាប់នាំចេញ មានស្រូវ មានប៉ែល មានថ្នាំសម្លាប់សត្វល្អិត មានកៅស៊ូ មានកូតុង មានអង្ករ។ ទាំងអស់នេះគឺជាការពិតដែលកើតមាននៅទីក្រុងភ្នំពេញនៅពេលនោះមែន។

[១៥:១៥:០៧]

ស៊ឹម ហោ ក៏ជាអ្នកបញ្ជាក់ដែរ ថាមានទទួលអង្ករពីចិន។ ដូច្នេះលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងជំនួយ ដូចដែលមានបង្ហាញនៅក្នុងកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍។ ដូច្នេះលោក ខៀវ សំផន មិនមានចេតនាក្នុងការធ្វើឲ្យប្រជាជនអត់ឃ្លានដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះទេ ពីព្រោះ

ថា យើងឃើញជាហូរហែមកហើយ ថាគាត់បានទទួលសម្ភារៈ ទទួលជំនួយពីចិន ហើយមានការបែងចែកទៅតាមមូលដ្ឋាននោះ។

នៅថ្ងៃទី២១ មិថុនា ឆ្នាំ២០១២ សាក្សីមួយរូបបានបញ្ជាក់ការពិពណ៌នាពីសកម្មភាពរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងការងាររបស់គាត់។ ខ្ញុំសូមដកស្រង់៖ "គាត់ចង់ដឹងថា តើអ្វីៗត្រូវបានបញ្ជូនទៅឱ្យប្រជាជនមែន ឬក៏អត់? ហើយពេលដែលបានទទួលមែន គាត់មានការពេញចិត្ត"។ ដូច្នេះ ខ្ញុំអាចកែកំហុសបានកាលពីថ្ងៃសុក្រ លោក មាស វឿន មិនមែនទៅតំបន់១០៥ទេ គឺទៅតំបន់១០៣ ដែលត្រូវបានគិតថា គ្រប់គ្រងដោយលោក ខៀវ សំផន។ ក៏ប៉ុន្តែគាត់ថាពេលទៅដល់នោះ គឺថាមិនមានការទំនាក់ទំនងគ្នាទេ ពីព្រោះថាពេលទៅដល់ទុំង វាដាច់ទំនាក់ទំនងគ្នា នៅពេលដែលគាត់ទៅដល់តំបន់១០៣នោះ គាត់ឃើញថា សម្ភារៈ មានស្បៀងដូចជា អំបិល មុង ជាដើមនោះ មិនត្រូវបានគេចែកជូនប្រជាជនទេ។ ដូច្នេះ ជាការទទួលខុសត្រូវរបស់ថ្នាក់មូលដ្ឋាន ដែលមិនបានចែកស្បៀងទាំងអស់ហ្នឹងនោះ មិនមែនជាការទំនួលខុសត្រូវរបស់ថ្នាក់លើទេ។

[១៥:១៧:០៧]

ហើយយុទ្ធសាស្ត្ររបស់ព្រះរាជអាជ្ញាក្នុងការព្យាយាមទម្លាក់ទំនួលខុសត្រូវទៅលើលោក ខៀវ សំផន ដែលគាត់មិនមាននោះ ដែលចោទគាត់ថា គាត់ជាប្រធាន៨៧០។ ខ្ញុំសូមនិយាយសង្ខេបពីចំណុចនេះ ពីព្រោះថាពេលវេលាចេះតែកន្លងផុតទៅហើយ។ ហើយយើងក៏មានបញ្ហាអំពីវិសាលភាពផងដែរ ក៏ប៉ុន្តែវាជាចំណុចអារម្មណ៍ ក្នុងការអានកថាខណ្ឌ៥៣៨ នៃសារណារបស់សហព្រះរាជអាជ្ញា។ ជាអ្វីដែលសហចៅក្រមស៊ើបអង្កេតមិនប៊ានធ្វើ។ គាត់ថា៖ "ខៀវ សំផន ជាប្រធានមន្ទីរ៨៧០"។ ទោះបីជាយើងដឹងហើយ មកហើយថា មិនដឹងថា ៨៧០ហ្នឹងជាកន្លែងស្អីទេ។ ហើយ ស្ទីវ ហេដឌ័រ ក៏គាត់បាននិយាយផងដែរថា គេដាក់ឈ្មោះហ្នឹង គឺថាដើម្បីឱ្យមានការភ័ន្តច្រឡំ។

មានសាក្សីជាច្រើនដែលបានពន្យល់ថា គាត់ធ្វើការជាប់ជាមួយលោក ខៀវ សំផន ហើយនិយាយថា អត់មានការចាប់ខ្លួនទេ នៅពេលនោះ។ សូម្បីតែ ភី ភួន ផ្ទាល់ ក៏បានឆ្លើយផងដែរ ថាលោក ខៀវ សំផន ទំនងជាប្រធាន៨៧០។ ហើយគាត់ក៏ជាអ្នកទទួលបន្ទុកខាងការចាប់ខ្លួនដែរ ហើយមានការធ្វើដំណើរទៅមកនៅស-២១។ គាត់បាននិយាយថា នៅក្នុងសវនាការនៅថ្ងៃទី០២ សីហា ឆ្នាំ២០១២ ប្រហែលជាម៉ោង១១:៤៤នាទី នៅពេលដែលគេសួរគាត់ថា៖ "តើគាត់មានទំនាក់ទំនងអីខ្លះជាមួយលោក ខៀវ សំផន?" គាត់ថា ខ្ញុំសូមដកស្រង់, គឺនៅម៉ោង១១:៤៤នាទី, ៖ "ទំនាក់ទំនងគ្នា គឺថាមានការទទួល

អ្នកផ្សេង ហើយនិងមានការឲ្យទៅទស្សនកិច្ចនៅតាមខេត្ត។ សំណួរ៖ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ តើលោកធ្លាប់ធ្វើការ ឬសហការផ្ទាល់ជាមួយលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាចាប់ខ្លួនមនុស្ស? ឬក៏ការកម្ទេចមនុស្សដែរឬទេ? ចម្លើយ៖ អត់មានទេ អត់មានធ្វើការពាក់ព័ន្ធខាងផ្នែកចាប់ខ្លួន និងកម្ទេចហ្នឹងទេ”។

[១៥:១៩:៤៩]

នៅថ្ងៃដដែលនោះ គឺនៅម៉ោង១១:៤៨នាទី ខ្ញុំសូមដកស្រង់៖ “បើតាមខ្ញុំចាំ នៅពេលដែលគាត់ទទួលបន្តពី ឌឿន ហ្នឹងគឺមានន័យគាត់ទទួលខុសត្រូវទូទៅជំនួស ឌឿន ហើយនៅពេលដែលខ្ញុំទៅធ្វើការជាមួយគាត់ហ្នឹង គាត់ទទួលតែភ្ញៀវទេ”។ ដូច្នេះនៅក្នុងចម្លើយរបស់គាត់នេះគឺ ភី ភួន គាត់បញ្ជាក់ថាលោក ខៀវ សំផន កាន់តំណែងនេះគឺថាចាប់ពីឆ្នាំ១៩៧៨ គឺវាចេញផុតពីវិសាលភាពហើយ។

ហើយលោក ឌុចៗ ជាអ្នកដឹងរឿងច្រើនអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ បើយើងពិនិត្យមើលចម្លើយរបស់គាត់ចំពោះសហចៅក្រមស៊ើបអង្កេតនោះ គាត់មានទស្សនៈផ្សេងៗគ្នានៅពេលដែលគាត់ដឹងពីសំណុំរឿងកាន់តែច្រើន គាត់ទស្សនៈរបស់គាត់មានការប្រែប្រួល។ ដូច្នេះ យើងឃើញហើយសគីម ល្មុត ក៏អ៊ីចឹងដែរ គាត់មាន -- គាត់ស្មានៗនៅពេលដែលឃើញមានឯកសារគាត់ឆ្លើយស្មាន។ ដូច្នេះចម្លើយវាអាចមានការប្រែប្រួល។

[១៥:២១:០៤]

ហើយនៅមានសំណួរមួយបន្ទាប់ពីមានការជំទាស់របស់លោកមេធាវី វែកគែន នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២ ប្រហែលជាម៉ោង១០:០២នាទី ទៅដល់១០:០៣នាទី គឺមានការសួរសំណួរដោយសហព្រះរាជអាជ្ញាសួរទៅកាន់ ឌុច គឺយើងសូមចាប់ផ្ដើមពីម៉ោងដប់។ សំណួរទៅកាន់ ឌុច៖ “ឥឡូវនេះខ្ញុំត្រឡប់មកសួរដើមរបស់ខ្ញុំវិញ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឌឿន ហើយនិង ខៀវ សំផន តើអ្នកណាធំជាងអ្នកណា?”។ លោក លោកស្រីចៅក្រម! ចម្លើយរបស់ ឌុច គួរឲ្យចាប់អារម្មណ៍ណាស់ គាត់ឆ្លើយថា៖ “លោកប្រធានជាទីគោរព! បើតាមខ្ញុំចាំ ខ្ញុំអាចអានកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ខៀវ សំផន ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយកំណត់ហេតុនេះគឺវាត្រូវគ្នានឹងទស្សនៈរបស់ខ្ញុំ”។ គឺគាត់ថា៖ “ខ្ញុំអាន”។ គឺបានន័យថាគាត់ដឹងពីឯកសារ មិនមែនដឹងដោយខ្លួនឯងផ្ទាល់ទេ។

គឺម្ដងទៀតគឺនៅម៉ោង១០:០៣៖ “នៅពេលដែលលោកនៅស-២១ នៅពេលនោះ នៅពេល ឌឿន ចេញពីក្រសួងពាណិជ្ជកម្ម តើលោកដឹងទេថាអ្នកណាកាន់តំណែងជំនួស ឌឿន នៅគណៈមជ្ឈិម?”

ចម្លើយរបស់ ឌុច៖ “ខ្ញុំមិនច្បាស់ទេត្រង់ចំណុចនេះ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគឺមានមនុស្សម្នាក់ដែលដឹងច្រើន ហើយទទួលបញ្ជាពី ប៉ុល ពត ដែលគាត់អាចទៅដល់ស-២១ ហើយឈ្មោះម្នាក់ហ្នឹងគឺឈ្មោះ ប៉ង់”។ សហព្រះរាជអាជ្ញាបាននិយាយថា៖ “មិនមែនទេ ប៉ង់ មិនមែនជាប្រធាន៨៧០ទេ គឺប្រធានស-៧១ទេ”។ ដូច្នេះបញ្ហានេះមានបញ្ហាចម្រូងចម្រាសគ្នាពាក់ព័ន្ធទៅនឹងសកម្មភាពទាំងអស់នេះ។

[១៥:២៣:០៥]

សាក្សីមួយទៀត ដែលលើកឡើងដោយលោក ហ្វីលីព ស្សូត ពីព្រោះសហព្រះរាជអាជ្ញាបានលើកឡើងថា មានមនុស្សនិយាយថាលោក ខៀវ សំផន ជាប្រធាន៨៧០។ ហើយលោកអ្នកជំនាញ ឆេនដ៍ល័រ ហើយនិង ស្សូត គាត់បានលើកឡើងថា គឺបានលើកឡើងអំពីចំណុចនេះ ហើយនៅពេលដែលខ្ញុំសួរគាត់នៅពេលដែលស្តាប់ចម្លើយសាក្សី -- អ្នកជំនាញ ស្សូត ដើម្បីដឹងថាតើគាត់បានប្រភពណាខ្លះពាក់ព័ន្ធទៅនឹង៨៧០នោះ។ គាត់បានធ្វើការស្រាវជ្រាវពី៨៧០ ដែលជាដែននៃការងារស្រាវជ្រាវរបស់គាត់នោះ។ គាត់ពន្យល់ថាវាជារឿងសម្ងាត់ វាសម្ងាត់ណាស់។

ដូច្នេះដោយសារតែសម្ងាត់នោះមិនមានការសម្រេចឲ្យបានច្បាស់ទេ។ ដូច្នេះ សួរថាតើហេតុអីបានជាមានការសម្រេចថា ឌឿន ជាប្រធាន៨៧០ ហើយមិនមានសេចក្តីសម្រេចថាឲ្យលោក ខៀវ សំផន ជាប្រធាន? ហើយគេថាមានការសម្ងាត់ ជាមួយ ឌឿន អត់មានសម្ងាត់ទេ តែជាមួយលោក ខៀវ សំផន មានការសម្ងាត់។ ហើយនៅពេលដែលយើងសួរថា៖ “តើគាត់បានប្រភពពីណា ដែលបានបញ្ជាក់ថាលោក ខៀវ សំផន ជាប្រធាន៨៧០នៅពេលណាមួយនោះ?”។ គាត់និយាយថា៖ “មានប្រភពមួយគឺ ភី ភួន”។

[១៥:២៤:២០]

ហើយបន្ទាប់មកទៀត គាត់និយាយថាមាន សួង ស៊ីគឿន។ សួង ស៊ីគឿន មកផ្តល់សក្ខីកម្មនៅក្នុងតុលាការ។ គាត់និយាយនៅថ្ងៃទី០៦ សីហា ២០១២ ពាក់ព័ន្ធនៅពេលដែលគេសួរគាត់អំពី៨៧០។ “នៅចន្លោះឆ្នាំ៧៥ ដល់៧៩ តើលោកមានឮគេនិយាយអំពីមន្ទីរ៨៧០ទេ? ចម្លើយ៖ ខ្ញុំធ្លាប់ឮគេនិយាយពី៨៧០។ ទំនាក់ទំនងធ្វើតាមរយៈ ប៉ង់ ដែលជាប្រធាន៨៧០”។ សូមបញ្ចប់ការដកស្រង់។

ក៏មានការលើកឡើងអំពីសាក្សី សាឡុត បាន ដែលជាប្រភពសំខាន់ដែលអាច ដែលបញ្ជាក់ថាលោក ខៀវ សំផន ទំនងជាប្រធាន៨៧០។ ដូច្នេះយើងមិនដឹងថាតើ ៨៧០ហ្នឹងជាអី ហើយអ្នកដែលធ្វើការនៅក្នុងហ្នឹងធ្វើអ្វីនោះទេ។ តើ សាឡុត បាន បាននិយាយអ្វីខ្លះពាក់ព័ន្ធនឹង៨៧០ នេះ? ខ្ញុំគិតថា

ប្រហែលជានៅក្នុងសវនាការថ្ងៃទី២២ ខែមេសា គេសួរគាត់ថា -- សូមអភ័យទោស-- គឺសវនាការថ្ងៃទី២៣ ខែមេសា ប្រហែលជាម៉ោង១១:១០នាទី គឺមុនម៉ោង១១:១០នាទីបន្តិច។

"សំណួរ៖ នៅក្នុងសវនាការលោកនិយាយថាទាំង ខៀវ សំផន ទាំង ប៉ង់ កាន់ការងារនៅក្នុងមន្ទីរ៨៧០ ក៏ប៉ុន្តែខ្ញុំគិតថាដូចជាមិនច្បាស់ទេ។ អ៊ីចឹងខ្ញុំចង់ឲ្យដឹងថា តើទំនួលខុសត្រូវរបស់ ប៉ង់ និង ខៀវ សំផន នៅក្នុង៨៧០ ហ្នឹងខុសគ្នាយ៉ាងម៉េចខ្លះនៅពេលដែលពួកគាត់ធ្វើការរួមគ្នានោះ?"។ ចម្លើយរបស់ សាឡុត បាន៖ "ខ្ញុំចង់បញ្ជាក់ត្រង់ចំណុចនេះ ទំនួសខុសត្រូវគឺវាមិនដាច់គ្នាឲ្យច្បាស់ទេ។ ខ្ញុំប្រើពាក្យ ទំនួសខុសត្រូវ ក៏ប៉ុន្តែពេលដែលខ្ញុំគិតមើលទៅ ខ្ញុំគិតថាកុំឲ្យប្រើពាក្យនេះប្រើពាក្យថា "ជួយ" វិញ។ ជួយធ្វើសកម្មភាពណាមួយ ជួយធ្វើភារកិច្ចមួយ ពីព្រោះថាទំនួសខុសត្រូវវាពាក់ព័ន្ធខាងផ្នែកនយោបាយច្រើនជាង។ នៅសម័យនោះ ខ្ញុំមិនដឹងជាផ្លូវការអំពីតួនាទីរបស់អ្នកដែលនៅក្នុងហ្នឹងទេ។ ហើយពាក្យថា អ្នកទទួលខុសត្រូវ នេះគឺយើងប្រើបានច្រើនណាស់។ ចំពោះលោក ខៀវ សំផន នៅក្នុងមន្ទីរនេះ គឺមានប្រើពាក្យ ទំនួសខុសត្រូវ ក៏ប៉ុន្តែខ្ញុំមិនដឹងថាតួនាទីរបស់គាត់ និងមុខងាររបស់គាត់ពិតប្រាកដនៅក្នុង៨៧០ ហ្នឹងគឺអ្វីទេ ខ្ញុំមិនដឹងទេ។ អ្នកដែលធ្វើការនៅ៨៧០ទាំងអស់នោះ អ្នកនិយាយថាខ្លួនមានទំនួលខុសត្រូវនៅក្នុងមន្ទីរនោះ។ ដូច្នេះគេយោងជាទូទៅ គេនិយាយថា៨៧០។ អ៊ីចឹងគេមិនសំដៅទៅលើមនុស្សណាជាក់លាក់ទេ។ អ្នកដែលធ្វើការនៅទីហ្នឹងគឺមានការអីគេនិយាយថា ៨៧០ តែម្តង"។

[១៥:២៧:១៨]

យើងមិនដឹងថា តើ៨៧០ នេះពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឬក៏យ៉ាងម៉េច? គឺលោក ខៀវ សំផន គាត់ធ្លាប់បាននិយាយថា គាត់នៅ៨៧០ ហើយគាត់ទទួលខុសត្រូវក្នុងការបែងចែកសម្ភារៈ ហើយគាត់ឆ្លើយថាគាត់មានសកម្មភាពពាក់ព័ន្ធនឹងខាងពាណិជ្ជកម្ម។

សាក្សីមួយទៀត ដែលលើកឡើងដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹង ៨៧០ គឺ នង សុផង់ គឺសាក្សីនេះ យើងធ្លាប់បានលើកឡើងរួចមកហើយនៅក្នុងកថាខណ្ឌ៥៥៨។ តើ នង សុផង់ បាននិយាយអ្វីខ្លះ? គឺនៅក្នុងសវនាការថ្ងៃទី២៩ សីហា ២០១២ គឺក្រោយម៉ោង១១:៣៥នាទីបន្តិច នេះជាចម្លើយរបស់គាត់ពាក់ព័ន្ធនឹងសកម្មភាពរបស់៨៧០ និងការបែងចែកដែនទទួលខុសត្រូវ។ "សារទូរលេខភាគច្រើនពាក់ព័ន្ធនឹងសេដ្ឋកិច្ចនោះ គឺមកពីមន្ទីរ៨៧០។ ជាធម្មតាសេចក្តីណែនាំមកពី៨៧០ ពាក់ព័ន្ធទៅនឹងស្ថានភាពទូទៅនៅក្នុងប្រទេស។ វាមិនកម្រិតត្រឹមតែសេដ្ឋកិច្ច ឬក៏កសិកម្មនោះទេ ក៏ប៉ុន្តែមេដឹកនាំដែល

ទទួលខុសត្រូវសេដ្ឋកិច្ច ហើយនិងកសិកម្មនោះគឺផ្សេង។ ពិតណាស់ គឺសេដ្ឋកិច្ចនិងកសិកម្មមានភាពខុសផ្សេងគ្នា ហើយមានអ្នកទទួលខុសត្រូវផ្សេងគ្នា។ ចំពោះខាងសេដ្ឋកិច្ចនោះ បើសិនបើខ្ញុំចាំមិនច្រឡំទេ គឺថាមានអ្នកទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ស្បៀងទៅមូលដ្ឋាន គឺម្នាក់នោះគឺលោក ខៀវ សំផន ហ្នឹងហើយ"។ នេះឆ្លុះបញ្ចាំងអំពីសកម្មភាពដែលលោក នង សុផង់ បានផ្សាភ្ជាប់ទៅនឹងលោក ខៀវ សំផន គឺមិនមែនជាការចាប់ខ្លួន មិនមែនជាគោលនយោបាយទូទៅដែលត្រូវអនុវត្តក្នុងប្រទេស គឺជាការផ្គត់ផ្គង់ស្បៀងទៅតាមមូលដ្ឋាន។ ដូច្នេះយើងឃើញហើយអំពីចំណុចទាំងអស់នេះ។

[១៥:២៩:១៩]

នៅពេលដែលយើងស្ដាប់សាក្សីទាំងអស់ នៅពេលដែលយើងស្ដាប់ការរៀបរាប់អំពីសកម្មភាពរបស់លោក ខៀវ សំផន យើងគិតឃើញថា វាមានភាពស៊ីសង្វាក់គ្នានៅក្នុងចំណោមសក្ខីកម្មទាំងអស់នោះ។ ដូច្នេះគាត់ៗឆ្លើយថា-- លោក ខៀវ សំផន ឆ្លើយថា៖ "ខ្ញុំធ្វើការនៅ៨៧០ ពាក់ព័ន្ធនឹងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងការទិញទំនិញ ពាក់ព័ន្ធនឹងការនាំចេញ ពាក់ព័ន្ធនឹងការបែងចែកនាំស្បៀងទៅតាមមូលដ្ឋាន"។ ចំណុចនេះ គឺអ្វីដែលបានលើកឡើងដោយលោក ខៀវ សំផន ផ្ទាល់គាត់មិនដែលបដិសេធចំណុចនេះទេ។ ហើយសហព្រះរាជអាជ្ញាព្យាយាមធ្វើឱ្យមានភាពច្របូកច្របល់ពាក់ព័ន្ធនឹងខាងផ្នែកពាណិជ្ជកម្ម។ សូម្បីតែឈ្មោះរបស់លោក ខៀវ សំផន មិនមានការដាក់ចុះនៅក្នុងឯកសារដូចគ្នាហ្នឹង ក៏គាត់ធ្វើឱ្យមានការច្របូកច្របល់ គាត់ព្យាយាមដាក់ការទទួលខុសត្រូវលោក ខៀវ សំផន ឱ្យធ្វើជាប្រធាន៨៧០ ហើយដែលគ្មានអ្នកណាម្នាក់អាចដឹងច្បាស់ សូម្បីតែឯកសារក៏មិនបានបញ្ជាក់ច្បាស់ថាតើ ៨៧០ ហ្នឹងធ្វើអ្វីឱ្យពិតប្រាកដដែរ។

[១៥:៣០:២០]

យើងមានសក្ខីកម្មជាច្រើនដែលបានបញ្ជាក់អំពីសកម្មភាពរបស់លោក ខៀវ សំផន ផ្ទាល់។ សូម្បីតែ អៀង សារី ផ្ទាល់ក៏គាត់បានឆ្លើយផងដែរថា លោក ខៀវ សំផន -- គាត់មិនមែននិយាយខាងជូនសហព្រះរាជអាជ្ញាទេ គាត់និយាយប្រាប់លោក ស្ទីវ ហេដឌ័រ នៅក្នុងកិច្ចសម្ភាសន៍មួយ។ គាត់បាននិយាយរឿងជាច្រើន។ ហើយសូម្បីតែលោក អៀង សារី ផ្ទាល់នោះក៏គាត់បាននិយាយថា៖ "គាត់ជាប្រធាន៨៧០នៅពេលណាមួយនោះ ប៉ុន្តែមិនដឹងថាមានអីកើតឡើងទេ គាត់ដូចខ្ញុំអ៊ីចឹង"។ នេះជាចម្លើយរបស់លោក អៀង សារី។

ពិតណាស់នៅថ្ងៃនេះ យើងអាចព្យាយាមធ្វើឱ្យមានភាពច្របូកច្របល់គ្នាពាក់ព័ន្ធទៅនឹង ៨៧០

នេះ។ ហេតុអីបានជាសហព្រះរាជអាជ្ញាគាត់បានព្យាយាមធ្វើការភ្ជាប់ទំនាក់ទំនងលោក ខៀវ សំផន ទៅ៨៧០? ហេតុអីបានជាយើងមានភស្តុតាង មានឯកសារជាច្រើនដែលបង្ហាញថាគាត់ជួយខាងផ្នែកពាណិជ្ជកម្ម ពាក់ព័ន្ធនឹងខាងពាណិជ្ជកម្ម ហេតុអីបានជាគាត់មិនមើលលើចំណុចទាំងអស់នេះ ហើយគាត់ព្យាយាមរុញលោក ខៀវ សំផន ឲ្យធ្វើជាប្រធាន៨៧០ ទៅវិញនោះ?

យើងឃើញហើយមិនមានការបញ្ជាក់ឈ្មោះនៅក្នុងឯកសារថា គាត់ជាប្រធាន៨៧០ ទេគឺគេផ្សាភ្ជាប់ឈ្មោះគាត់ទៅនឹងទំនិញ ទៅនឹងការនាំចេញសម្ភារៈ។ ដូច្នេះ គេព្យាយាមភ្ជាប់ទំនាក់ទំនងគាត់ដើម្បីឲ្យគាត់ដឹង -- ដើម្បីបញ្ជាក់ថាគាត់ដឹងពីបញ្ហាសន្តិសុខ បញ្ហាចាប់ខ្លួន។ នេះហើយជាមូលហេតុដែលសហព្រះរាជអាជ្ញាដែលទោះបីជាមានភាពច្របូកច្របល់នៃសក្ខីកម្ម ភាពច្របូកច្របល់នៃចម្លើយរបស់សាក្សីក៏ដោយនោះ គាត់ព្យាយាមបញ្ជាក់ថាគាត់ជាប្រធាន៨៧០ ពីព្រោះគេត្រូវការគាត់។ ហើយគេត្រូវការធ្វើយ៉ាងនេះ ដើម្បីបង្ហាញពីចេតនាឧក្រិដ្ឋ ហើយដែលជាអ្វីដែលទូលំទូលាយបំផុត និងអ្វីដែលកើតមានឡើងនៅប្រទេសកម្ពុជាទាំងមូលតែម្តងនោះ។ ក៏ប៉ុន្តែនេះមិនមែនជាការពិតទេបើតាមអង្គហេតុនោះ។

[១៥:៣២:៣៤]

ចំណុចមួយទៀតលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ចំណុចមួយទៀតដ៏សំខាន់គឺជាចម្លើយរបស់លោក ខៀវ សំផន ដែលគាត់បានឆ្លើយពេលក្រោយមកទៀត ហើយនិងការពិតគឺថាភាគច្រើនជារឿងរ៉ាវដែលគាត់បាននិយាយប្រាប់ពេលក្រោយរបបខ្មែរក្រហមទេ។ ហើយភាគច្រើនអ៊ីចឹងទេ ជាជាងច្រើនជាងអ្វីដែលគេនិយាយនៅក្នុងសាលសវនាការនេះ សាក្សីដែលនិយាយនៅទីនេះពេលគេនិយាយថាដូចមាន គាត់មិនស្មោះត្រង់អី ឬក៏គាត់ស្មោះត្រង់នឹង ប៉ុល ពត ខ្លាំង។ ហើយនៅពេលដែលខ្ញុំមើលឃើញវីដេអូដែលលោក ខៀវ សំផន និយាយនៅក្នុងខ្ទម នៅក្នុងព្រៃដែលគាត់រស់នៅជាច្រើនឆ្នាំ រស់នៅដូចជាអ្នកដែលត្រូវគេនិរទេសខ្លួន គាត់ពន្យល់ថា គាត់សរសើរ ប៉ុល ពត ដោយសារគាត់អ្នកអាចធ្វើបដិវត្តន៍ជាមួយប្រជាកសិករបាន។ ហើយប្រសិនបើយើងប្រៀបធៀបគំនិត ខៀវ សំផន ដែលថាល្អឥតខ្ចោះនោះ ប្រៀបធៀបគំនិតទាំងអស់ហ្នឹងនៅក្នុងវគ្គសិក្សារៀនសូត្រ ហើយនិងអ្វីដែលគាត់ឃើញថា មានការប្រែប្រួល ការវិវត្តន៍ ហើយអ្វីដែលគាត់ឃើញដូចលោក គង់ សំអុន បានលើកឡើងនោះ។ អ៊ីចឹងយើងយល់ថា បញ្ហារបស់គាត់នោះមិនមែនថាគាត់ហ្នឹងបដិសេធអ្វីដែលកើតមានឡើងនៅឆ្នាំ ចន្លោះ៧៥-៧៩ទេ។ ក៏ប៉ុន្តែមិនមែនគាត់ចង់និយាយអ៊ីចឹងទេ គឺថាគាត់មិនមែនដោយសារ គាត់តស៊ូដើម្បីឲ្យមានអីកើតឡើងចន្លោះ៧៥-៧៩ទេ។

[១៥:៣៤:២១]

ក៏ប៉ុន្តែសហព្រះរាជអាជ្ញានោះគេនិយាយថា ក្រោយពីឆ្នាំ៧៩នោះ ខៀវ សំផន នៅតែកាន់នៅក្នុងចលនាខ្មែរក្រហមដដែល កាន់នូវចលនាខ្មែរក្រហមរហូតដល់ពេលដែលគាត់ថាបោះបង់ឆាកនយោបាយចោលនេះទាល់តែ ប៉ុល ពត ស្លាប់ហើយទេ នៅប៉ៃលិននោះ។ ពីព្រោះថាសហព្រះរាជអាជ្ញាគេបានប្រៀបធៀបជាមួយនឹងសម្តេច សីហនុ ហើយខ្ញុំឥឡូវក៏សូមប្រៀបធៀបដែរ គឺថានៅឆ្នាំ១៩៨២ហ្នឹងថាមានការ -- មានរដ្ឋាភិបាលចម្រុះជាមួយ សីហនុ។ ទោះបីជាថាកាលណោះ គេមិនសូវត្រូវគ្នាក៏ដោយជាមួយ ប៉ុល ពត នោះ សីហនុ គាត់ក៏នៅតែយល់ព្រមចងសម្ព័ន្ធភាពដែរ។ ហេតុអ្វី? ពីព្រោះថា នៅសម័យនោះប្រទេសរបស់គាត់ត្រូវបានឈ្លានពាន។ អ៊ីចឹងគាត់គិតទៅប្រទេសគាត់ជាបឋម។ ប្រហែលជាកាលនោះ គាត់គិតទៅអំណាចគាត់ផងដែរ។ អង្គាល់នោះ គឺថាគាត់គិតទៅយ៉ាងដូច្នេះ។ ហើយនៅពេលដែលលោក ខៀវ សំផន និយាយថា នៅក្នុងសំណេររបស់គាត់នេះ គាត់និយាយអំពីទស្សនៈរបស់គាត់ លើឯករាជ្យដាច់ខាតរបស់ប្រទេសកម្ពុជា។ អ៊ីចឹងហើយបានគាត់ខំតស៊ូ មិនមែនដើម្បីដាក់ប្រជាជនខ្លួនឯងឲ្យក្លាយជាទាសករទេ មិនមែនដើម្បីវាយប្រហារលើប្រជាជនស៊ីវិលទេ។ ក៏ប៉ុន្តែដើម្បីឲ្យអ្វីៗទាំងឡាយប្រសើរឡើងជាង នៅក្នុងស្ថានភាពមួយដ៏ធ្ងន់ធ្ងរ ដើម្បីប្រទេសខ្លួនតែប៉ុណ្ណឹង។ ហើយអ៊ីចឹងគាត់សុខចិត្តបរិច្ចាគអ្វីៗទាំងអស់។

[១៥:៣៦:១២]

ឥឡូវ ខ្ញុំសូមចូលមកនិយាយពីពាក្យដែលនិយាយថា៖ "យើងក្រោយពីឆ្នាំ៧៩"។ ខៀវ សំផន គាត់និយាយពាក្យថា "យើង"។ នៅពេលដែលអ្នកកាសែតសួរគាត់នោះ ពេលកាលនុំងមានសង្គ្រាមនឹងវៀតណាមខ្លាំងណាស់ គាត់ប្រើពាក្យ "យើង"។ ពីព្រោះថា វាដូចនៅពេលសម័យរណសិរ្សអ៊ីចឹងដែរ នៅឆ្នាំទសវត្សរ៍ឆ្នាំ៧០ ហ្នឹងគាត់ចង់បានរណសិរ្សរួបរួមជាតិមួយ។ គាត់មិនចង់ផ្តាច់ខ្លួនពីរណសិរ្សទេ អ៊ីចឹងដោយសារមាន អង្គាល់ណោះមានមានរឿងរ៉ាវច្រើនណាស់ ដែលគាត់មិនដឹង។ វាត្រូវបានគេនិយាយលើរបបហ្នឹង ក៏ប៉ុន្តែវា -- គាត់មិនទាន់ដឹងទេ គាត់នៅតែជឿលើការឃោសនានៅសម័យហ្នឹងទេ។

អ៊ីចឹងខ្ញុំសូម -- យើងឃើញមានវីដេអូមួយដែលព្រះរាជអាជ្ញាបានបញ្ចាំង។ ឃើញ ខៀវ សំផន ជាមួយនឹងសៀវភៅជាច្រើនទាក់ទងទៅនឹងរបបខ្មែរក្រហម។ ហើយគាត់អានសៀវភៅនេះជាច្រើនដង ហើយគាត់សរសេរក៏ច្រើនដែរ។ គាត់និយាយថាគាត់មិនដែលបាននិយាយ គាត់បានសរសេរច្រើនហើយ គាត់និយាយក៏ច្រើនដែរទាក់ទងរបបខ្មែរក្រហមនេះ។ អ៊ីចឹងមនុស្សដូចជា ខៀវ សំផន នេះដែលគាត់ចង់

ថាគាត់ជឿអី ហេតុអីបានអ្វីដែលគាត់ជឿ ជំនឿជឿជាក់គាត់នោះមិនអាចដំណើរការបាននោះ តើនេះ -- តើបានន័យថាម៉េច? បានថាគាត់ជាដឹង ឬក៏មិនដឹង? តាមពិតគាត់ជាអ្នកចង់ដឹងទេ កាលណាគាត់ខំសួរសំណួរយ៉ាងដូច្នេះទៅកាន់ខ្លួនឯងនេះ។ អ៊ីចឹងប្រហែលជាចំពោះគាត់នោះ ប្រហែលជាស្រួលជាងក្នុងការដែលទទួលស្គាល់ថា ពួកគេនោះបានប្រព្រឹត្តបទឧក្រិដ្ឋនោះ ហើយគេចង់ធ្វើបទឧក្រិដ្ឋហ្នឹង។ ក៏ប៉ុន្តែលោក ខៀវ សំផន ចង់គោរពការពិតរបស់ខ្លួននូវអ្វីដែលគាត់ដឹង ព្រោះថាអ្វីដែលគាត់ដឹងហ្នឹង គឺថាមិនមែនជាគោលបំណងទេក្នុងការធ្វើឲ្យប្រជាជនឈឺចាប់ ហើយគឺថាធ្វើឲ្យពួកប្រជាជននេះប្រសើរទេ។ ព្រោះថានេះជាការបរាជ័យ ដោយសារកាលណោះស្ថានភាពលំបាកពេក ហើយពុំមានការរៀបចំរចនាសម្ព័ន្ធត្រឹមត្រូវ ខ្វះសមត្ថភាព ក៏ប៉ុន្តែពួកខ្មែរក្រហមមិនមានចេតនាឧក្រិដ្ឋទេ។ ហើយនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងព្រហ្មទណ្ឌត្រូវគិតពីចំណុចនេះ សំខាន់មែនទែន។

[១៥:៣៨:៣៤]

ដូច្នេះ ខ្ញុំត្រូវដកស្រង់ ទោះបីថាចុងក្រោយនេះ លោក ខៀវ សំផន នឹងនិយាយការសន្និដ្ឋានចុងក្រោយក៏ដោយ។ ក៏ប៉ុន្តែលោក ខៀវ សំផន បានខំសរសេរទៅកាន់ជនរួមជាតិរបស់ខ្លួន សៀវភៅមួយទាក់ទងគោលជំហរថ្មីៗរបស់គាត់ គឺឯកសារ E3/18។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំគិតថាកាតព្វកិច្ចរបស់ខ្ញុំ ខ្ញុំត្រូវតែសហការជាមួយកម្លាំងគ្រប់ ដើម្បីដោះស្រាយបញ្ហាដែលប្រឈម។ នេះជាអ្វីដែលខ្ញុំធ្វើនៅពេលដែលឱកាសហុចហើយ តាមលទ្ធភាព និងលទ្ធភាពរបស់ខ្ញុំ”។ សូមបញ្ចប់ការដកស្រង់។

ហើយគាត់សរសេរនូវសំបុត្រមួយទៀត ដែលគាត់សរសេរជូនទៅប្រជាពលរដ្ឋហ្នឹង ថ្ងៃទី១៦, ១៧ ឆ្នាំ -- សីហា ២០០១។ “ខ្ញុំគ្រាន់តែជាបញ្ញាជនដែលស្រមើលស្រមៃ ដែលក្នុងការបំពេញកាតព្វកិច្ចចំពោះប្រទេសជាតិតែប៉ុណ្ណឹង។ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ឧត្តមគតិរបស់ខ្ញុំ ខ្ញុំមិនដែលគិតថា ខ្ញុំនឹងក្លាយទៅជាអ្នកដឹកនាំ ហើយនិងក្លាយជាអ្នកសម្លាប់គេនោះទេ។ ខ្ញុំខំបំពេញការងារដោយមិនឲ្យខកខានតែប៉ុណ្ណោះ”។

[១៥:៤០:០២]

ហើយខ្ញុំ ខ្ញុំសូមដកស្រង់មួយទៀត៖ “ជនរួមជាតិដែលបាត់បង់ក្រុមគ្រួសារជាទីស្រឡាញ់របស់គេនៅសម័យនោះ ខ្ញុំសូមទោស ខ្ញុំសូមឲ្យអត់ទោសពីភាពឆោតល្ងង់របស់ខ្ញុំ។ ខ្ញុំស្មានថា ខ្ញុំធ្វើយ៉ាងដូច្នេះទៅដើម្បីឲ្យប្រទេសជាតិរីកចម្រើន ហើយខ្ញុំអាចរស់បាន ហើយខ្ញុំមិនដែលនឹកស្មានថា ការធ្វើយ៉ាងដូច្នេះវាក្លាយជាទង្វើកាប់សម្លាប់មនុស្សនោះទេ”។ ដូច្នេះអស់លោក លោកស្រីចៅក្រមត្រូវពិចារណា

ត្រង់ចំណុចនេះ ហើយត្រូវគោរពអំពីវិធាននីតិវិធី ហើយនិងគោរពសេចក្ដីសម្រេចរបស់ខ្លួនផងដែរ គោរពដីកាដំណោះស្រាយ បំបែកដំណើរការនីតិវិធីខ្លួនឯងផងដែរ។

លោកប្រធាន អស់លោក លោកស្រីចៅក្រម! បុរសនេះគឺលោក ខៀវ សំផន ដូចដែលបានខ្ញុំនិយាយកាលពីដើមនេះអ៊ីចឹង។ បុរសនេះជាមនុស្សតែឯងទេនៅក្នុងកន្លែងជំនុំជម្រះសេចក្ដីនេះដែលតំណាងឱ្យសម័យមួយចប់ហើយសម័យហ្នឹង។ ក៏ប៉ុន្តែយើងនៅទីនេះ អ្នកខ្លះគេនៅចាំ គឺជាសម័យមួយដែលមានឧត្តមគតិរបស់ខ្លួន ដែលប្រហែលជាមិនធ្វើមិនកើត មិនអាចសម្រេចបាន ហើយអាចមានកង្វះខាតជាច្រើនដោយពុំបានចាត់វិធានការឱ្យបានឆាប់រហ័ស។ ក៏ប៉ុន្តែគឺជាបុរសដែលគេចង់ធ្វើឱ្យគាត់ក្លាយជាបិសាច ហើយខ្ញុំក៏ចង់ប្រាប់ថាគាត់មិនបានចង់ធ្វើខ្លួនឱ្យក្លាយជាបិសាចទេ ឧត្ដមគតិរបស់គាត់ខុសពីនេះ។

[១៥:៤២:០៥]

ខ្ញុំសូមនិយាយតែមួយម៉ាត់ទេ អំពីច្បាប់ អំពីសហឧក្រិដ្ឋកម្មរួមដែលសហព្រះរាជអាជ្ញាចង់ឱ្យអនុវត្តនៅទីនេះ មិនអាចធ្វើទៅបានទេនៅក្នុងក្របខ័ណ្ឌ នៅក្នុងវិសាលភាពនៃអង្គជំនុំជម្រះយើងនេះ។ ពីព្រោះ -- ចំពោះខាងការពារក្ដីវិញ ខ្ញុំសូមរំឭកថាអ្វីដែលយើងបាននិយាយលម្អិតនៅក្នុងសារណាសន្និដ្ឋានបញ្ចប់របស់យើង ហើយនិងនៅក្នុងសេចក្ដីសន្និដ្ឋានទាក់ទងនឹងច្បាប់ដែលអាចអនុវត្តបាននៅពេលនេះ ស្របទៅតាមយុត្តិសាស្ត្រ គឺថាមានទិសដៅចុងក្រោយ ហើយនិងផែនការរួម មិនមែនជាការយល់ស្របផ្នែកបញ្ញាជាមួយនឹងផែនការចុងក្រោយទេដែលបញ្ជាក់ពីចេតនាឧក្រិដ្ឋកម្មនោះ។ ក៏ប៉ុន្តែទាល់តែមានការចូលរួមពិតប្រាកដទៅមធ្យោបាយធ្វើឧក្រិដ្ឋហ្នឹងទេ បានអាចថាមានការអនុវត្តបទឧក្រិដ្ឋ។

ដូច្នេះអ្វីដែលអស់លោក លោកស្រីចៅក្រមបានឮនៅទីនេះ ហើយអ្វីដែលគេពណ៌នានៅទីនេះលើដំណើរការ ហើយនិងតួនាទីដែលនិយាយរៀបរាប់ដោយសាក្សីនៅទីនេះ។ ទោះជាយ៉ាងណាក្ដី គឺថាតាមរយៈទាំងអស់នេះ គឺថាវាបង្ហាញអំពីការចូលរួមក្នុងការធ្វើសហឧក្រិដ្ឋកម្មរួមដែរឬក៏អត់? តើក្នុងក្របខ័ណ្ឌនៃការជម្លៀសលើកទី១ លើកទី២ ឬក៏នៅទួលពោធិ៍ជ្រៃនេះ អ្វីដែលធ្វើដោយ ខៀវ សំផន ហ្នឹង តំណែងរបស់គាត់ ដែលតំណែងខែល ឧបកិច្ច។ តើតាមរយៈទាំងអស់នេះ តើអស់លោក លោកស្រីចៅក្រមអាចឃើញថាគាត់បានចូលរួមដោយប្រសិទ្ធភាព ឬក៏មានមធ្យោបាយអីទេ? ចម្លើយគឺថាអត់មានទេ បើសិនជាអស់លោក លោកស្រីចៅក្រមរកមិនឃើញទេ គឺថាត្រូវដោះលែងគាត់។ ពីព្រោះ -- ទោះបីជាថាមានការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយចុះ ទោះបីជាមានសម្ពាធរបស់មតិ

អន្តរជាតិក៏ដោយ ត្រូវដោះលែងដែរ ទោះបីជាថាមនុស្សទូទៅគិតថាអ្វីៗទាំងអស់នោះត្រូវបានសម្រេចអស់ហើយ។

[១៥:៤៤:៤៧]

អស់លោក លោកស្រីចៅក្រម ជាចៅក្រមដែលមានកាតព្វកិច្ចចំពោះមុខច្បាប់ មានកាតព្វកិច្ចគោរពនីតិវិធី ហើយមានកាតព្វកិច្ចក្នុងការរក្សាឯករាជ្យភាពរបស់ខ្លួន។ តើអស់លោក លោកស្រីចៅក្រមនឹងបំពេញកាតព្វកិច្ចនេះបានសម្រេចដែរឬទេ? មានតែអស់លោក លោកស្រីចៅក្រមទេ ដែលអាចឆ្លើយនឹងសំណួរនេះបាន នៅក្នុងពេលដែលលោក លោកស្រីចៅក្រមចេញសាលក្រម។ អ៊ីចឹងសូមថាត្រូវចាំថា អំណះអំណាងនៃសាលក្រមរបស់អស់លោក លោកចៅក្រម នឹងមានគេអាននៅថ្ងៃអនាគត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ ថ្ងៃនេះឃើញថា កិច្ចដំណើរការប្រព្រឹត្តទៅនៃសេចក្ដីថ្លែងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី មេធាវីការពារក្ដីលោក ខៀវ សំផន គឺបានបញ្ចប់តាមកាលពេលវេលាដែលបានចែកជូន។

ហើយមុននឹងសម្រាកនៅថ្ងៃនេះ អង្គជំនុំជម្រះសូមសួរសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញា អំពីពេលវេលាដែលអង្គជំនុំជម្រះនឹងផ្ដល់ឲ្យធ្វើសេចក្ដីសន្និដ្ឋានតបបញ្ចប់កិច្ចពិភាក្សាដេញដោល នៅថ្ងៃខានស្អែក ថ្ងៃពុធ ទី៣០ ខែតុលា នោះ។ ថាតើទី១ តើក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រើប្រាស់ពេលវេលាប៉ុន្មានដែរ? ក៏ដូចគ្នាក្នុងបែងចែកពេលវេលាជាមួយនឹងសហព្រះរាជអាជ្ញាយ៉ាងដូចម្ដេចដែរ? ពីព្រោះអង្គជំនុំជម្រះបានជូនដំណឹងទៅដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ថាមានពេលវេលាមួយថ្ងៃ។ ឥឡូវនេះថាតើក្រុមទាំងពីរនេះ ការបែងចែកពេលវេលាយ៉ាងម៉េចដែរ?

សូមលោកក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនិយាយមុន។

[១៥:៤៧:២២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ យើងប្រើពេលវេលាទាំងមូលដែលបានផ្ដល់ជូនដោយអង្គជំនុំជម្រះគឺមានន័យថា មួយភាគបួននៃថ្ងៃ គឺថា១ម៉ោង១០នាទី ទៅតាមការកំណត់របស់អង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការផ្តល់ព័ត៌មាននេះ។ ចុះខាងតំណាងសហព្រះរាជអាជ្ញាយ៉ាងម៉េចដែរ?

**លោក នីកូឡាស គូមជែន៖**

សូមជម្រាបសួរលោកប្រធាន យើងនឹងគោរពតាមកំណត់ ដូចដែលតុលាការបានបែងចែកជូនខាងយើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្តល់ព័ត៌មាននេះ។

ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះត្រូវប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃខានស្អែក ថ្ងៃពុធ ទី៣០ ខែតុលា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

អង្គជំនុំជម្រះសូមបញ្ជាក់ថា នៅថ្ងៃស្អែកនេះ គឺថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣ ជាថ្ងៃឈប់សម្រាកបុណ្យជាតិ អង្គជំនុំជម្រះមិនធ្វើសវនាការទេ។

អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនជ្រាបផងដែរថា នៅថ្ងៃពុធ ខានស្អែកនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ឡើងធ្វើសេចក្តីសន្និដ្ឋានតបបញ្ចប់កិច្ចពិភាក្សាដេញដោលផ្នែក០០២/០១នេះ។ ហើយប៉ុន្តែដើម្បីឲ្យបានកាន់តែច្បាស់ និងសម្របសម្រួលដល់កិច្ចដំណើរការសវនាការប្រព្រឹត្តទៅបានល្អ មានប្រសិទ្ធភាព អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់នៃរឿងក្តីថា នៅក្នុងអំឡុងពេលនៃធ្វើសេចក្តីសន្និដ្ឋានតប ភាគីគប្បីផ្តោតទៅលើបញ្ហាទាំងឡាយដែលជាកម្មវត្ថុ ជាមូលដ្ឋានក្នុងការពិនិត្យពិចារណាវាយតម្លៃសម្រាប់ការវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០១។

ដូច្នេះសូមភាគី មន្ត្រីបុគ្គលិក នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមឲ្យបានមុនម៉ោងកំណត់នេះ។

[១៥:៤៩:៤៣]

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់

ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ នៅព្រឹកថ្ងៃពុធ ទី៣០ ខែតុលា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួន។ ដោយឲ្យនាំលោក ខៀវ សំផន មកចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ដោយឡែក លោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥០នាទី)*